មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ឆេង ភាព ភេទស្រី អាយុ៥៨ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ "ពាណិជ្ជកម្ម"**

**ស្រុកកំណើតនៅភូមិស្តៅ ឃុំស្តៅ ស្រុកគូលេន ខេត្តព្រះវិហារ**

**រស់នៅភូមិទួលពង្រ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៧និង១៨ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ម៉ម សុវណ្ណ**

**០១:៤៦:២២និង០២:៤០:៥៩**

**១០៣ទំព័រ**

សុវណ្ណៈ ចឹងជាដំបូងខ្ញុំសុំជរាបសួរមីង ។

ភាពៈ ចាស ។

សុវណ្ណៈ ហើយខ្ញុំសូមណែនាំខ្លួនខ្ញុំឲ្យស្គាល់ ខ្ញុំឈ្មោះ ម៉ម សុវណ្ណ ខ្ញុំជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមកថ្ងៃនេះគឺថាខ្ញុំមកធ្វើការនៅស្រុកត្រពាំងប្រាសាទថ្ងៃទី១៧ខែ១២ឆ្នាំ២០១៣ ហើយខាងខ្ញុំមកធ្វើការនៅរឿងរ៉ាវសរសេរចងក្រងសៀវភៅប្រវត្តិសាស្ត្រស្រុកអន្លង់វែង ហើយ ចឹងក្នុងការចងក្រងសៀវភៅហ្នឹងបាន លុះត្រាតែខាងខ្ញុំជួបអ៊ំពូមីងដែលធ្លាប់រស់នៅហ្នឹងពីមុនមកដែលគាត់បានដឹងរឿងរ៉ាវច្រើន ។

ភាពៈ ចាស ។

សុវណ្ណៈ ចឹងមានតែអ៊ំពូមីងទាំងអស់ហ្នឹង ដែលជាពិភពឯកសាររស់ដើម្បីប្រាប់រឿងរ៉ាវដល់ក្មេងជំនាន់ក្រោយឬប្រាប់ដល់អ្នកសិក្សាស្រាវជ្រាវផ្សេងៗឲ្យមានគំនិតក្នុងការសរសេរមីង ។

ភាពៈ ចាស ។

សុវណ្ណៈ ចឹងជាដំបូងខ្ញុំចង់ឲ្យមីងណែនាំខ្លួន ថាមីងឈ្មោះអីដែរ?

ភាពៈ ខ្ញុំឈ្មោះ ភាព ឈ្មោះ ឆេង ភាព ។

សុវណ្ណៈ មីងសព្វថ្ងៃអាយុប៉ុន្មានហើយ?

ភាពៈ ខ្ញុំអាយុ៥៨ ។

សុវណ្ណៈ មីងកើតឆ្នាំណាដែលមីងមានចាំទេ?

ភាពៈ ៥៨ហ្នឹងខ្ញុំកើតឆ្នាំ១៩៥៨ ។

សុវណ្ណៈ ចឹងឆ្នាំ១៩៥៨?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងនៅភូមិនេះគេហៅភូមិអីគេ?

ភាពៈ ភូមិទួលពង្រ ។

សុវណ្ណៈ ឃុំ?

ភាពៈ ឃុំទួលប៉ាច់ ។

សុវណ្ណៈ ស្រុក?

ភាពៈ ស្រុកត្រពាំងប្រាសាទ ។

សុវណ្ណៈ ខេត្ត?

ភាពៈ ខេត្តឧត្តរមានជ័យ ។

សុវណ្ណៈ ចឹងមីងពីមុនមានភូមិកំណើតនៅណាដែរ?

ភាពៈ ភូមិកំណើតនៅស្ដៅ ។

សុវណ្ណៈ នៅភូមិស្ដៅ?

ភាពៈ ចាស ។

សុវណ្ណៈ ឃុំ?

ភាពៈ ឃុំស្ដៅ ។

សុវណ្ណៈ ស្រុក?

ភាពៈ ស្រុកគូលេន ។

សុវណ្ណៈ ខេត្ត?

ភាពៈ ខេត្តព្រះវិហារ កំណើតឪពុកម្ដាយខ្ញុំគាត់កើតនៅទីនោះ ។

សុវណ្ណៈ នៅទីរួមខេត្ត?

ភាពៈ អត់ទេ នៅទីរួមឃុំ ស្រុកគូលេន ខេត្តព្រះវិហារ ។

សុវណ្ណៈ ចឹងស្រុកគូលេន ខេត្តព្រះវិហារ?

ភាពៈ ចាស!កាលពីដើមដែលខ្ញុំកើតដឹងក្ដីទៅ ដល់ឥឡូវគេកែប្រែយ៉ាងម៉េចខ្ញុំអត់ដឹង ដឹងថាពីដើមមក ។

សុវណ្ណៈ ចឹងគ្រួសារមីង អឺប្រុសមិញគាត់ឈ្មោះអីគេ?

ភាពៈ គាត់ឈ្មោះ កុយ ។

សុវណ្ណៈ គាត់ឈ្មោះអីគេពេញ?

ភាពៈ ឈ្មោះ ឯក កុយ ។

សុវណ្ណៈ គាត់អាយុប៉ុន្មានហើយសព្វថ្ងៃ?

ភាពៈ អាយុ៧៧ ។

សុវណ្ណៈ	ហើយមីងស្គាល់គាត់ពេលណាដែលទៅ?

ភាពៈ	ពិបាកប្រាប់ណាស់ ស្គាល់តាំងពីស្រុកដែរ តែមកនៅភ្នំនេះបាន បានមីងណា ។

សុវណ្ណៈ	ចឹងរៀបការឆ្នាំណា?

ភាពៈ	ខ្ញុំដែលយកគាត់នេះឆ្នាំ ខ្ញុំយកតានេះក្រោយទេ តាមុន ប្តីខ្ញុំមុនខ្ញុំយកតាំងពីឆ្នាំ១៩៧៨ បានកូនមួយពីរចឹងទៅឆ្នាំ៨០ យើងរត់ឡើងភ្នំទៅ ចឹងក៏បែកគ្នាទៅ ។

សុវណ្ណៈ	ចឹងមកដល់សព្វថ្ងៃមីងមានកូនប៉ុន្មានហើយ?

ភាពៈ	ខ្ញុំយកតាក្រោយនេះបានកូនមួយ ហើយកូនមុនមានពីរ មួយមីចៀនចេកមួយ មួយទៀតនៅទៀតនៅត្រពាំងប្រាសាទ ស្រីទាំងពីរ ។

សុវណ្ណៈ	ចឹងកូនមានបីហ្នឹងស្រីទាំងបី?

ភាពៈ	ចាស ។

សុវណ្ណៈ	គ្រួសារមុនកូនពីរនាក់?

ភាពៈ	ចាស ។

សុវណ្ណៈ	ចឹងគ្រួសារអ៊ំក្រោយនេះមានម្នាក់ទៀត?

ភាពៈ	ចាស!បានកូនស្រីមួយដែរ ។

សុវណ្ណៈ	ហើយគាត់ធ្វើអីគេប្រវត្តិតស៊ូនៅលើភ្នំមីង?

ភាពៈ	ការតស៊ូលើភ្នំ គាត់ធ្វើអីទេ វាមិនបានជា ។

សុវណ្ណៈ	ធ្វើទាហានដែលឬអត់ទេ?

ភាពៈ	ចាស!ទាហានដែរ ។

សុវណ្ណៈ	កងពលខាងណា?

ភាពៈ	កងពលប៉ុន្មានទេ ៨១២ដឹង៩១២ កងពលតាហឿន ៩១២ចឹងដឹង ។

សុវណ្ណៈ	ចឹង៩១២?

ភាពៈ	ចាស ។

សុវណ្ណៈ	ចឹងគាត់អាយុប៉ុន្មានវិញ សព្វថ្ងៃប៉ុន្មាន?

ភាពៈ	តា៧៧ គាត់ប្រាប់ខ្ញុំថា៧៧ ខ្ញុំមិនបានដឹងគាត់សួរម្តងអាយុប៉ុននេះ ។

សុវណ្ណៈ	ចឹងសព្វថ្ងៃកូនមានគ្រួសារអស់ហើយមីង?

ភាពៈ	ចាស!មានអស់ហើយ ខ្ញុំយកជាមួយតានេះបានកូនស្រីមួយនោះ បានកូនពីរហើយ ។

សុវណ្ណៈ	ចឹងគ្រួសារមុនកូនពីរទៀត?

ភាពៈ	ចាស ។

សុវណ្ណៈ	ឥឡូវក្រោយពីទៀត?

ភាពៈ	ទេ ក្រោយនោះបានមួយ តែវាយកប្តីនោះវាបានកូនពីរទៀតហើយ ។

សុវណ្ណៈ	ចឹងចៅទេ?

ភាពៈ	ចៅពីរ ។

សុវណ្ណៈ	ចឹងសព្វថ្ងៃកូនបីទេ?

ភាពៈ	ចាស ។

សុវណ្ណៈ	ចឹងកូនឈប់រៀននៅត្រឹមថ្នាក់ណាដែរ?

ភាពៈ	មិយាយពីកូនបង១មិនបានរៀនអីខ្ទស់ទេ កាលជំនាន់នោះយើងរត់ទៅកន្លែងនេះទៅរៀនបន្តិចទៅ ទៅនោះរៀនបន្តិចទៅរៀនតាមក្រោមដើមឈើ គ្មានសាលាអីត្រឹមត្រូវបើយើងរត់ទៅកន្លែងណាមួយ១ យើងអត់មានកំណត់ថានៅមួយឆ្នាំឬពីរឆ្នាំទេ ជួនកាលនៅបានបីបួនប្រាំខែរត់ទៅទៀតទៅ ចឹងគ្រូចេះតែបង្ហាត់មួប់ឈើអីហ្នឹង ។

សុវណ្ណៈ	នៅលើភ្នំកាលហ្នឹងមឹង?

ភាពៈ	ចាស!នៅលើភ្នំ ចុះកូនខ្ញុំកើតនៅលើភ្នំធំនៅលើភ្នំទាំងអស់ហ្នឹង ។

សុវណ្ណៈ	យ៉ាងម៉េចបានជាយើងចេះតែរត់ចុះឡើងចឹង?

ភាពៈ	រត់ចុះឡើងដូចថាសភាពការណ៍យ៉ាងម៉េចទេ យើងនៅក្រោយយើងមិនដឹង មេប្រាប់ចេះតែទៅចឹងឯង គេថាយើងនៅមិនបានទេយួន ទាហានអីណាណីឡើងភ្នំ ដល់ពេលបុកពីក្រោយមកខ្លាំងគ្រាប់បាញ់ដូចគេចែសលាចចឹង ថានរណាបោះចោលកូនក៏បោះទៅនរណាមានកូនតូចដាក់រត់តែប៉ុណ្ណោះ រត់ចូលដីថៃ ថៃវាឲ្យតម្រៀបជួរគ្នាវាឃាត់មិនឲ្យចូលដីវាតែគ្រាប់ចែសពីក្រោយយើងទៅណា ចឹងអាខ្លះប្រានថៃដួល តែថៃវាអត់បាញ់ទេ គ្រាន់វាហាមកុំចូល១ តែបើខ្លាចហើយយើងចេះតែចូលបើថាបាញ់ងាប់១ទៅវាអត់មានបាញ់ទេដឹងថាសភាពការណ៍ការតឹងតែងពេក ក៏គាត់កុងត្រាជាមួយថៃ កុងត្រាថាដីប៉ុន្មានមួយគីឡូបួនជ្រុងឬពីរគីឡូបីគីឡូឬ១០គីឡូអី គាត់ចុះកុងត្រាឲ្យថៃអនុញ្ញាតិឲ្យគ្រួសារទ័ពនៅ នៅដីថៃនៅរយៈប៉ុន្មានថាពីរឆ្នាំឬមួយឆ្នាំអីក៏ នៅបានមួយឆ្នាំអីជួនកាលអស់អណត្តិដែលយើងកិច្ចសន្យាជាមួយគេ គេដកទៅទៀតហើយ និយាយទៅនៅតាមខ្នងភ្នំនេះ នៅរហូតហ្នឹងទៅត្រង់នេះទៅត្រង់នោះ អត់ចាំកន្លែងទេ ពកូនទៅគ្រាក់១ហ្នឹងគ្មានស្អីទេ មានតែវ៉ាឡូមួយប៉ុណ្ណឹង ចាននោះពីរ អង្រឹងមួយកៅស៊ូមួយសន្ទឹកប៉ុណ្ណោះឯង ។

សុវណ្ណៈ	វ៉ាឡូហ្នឹងស្អីគេមឹង?

ភាពៈ	វ៉ាឡូដាក់ខោអាវ ។

សុវណ្ណៈ　　កាបូប?

ភាពៈ　　វ៉ាឡូចិននោះ ពណ៌ខៀវៗណាស់ ។

សុវណ្ណៈ　　សាក់កាដូ?

ភាពៈ　　សាក់កាដូ ពួកខ្ញុំច្រើនប្រើពាក្យហៅវ៉ាឡូ ។

សុវណ្ណៈ　　វ៉ាឡូហ្នឹងពាក់អីគេមីង?

ភាពៈ　　ដឹងពាក្យស្អីបើគេហៅវ៉ាឡូហៅតាមគ្នាចឹងទៅវ៉ាឡូៗប៉ុណ្ណោះឯង ។

សុវណ្ណៈ　　ចឹងមីងម៉េចដឹងថា ចិនបើកឲ្យ?

ភាពៈ　　ចុះរដ្ឋគេចែកមកគេថាជំនួយពីចិនមក អាហ្នឹងពណ៌ខៀវៗដូចពណ៌ស្លឹកឈើចឹង ។

សុវណ្ណៈ　　ឆ្នាំណាគេបើកឲ្យ?

ភាពៈ　　និយាយមួយមាត់ទៅតាំងពីពួកខ្ញុំឡើងភ្នំ ឡើងភ្នំយេះមួយឆ្នាំមកឃើញរបស់ហ្នឹងរហូត ។

សុវណ្ណៈ　　មីងឡើងភ្នំតាំងពីឆ្នាំណា?

ភាពៈ　　ឆ្នាំ៨០ ហើយឃើញរបស់នោះមានអង្រឹង មានសាក់កាដូ មានស្បែកជើង មានកៅស៊ូ មានកាដឹង បើសម្លៀកបំពាក់ចឹងៗជំនួយមកពីថៃ តាម៉ុក គាត់ទិញពីថៃចែកឲ្យទេ ដូចជាសារ៉ុងកាណាត់ខោអាវអីហ្នឹងគាត់ទិញមក ពួកគេដឹកមកទម្លាក់គ្រឹបៗទៅ ដូចថាប្រធានអង្គភាពចែកឲ្យតាមគ្រួសារតិចច្រើនអី គេផ្តល់ឲ្យជាឆ្នាំងជាចានអី គេដឹកមកឲ្យតែរបស់សំខាន់ជំនួយពីចិនមកគឺរបស់យោធារបស់ទ័ព ចឹងជំនួយពីចិនមក មិនដឹងខាងណាគេជួយតែឮថាពីចិនមក ថាតាមគេទៅ ប្រជាជនដូចពួកខ្ញុំបើគេនាំរត់ក៏រត់ទៅ ទៅខាងណាខាងណីទេ ។

សុវណ្ណៈ　　ចឹងពេលរត់ម្តងៗមានទាហានខាងរដ្ឋាភិបាលវាយឬយ៉ាងម៉េច?

ភាពៈ　　ចាស!ទាហានខាងរដ្ឋាភិបាលវាយ វាយឡើងដុតឃ្លាំងនៅត្រង់នេះ ដុតឃ្លាំងម៉ាស៊ីនរាប់រយគ្រឿងដុតឆេះអស់ ហើយនិយាយពីបាញ់ បាញ់រត់រួចៗរត់មិនរួចក៏បាញ់ងាប់ទៅណាស់ មានអ្នកនៅជិតខ្ញុំមួយ នៅត្រង់នោះដល់បាញ់ទៅគេចាប់បាន ចុះពីភ្នំមកប្តីរត់រួចប្រពន្ធរត់មិនរួចដល់ចឹងចាប់ប្រពន្ធបានទៅ ។

សុវណ្ណៈ　　មីងមិញឮនិយាយពីតាម៉ុក ហើយមីងមានស្គាល់តាម៉ុកច្បាស់ទេ?

ភាពៈ　　ចាស!ខ្ញុំស្គាល់តើ ។

សុវណ្ណៈ　　មីងកាលហ្នឹងរស់នៅក្រោមការគ្រប់គ្រងរបស់គាត់?

ភាពៈ　　ចាស ។

សុវណ្ណៈ　　តាម៉ុក គាត់ជាមនុស្សយ៉ាងម៉េចដែរ មនុស្សគាត់កាច មិនសូវកាច?

ភាពៈ តាម៉ុក តាមខ្ញុំនៅជាមួយណា តែអ្នកផ្សេងៗថា គាត់នៅជុំយើងចេះ គាត់មកជួបប្រជាជនអីៗ គាត់សម្ដីអាក្រក់តែគាត់ចិត្តល្អ ឧទាហរណ៍ថា ដូចពួកខ្ញុំចេះខ្វះនេះខ្វះនោះអី គាត់ទៅឃ្លាំងអីកន្លែងគេទុកសម្ភារៈអីគ្រប់បែបគ្រប់យ៉ាងអី ជួនកាលទៅជួបគាត់ដែរ គាត់សួរថាពួកមីដែងទៅណា តាខ្ញុំមករកបីចេងរកស្ករកប្រហុកហូប ដល់ចឹងគាត់ជេរហើយ ជេរតែឲ្យ ប្រពន្ធអាណានៅអង្គភាពណា ប្ដីងែងឈ្មោះអី ជួនកាលជេរហើយនាំគ្នាឈរ បន្តិចចូលមកនាំគ្នាយក គាត់ជេរតែគាត់ឲ្យហូប ជេរប៉ុណ្ណាឲ្យប៉ុណ្ណឹង តែដឹងចិត្តរាប់រយរាប់ពាន់ទៅជេរគ្មានពីណាយកចិត្តទុកដាក់ខឹង ដល់ជេរខ្លាំងកាន់តែចូលខ្លាំង គាត់កាចតែជេរទៅហៅមកដូចជាឪពុកម្ដាយ ចឹងយើងទាំងអស់គ្នាទោះបីយ៉ាងណា ក្រោមការគ្រប់គ្រងរបស់គាត់ហើយគាត់ជេរក៏គ្មានយកចិត្តទុកដាក់អីខឹង ជេរគាត់ឲ្យសុំអីឲ្យនោះ មានលុយទាញពីហៅប៉ោឲ្យព្រះ ៥នាក់ចែកទៅម្នាក់៥០០ចេញផុតពីមុខអញ ចឹងតានោះ ចឹងគាត់ជាកាចអត់ជាស្លូតអីណាទេ ម្យ៉ាងគាត់មេទ័ពផង ចែកអីឲ្យទ័ពប៉ុន្មានៗបើសល់គាត់ឲ្យចែកគ្នាទៅហើយចំណែកកូនចៅគាត់ក្រុមគ្រួសារគាត់ មិនមានដូចថាគាត់រដ្ឋមន្ត្រីមានប៉ុណ្ណឹងហើយឲ្យកូនគាត់លើសគេទេ កូនចៅរស់នៅធម្មតាដូចពួកខ្ញុំចឹង គិតថាប្រពន្ធគាត់លេងខ្សែកខ្សែដៃសំពត់ហូរអាវប៉ាក់អី ស្បែកជើងកែវចោទអី អត់បានទេ ធ្វើដូចគេមើលគេ កុំរបៀបប្ដីរដ្ឋមន្ត្រីហើយប្រពន្ធរបៀបស្ដេចមិនបានទេ ហ្នឹងចរិកគាត់ ដែលខ្ញុំរស់នៅជាមួយគាត់ គាត់មិនជាកាចមិនជាស្លូតអីណាស់ណាទេ ។

សុវណ្ណៈ ចឹងខ្លួនមីងផ្ទាល់មីងចូលចិត្តគាត់ទេ?

ភាពៈ ខ្ញុំថាចូលចិត្តដូចថាមិនចូលចិត្ត យើងរស់នៅក្នុងការបង្អៀតបង្អុល ព្រោះសភាពការណ៍វាមិនអំណោយទាន ឲ្យយើងនៅកន្លែងណាឲ្យវាប្រាកប្រជា ចង់ទៅនៅស្រុកភូមិវិញដែលតែទៅយ៉ាងម៉េចបាន ចង់វិញទៅរកស្រុកកំណើតវិញទៅមិនរួច ។

សុវណ្ណៈ យ៉ាងម៉េចចឹង?

ភាពៈ មកយ៉ាងម៉េចរួច បើមកប៉ះទាហាន វ៉ៗបាញ់ផាប់អស់ទាំងសំបុក ។

សុវណ្ណៈ ប៉ះទាហានខាងណា?

ភាពៈ ទាហានរដ្ឋាភិបាល មកបាញ់ផាប់ទាំងសំបុក ដល់ចឹងអត់ហ៊ានមកទេ ចឹងហើយចង់ក្រែងជាសម្ព័ន្ធភាពប្រិយមិត្តជាមិត្តភក្តិអីនោះ ថៃអីនោះ ក្លើម្រះអីទៅថៃនោះ ចង់ចូលលេងផ្សារថៃ ចង់និញអ្វីៗរបស់ល្អៗឆ្ងាញ់ៗប្ដូចង់បាន ចង់ទៅលេងឲ្យស្គាល់ស្រុកគេក៏ទៅតាមមិត្តភក្តិទៅ គេនាំទៅផ្សារទៅបុណ្យអីខ្លះទៅ រហូតដល់ទីក្រុងថេបទៅជាមួយឆប៉ែគេ ឆប៉ ខ្មែរដឹងគេហៅស្អីបើថៃ ហៅ«ឆប៉» ។

សុវណ្ណៈ ឆប៉ី ហ្នឹងស្អីគេមីង?

ភាពៈ ឆប៉ី ដឹងគេហៅស្អី បើខ្មែរដឹងគេហៅស្អី ស្គាល់ពាក្យ“ឆប៉ី” ។

សុវណ្ណៈ ឆប៉ី ហ្នឹងពាក្យខ្មែរឬពាក្យថៃ?

ភាពៈ ពាក្យថៃ ខ្មែរបែបគេហៅទូតប្រចាំ បែបទូតដឹងយ៉ាង ខ្ញុំហៅតែ“ឆប៉ី” ។

សុវណ្ណៈ ចឹងខ្ញុំចង់និយាយបកទៅក្រោយបន្តិចយើងនិយាយដល់កន្លែងលើភ្នំវាំងលឿនបន្តិចហើយ ចឹងខ្ញុំសុំបកទៅពីជីវិតមីងនៅក្មេងៗបន្តិច មីងទាន់ជំនាន់របស់សម្តេចទេ?

ភាពៈ ខ្ញុំទាន់មើលរដ្ឋប្រហារខ្ញុំអាយុ១២ ក្នុយគិតមើល ។

សុវណ្ណៈ កាលហ្នឹងមីងឈប់រៀនត្រឹមថ្នាក់ទីប៉ុន្មាន?

ភាពៈ រៀនបានតិច ។

សុវណ្ណៈ រៀនបានថ្នាក់ទីប៉ុន្មាន?

ភាពៈ ពីដើមគេរៀនថ្នាក់ទី១២ចុះណោ ចឹងមីងរៀនបានត្រឹមថ្នាក់ទី១០ចាស់ ។

សុវណ្ណៈ ចឹងពេលបច្ចុប្បន្នត្រឹមថ្នាក់ទី៣ដែរ?

ភាពៈ ចាស!ទី៣ដែរ តែថាថ្នាក់ទី១០ពីដើម យើងរៀន“អា បេ សេ ដេ អឺ” ណាស់យើងរៀនមិនទាន់នេះទេ យើងរៀនបំបែកបានខ្លះដែរ រៀនមិនទាន់គ្រប់ពេញមួយឆ្នាំទេ ក៏រដ្ឋប្រហារព្រឹបក៏ផ្អាកតាំងពីនោះមកក៏ចេះតែរសាប់រសេទៅមើលឆ្នាំ៧០មីងអាយុ១២ ក្មេងឥឡូវមិនដឹងជាដឹងក្តីអីណាស់ណាទេ មានការចងចាំខ្លះភ្លេចខ្លះ ។

សុវណ្ណៈ ចឹងមានមូលហេតុអីឈប់រៀនកាលហ្នឹង ឈប់រៀនទី១០ត្រូវទេមីងកាលហ្នឹង?

ភាពៈ ចាស ។

សុវណ្ណៈ មូលហេតុអីឈប់រៀន?

ភាពៈ ចុះរដ្ឋប្រហារ សាលាបិទអស់ ហើយគ្រូទៅស្រុកទៅទេសអីអស់ អត់មានបង្ហាត់អីអស់ អត់មានសាលាទេ ចឹងស្រុកទេសចេះតែជ្រួលច្របល់ ហើយចាស់ៗគាត់ចេះតែថាស្រុកយើងកើតសង្គ្រាមហើយ ។

សុវណ្ណៈ ចឹងកាលមីងនៅស្រុកគូលេនស្រុកកំណើតកើតជានៅហ្នឹងតែម្តង?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងអត់មានដូរទៅណាទៅណីទេ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងដល់ពេលមានរដ្ឋប្រហារឆ្នាំ៧០ហ្នឹង មីងមានដឹងថាហេតុអីមានរដ្ឋប្រហារពេលហ្នឹង?

ភាពៈ ខ្ញុំឮពុកម៉ែខ្ញុំប្រាប់ ។

សុវណ្ណៈ	គាត់ប្រាប់ថាយ៉ាងម៉េច?

ភាពៈ	ប្រាប់ថា សម្តេចសីហនុគេទម្លាក់ហើយ លោកអស់ដំណែងហើយ អត់មានស្នងរាជ្យអីទៀតទេ យើងមានលុយកាក់អីឆាប់ដូរឲ្យទាន់ បើដូរមិនទាន់ទេ លុយគេចោលហើយ ម៉ែខ្ញុំគាត់មានគោក្របីច្រើន បងប្អូនខាងឪពុកខ្ញុំគាត់ធ្វើមាសខាងភ្នំអន្លង់ ដល់ចឹងគាត់ទៅធ្វើមាសហ្នឹងគេទៅក៏មាន មានលុយមានកាក់ទៅដល់ពេលរដ្ឋប្រហារគាត់ចេះតែទុកៗក្នុយ អើយលុយគ្មានបានប្រើអីមួយរយទេ ចោលទាំងអស់ហ្នឹង ដូរក៏មិនបានអីក៏មិនបានហើយ ចាស់ៗពីដើមគាត់ច្រើនដាក់លុយតាមបំពង់ឫស្សីតាមអី ចឹងក៏ចោលអស់ ខ្ញុំ៧៣-៧៤ ហ្នឹងលុយចោលអារដ្ឋអាភាយ លុយរូបក្អម លុយរូបគោ ខ្ញុំចោលទាំងអស់គ្មានទិញស្អីបានហើយឡើងភ្នំខ្ញុំយកបានប្រហែលជា១៨សន្លឹក រូបគេមានគេចង់មើលក៏ចោលបាត់អស់ទៅ លុយរូបគោពីរសន្លឹកមិនដឹងទៅត្រង់ណា គ្មានបានប្រើប្រាស់អីទេ។

សុវណ្ណៈ	មីងមានបងប្អូនប៉ុន្មាននាក់?

ភាពៈ	ខ្ញុំមានបងប្អូន៦នាក់ គាត់ស្លាប់មួយហើយនៅតែ៥ទេ។

សុវណ្ណៈ	ប្រុសប៉ុន្មានស្រីប៉ុន្មានមីង?

ភាពៈ	ចាស!ប្រុសបួនស្រីពីរ។

សុវណ្ណៈ	មីងជាកូនអីប៉ុន្មាន?

ភាពៈ	ខ្ញុំកូនទីពីរ។

សុវណ្ណៈ	ចឹងបងគេ បងប្រុស?

ភាពៈ	បងប្រុសគាត់ស្លាប់បាត់ហើយ ស្លាប់ពីឆ្នាំមុន។

សុវណ្ណៈ	ស្លាប់ម្នាក់មីង?

ភាពៈ	ចាស!ស្លាប់ម្នាក់នៅ៥ទេ ស្លាប់បងទី១។

សុវណ្ណៈ	ស្លាប់បងទី១គាត់ស្លាប់ដោយសារអីគេ?

ភាពៈ	ទេ គាត់នៅគូលេននោះគាត់ឈឺ គាត់ឈឺយ៉ាងម៉េចខ្ញុំមិនដឹងដែរ ស្លាប់ហើយបានបងប្អូនគេមកថាបងស្លាប់ ទៅមើលគាត់ថា អត់មានឈឺអី ដេកៗស្រាប់តែផុតដង្ហើមទៅស្លាប់ទៅ។

សុវណ្ណៈ	ចឹងទើបស្លាប់ឥឡូវៗទេ?

ភាពៈ	ចាស!ស្លាប់បានប្រហែលជាងមួយឆ្នាំហើយ។

សុវណ្ណៈ	ចឹងទើបឥឡូវមិនមែនពីមុនមកទេ?

ភាពៈ	ចាស!គាត់ស្លាប់និងឈឺរោគគាត់ទេ អត់មានពីណាធ្វើអីគាត់ទេ។

សុវណ្ណៈ	ជីវភាពគ្រួសារមីងកាលជំនាន់ហ្នឹងយ៉ាងម៉េចដែលមីង?

ភាពៈ ដូចគ្នាទូទៅ ។

សុវណ្ណៈ ធូរធារឬមួយមិនធូរធារទេ?

ភាពៈ មិនមានអ្នកណាមានអ្នកណាក្រទេ ស្មើៗគ្នា ។

សុវណ្ណៈ ចង់និយាយថា យើងរកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹកអីចឹងឬមួយល្មមៗ ?

ភាពៈ ទេ បើនៅលើភ្នំជាមួយរដ្ឋអី ដូចគ្នាទាំងអស់ ។

សុវណ្ណៈ ខ្ញុំចង់និយាយថា គ្រួសារមីងនៅជាមួយឪពុកម្ដាយ កាលក្មេងៗ ?

ភាពៈ នៅជាមួយឪពុកម្ដាយកណ្ដាល ។

សុវណ្ណៈ ហូបចុកគ្រប់គ្រាន់ឬខ្វះខាតអីមានទេ?

ភាពៈ ចាស!អត់ទេ គាត់កណ្ដាល ។

សុវណ្ណៈ ឪពុកម្ដាយមីងធ្វើអីគេ?

ភាពៈ ឪពុកខ្ញុំធ្វើក្នុងឃុំដែរ បងជីដូនមួយគាត់នោះធ្វើមេឃុំ ហើយបន្ទាប់មកឪពុកខ្ញុំដល់ចឹងជីវភាពគាត់ គាត់ថាមិនមានដោយសារមេឃុំទេ គឺខាងម៉ែខ្ញុំយាយតាខ្ញុំគាត់អ្នកធូរធារ គោអំពែ កេរ្តិ៍អាករខាងយាយខាងតាខ្ញុំមានច្រើនណាស់ រាប់រយក្បាលដល់ចឹងកូនគាត់មានតែមួយ អត់ពីយាយទៅអ៊ីៗធ្លាក់លើម៉ែខ្ញុំទាំងអស់ ចឹងខ្ញុំធំដឹងក្ដីមកមិនសូវយ៉ាប់ទេណាស់ ។

សុវណ្ណៈ ឪពុកមីងស្លាប់នៅពេលណាដែរ?

ភាពៈ ឪពុកខ្ញុំស្លាប់នៅឆ្នាំ១៩៧៣ ។

សុវណ្ណៈ ស្លាប់ដោយសារអីគេ?

ភាពៈ ដោយសារឈឺ ម៉ែខ្ញុំក៏ឆ្នាំ៧៣ ១៥ថ្ងៃម្នាក់ ។

សុវណ្ណៈ ឈឺអីគេមីង?

ភាពៈ ឈឺចេះតែរាគទៅៗគាត់អស់កម្លាំងទៅដាច់ខ្យល់តែម្ដងទៅ ។

សុវណ្ណៈ ជំងឺរាគមិនដឹងជាគាត់អីខុសឬមួយយ៉ាងម៉េច?

ភាពៈ មិនដឹងជាគាត់ហូបអីខុស ចាស់ៗគាត់តែងនិយាយថា ឪពុកនាងឯងខុសគ្រូខុសអ្នកតាអីចាស់ៗចេះតែនិយាយណាស់ ហើយពួកខ្ញុំនៅក្មេងដែរ ខ្ញុំគ្មានបាននៅទេ ឆ្នាំ៧១ខ្ញុំចេញពីផ្ទះបាត់ហើយ ។

សុវណ្ណៈ មីងចេញពីផ្ទះទៅខាងណាវិញ?

ភាពៈ ខ្ញុំចេញពីផ្ទះទៅនៅអង្គភាពគេ ។

សុវណ្ណៈ មីងចូលបដិវត្ត?

ភាពៈ ចាស!ខ្ញុំចូលបដិវត្តហ្នឹង ដល់ឪពុកខ្ញុំឈឺខ្លាំងបានសំបុត្រគេប្រាប់ទៅខ្ញុំមក ខ្ញុំមកឪពុកស្លាប់ ហើយខ្ញុំទៅកន្លែងខ្ញុំវិញ ។

សុវណ្ណៈ ចឹងមីងចូលបដិវត្តឆ្នាំ៧១?

ភាពៈ ចូល៧១ ។

សុវណ្ណៈ ដើម៧១ ចុង៧១ ពាក់កណ្តាល៧១?

ភាពៈ ចុង៧១ ។

សុវណ្ណៈ ចឹងមានមូលហេតុអីបានជាមីងចូលបដិវត្ត?

ភាពៈ ក្មួយអើយ ចូលនេះចូលដូចយើងថា ចូលទាំងងងឹតងងុល គេបំពាក់បំប៉នថាឲ្យរៀនឲ្យសូត្រ ដើម្បីឲ្យចេះដឹង ពីរឿងប្រទេសជាតិ ដូចថាកសាងខ្លួន សីលធម៌អីណា១២ប្រការឲ្យទៅជា យុវនារីខ្លាហានអីនោះ ដូចថាចង់រៀនចង់សូត្រចង់ចេះម្យ៉ាងចង់ដើរឲ្យស្គាល់ស្រុកគេ ចេះ តែទៅរៀន ទៅបានរៀនមែន រៀនពីការលត់ដំខ្លួន ការនិយាយស្តីអី ឲ្យដឹងទាបដឹងខ្ពស់ ឲ្យរៀនពីការបាញ់កាំភ្លើងអីណាស់ រៀនបាញ់និងគេបាន៦ខែ បានចេះបាញ់ រៀនចេះ ហើយគេបំពាក់ឲ្យកាន់កាំភ្លើង គេឲ្យកាន់អត់មានឲ្យទៅណាទេ គេឲ្យនៅការពារក្នុងមន្ទីរគេ អង្គភាពគេណា យប់ឡើងយើងយាមទៅ ថ្ងៃឡើងយើងធ្វើអីផ្សេង កាំភ្លើងទុកនៅផ្ទះទៅ ពេលយប់ឡើងយើងយាមទៅ ទៅណាមកណីក៏កាន់រាងៗខ្លួនទៅណា ។

សុវណ្ណៈ ចឹងសីលធម៌១២ប្រការមានស្អីខ្លះទៅមីង?

ភាពៈ សីលធម៌១២ប្រការ ភ្លេចអស់ហើយ ។

សុវណ្ណៈ មីងមានចាំខ្លះទេ?

ភាពៈ ចាំខ្លះ ។

សុវណ្ណៈ ទី១ស្អី?

ភាពៈ ទី១ ដើរហើរដេកពួនអីណា ប្រុសឈ្មោលអី ទី១ការនិយាយស្តីអី កន្លែងណាឲ្យចេះ និយាយរបៀបរាបសារជាមួយប្រជាជន ទី២ទៅទីណាកន្លែងណាក៏ដោយយើងឃើញរបស់ របរប្រជាជនជ្រុះឬផ្លែឈើតាមចម្ការជាឆ្នាំងចាន មាសប្រាក់លុយកាក់អី យើងកុំប៉ះពាល់ ឲ្យសោះ គេហាមឃាត់ ទី៣ទៀត គឺដូចថាប្រុសឈ្មោលអីណា ដូចជាសែបគុបមិត្តភក្តិមិន ល្អ មានប្រុសមានឈ្មោល មានសាហាយមានស្នេហា លាក់បំពួនពីមិត្តភក្តិ មេកងយើង ធ្លាប់រស់នៅអីកុំឲ្យឆ្អេកឆ្អាច កុំឲ្យនិយាយលេងសើចអីច្រើន ហើយកុំមានសំបុត្រទាក់ទងអី ទាំងពីបញ្ហាកាន់អាវុធកាន់អី កាន់អាវុធមានច្រើនណាស់ ។

សុវណ្ណៈ ចឹងទី៤មីង?

ភាពៈ ចាស!ទី៤យើងកាន់អាវុធ ពេលយើងដើរដំណើរទៅផ្ទះប្រជាជន យើងត្រូវរៀបសារកុំឲ្យយើងមានអាវុធកាន់នៅដៃហើយកុំឲ្យធ្វើប្រផែងប្រផាំង ធ្វើឯងណាអ្នកតូចអ្នកធំអីឲ្យប្រជាជនខ្លាចក្រែងណាស់ ត្រូវរាបសារ ទី៥ទៀតទៅកន្លែងណា ឃើញប្រជាជនធ្វើការងារអីដូចជាស្ទូងដកប្តូធ្វើអ្វីផ្សេងទៀត កុំទំកើងរពុកថាខ្លួនយើងចេះ យើងត្រូវដាក់ខ្លួនឲ្យដូចជាប្រជាជន ត្រូវជួយគឺជួយ ត្រូវជួយត្រូសកាប់ជួយធ្វើអីក៏ដោយ បើប្រជាជនធ្វើអីមិនកើតគឺយើងត្រូវធ្វើឲ្យកើតដឹងមុខប្រជាជន កុំខ្ពើមកុំរើសអ្នកក្រអ្នកមាន ។

សុវណ្ណៈ ចឹងទី៦ ?

ភាពៈ ទី៦ ទៅទីណាដូចថាប្រជាជនមិនមានអនាម័យផ្ទះណា ទៅឃើញប្រជាជនផ្ទះមិនស្អាតយើងបោសដាំទឹកក្តៅ យើងដុសចានឆ្នាំងជូនប្រជាជនឲ្យប្រជាជនមើល ពេលបត់ជើងតូចធំអីត្រូវបង្រៀនប្រជាជន អត់បន្ទន់ត្រូវចេះជីកអន្លង់ប្រើដេះប្រើអីចាក់លុបដីដាន់ឲ្យណែនអី ។

សុវណ្ណៈ ចឹងទី៧ ?

ភាពៈ ទី៧ ភ្លេចអស់បាត់ហើយ ច្រើនពេក ។

សុវណ្ណៈ បានច្រើនតើមឹង?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងកាលចូលពីណាណែនាំឲ្យចូលមឹង មិត្តភក្តិនៅក្នុងភូមិ?

ភាពៈ កាលមុនមិត្តភក្តិ មិត្តភក្តិថា ទៅធ្វើយោធា ខ្ញុំថាយោធាស្អីទេ ដល់មិត្តភក្តិខ្ញុំថា យើងចង់ឃើញគេកាន់កាំភ្លើងណាស់ ខ្ញុំថាខ្លាចណាស់ វាថាទៅសាកមើលបើគេឲ្យយើងរៀនបាញ់និងគេ ដល់ពេលមិត្តភក្តិបបួលទៅ ដល់ចឹងទៅមែនដល់ជួបការលំបាកនឹកផ្ទះ ចង់មកផ្ទះពេលយើងកំពង់ដេកលក់ម៉ោង១ម៉ោង២អីគេដាស់យាមណាស់ ។

សុវណ្ណៈ មិត្តភក្តិហ្នឹងឈ្មោះអីគេ?

ភាពៈ ចាស!មិត្តភក្តិខ្ញុំច្រើនណាស់ ។

សុវណ្ណៈ មានអ្នកនាំសំខាន់ទេ អ្នកនាំសំខាន់ហ្នឹងឈ្មោះអីគេ?

ភាពៈ អ្នកនាំសំខាន់ស្លាប់បាត់ហើយ ។

សុវណ្ណៈ តែឈ្មោះអីគេ?

ភាពៈ ឈ្មោះ វី ។

សុវណ្ណៈ គាត់ត្រូវជាស្អីគេ?

ភាពៈ គាត់មិត្តភក្តិដូចថាធ្លាប់ទៅណាទៅណីទៅជាមួយគ្នាទៅ គេក៏ចូលខ្ញុំក៏ចូលទាំងអស់គ្នា ។

សុវណ្ណៈ មិត្តភក្តិស្រីឬមួយប្រុសមឹង?

ភាពៈ ស្រី ខ្ញុំមិនដែលមានមិត្តភក្តិប្រុសទេ ចំណាស់ប៉ុននេះហើយ ។

សុវណ្ណៈ ឈ្មោះ វី ហ្នឹងគាត់អាយុប្រហែលជាប៉ុន្មាន?

ភាពៈ មួយស្រករគ្នាហ្នឹងឯង ។

សុវណ្ណៈ កាលហ្នឹងអាយុប្រហែល១៣?

ភាពៈ ចាស!កាលនោះមួយសារគ្នាហ្នឹងឯង ។

សុវណ្ណៈ ឆ្នាំ៧០ អាយុ១២ឆ្នាំដល់៧១អាយុ១៣ហើយ?

ភាពៈ ចាស ។

សុវណ្ណៈ មិត្តភក្តិស្រករគ្នាទេ?

ភាពៈ ចាស!មួយស្រករគ្នាឯងហ្នឹងណា ឥឡូវគេស្លាប់បាត់ហើយ ។

សុវណ្ណៈ ស្លាប់ដោយសារអីគេ?

ភាពៈ ដឹងស្លាប់រឿងអីទេ ខ្ញុំសួរដំណឹងតាមគេថាស្លាប់បាត់ហើយ ។

សុវណ្ណៈ ស្លាប់ឥឡូវឬស្លាប់តាំងពីមុន?

ភាពៈ គេថាស្លាប់ជំនាន់ប្រហែលជាពីរបីឆ្នាំមុននេះណា ចុះបែកគ្នាតាំងពីយើងនៅលីវរាងខ្លួននោះ រហូតគេនៅស្រុកនៅភូមិម៉ែឪគេ ខ្ញុំក៏ឡើងភ្នំបានកូនបានចៅទៅភ្លេចគ្នាស្រាប់តែឮដំណឹងថាស្លាប់បាត់ ។

សុវណ្ណៈ ចឹងក្មេងៗនៅក្នុងភូមិមីងចូលបដិវត្តមានគ្នាប៉ុន្មាននាក់ មានចាំទេ កាលហ្នឹង?

ភាពៈ នៅក្នុងភូមិខ្ញុំអត់មានពីណាគេចូលទេ ខ្ញុំចេញពីផ្ទះទៅគេថាខ្ញុំចេះថាខ្ញុំចុះ ពុកខ្ញុំកាលនោះគាត់នៅរស់គាត់ថា កូនអញអាប្រុសវាមិនដាច់ខាតទេ កូនអញមីស្រីដាច់ខាត ឥឡូវឲ្យវាទៅមើល វាទៅប៉ុណ្ណាវានឹកផ្ទះវាវិលវិញ តាមដំណើរទៅធំប៉ុននេះហើយមិនចេះហាមចេះឃាត់ ព្រោះមិនមានធ្មើតែយើងណា គេគ្រប់គ្នាកូនស្រីគេលះបង់ឲ្យទៅ គេមានយកទៅសម្លាប់អីណា គ្រាន់តែទៅរៀនចេះដឹង រឿងច្បាប់ទម្លាប់របស់គេ ពីដើមគេប្រើពាក្យថាអង្គការណា អង្គការខ្ញុំទៅក៏ស្រេចតែអង្គការទៅ ទោះបីទៅមានប្ដីមានសី ទុកដាក់ការប្ដីប្រពន្ធស្រេចតែអង្គការ ឪពុកម្ដាយគ្មានសិទ្ធអីទេ ស្រេចលើអង្គការទាំងអស់ ។

សុវណ្ណៈ ចឹងជិតខាងគេថាយើងយ៉ាងម៉េចពេលយើងចូលបដិវត្ត?

ភាពៈ គេថាខ្ញុំចង់បានកាំភ្លើង គេថាខ្ញុំមនុស្សស្រីអីចេះដើរចោលផ្ទះ ចេះទៅឆ្ងាយពីផ្ទះ ខ្ញុំថាស្រីសព្វថ្ងៃមិននេះណា ចុះស្រីពីមុនស្រីជំនាន់ពួកគាត់ នៅបន្ទិលចង្ក្រានមិនដុំទេ ទោះបីខ្ញុំមិនចេះក៏ខ្ញុំទៅមើលគេមើលឯងដែរ ខ្ញុំរៀនសូត្រពីបងៗ ពីដើមគេហៅបងៗគណៈតំបន់គ្រាន់តែក្រលេកឃើញខ្ញុំនិយាយពីទទួលអាល័យខ្ញុំណាស់ ប្រធានតំបន់ ។

សុវណ្ណៈ	គាត់ឈ្មោះអីគេមីង?

ភាពៈ	ប្រធានតំបន់គាត់ឈ្មោះ បងសុន ។

សុវណ្ណៈ	ប្រធានតំបន់ប៉ុន្មានមីង?

ភាពៈ	តំបន់១០៣ ឈ្មោះ សុន រាល់ថ្ងៃគាត់នៅកោះកុង ។

សុវណ្ណៈ	ចឹងឥឡូវនៅរស់ទេ?

ភាពៈ	ចាស! នៅរស់តើ ។

សុវណ្ណៈ	ឈ្មោះ សុន?

ភាពៈ	ចាស ។

សុវណ្ណៈ	ប្រុសឬមួយស្រី?

ភាពៈ	ស្រី គាត់ប្រធានតំបន់១០៣តែម្តង ។

សុវណ្ណៈ	ប្រធានតំបន់១០៣កាលហ្នឹងនៅក្នុងខេត្តណា ស្រុកណាមីង?

ភាពៈ	និយាយមួយមាត់មកមានច្រើនស្រុក មើលស្រុករវៀង ២ស្រុកគូលេន ៣ស្រុកទំពរ ៤ស្រុកជ័យសែន ។

សុវណ្ណៈ	ឥឡូវស្រុកទំពរគេដូរហើយនៅ?

ភាពៈ	ដឹងគេដាក់អីវិញ ។

សុវណ្ណៈ	ទៅត្បែងមានជ័យទេដឹង?

ភាពៈ	ទេ ស្រុកត្បែងមានជ័យ នៅត្បែងមានជ័យ ស្រុកត្បែងមានជ័យពីដើមមកស្រុកត្បែងមានជ័យដូចគ្នាហ្នឹង មួយត្បែងមានជ័យ មួយត្បែងពីរ ។

សុវណ្ណៈ	ចឹងបងសុនគាត់ប្រធានតំបន់?

ភាពៈ	តំនប់១០៣ ។

សុវណ្ណៈ	ប្រធានតំបន់១០៣ហ្នឹង តាំងពីឆ្នាំណាដល់ឆ្នាំណា?

ភាពៈ	តាំងពីខ្ញុំចេញពីផ្ទះទៅខ្ញុំឃើញគាត់រហូតដល់បែកគ្នាឆ្នាំ៧៩ ។

សុវណ្ណៈ	ចឹងគេអត់មានដូរដោះទេ?

ភាពៈ	អត់មានដូរដោះទេ ប្រជាជនគាំទ្រគាត់ណាស់ គាត់ល្អ ។

សុវណ្ណៈ	តែមីងមានដឹងថា គាត់ចូលមកកាន់កាប់នៅតំបន់១០៣ហ្នឹងតាំងពីឆ្នាំណាមក?

ភាពៈ	អត់មានដឹងគាត់តាំងពីឆ្នាំណាទេ ស្រាប់ពួកខ្ញុំចេញទៅពីផ្ទះស្រាប់តែឃើញគាត់តែម្តងហើយ គេធំជាងយើងណាហ៊ានស្រាវជ្រាវប្រវត្តិគាត់ ។

សុវណ្ណៈ	គាត់អាយុប្រហែលជាប៉ុន្មាន កាលហ្នឹងមីង?

ភាពៈ	អេ!ឥឡូវគាត់ចំណាស់ដែលហើយ  កាលនោះអាយុខ្ទង់៤២ហើយយ៉ាងមើលទៅខ្ញុំទៅជួបគាត់ គាត់ចាស់ហើយតែគាត់នៅស្អាត គាត់អ្នកធ្វើការចេះ ។

សុវណ្ណៈ	ដល់ពេលសព្វថ្ងៃរស់នៅកោះកុង?

ភាពៈ	ចាស!គាត់នៅកោះកុង ។

សុវណ្ណៈ	យ៉ាងម៉េចបានមីងដឹងថា គាត់នៅកោះកុង?

ភាពៈ	ចាស!ពីឆ្នាំទៅអ្នកដែលទៅខាងខ្ញុំគេមកលេង គេមកលេងកូនគេ មកលេងទៅគេស្រាវជ្រាវរកខ្ញុំថា ភាព នៅណាចេះ មកដល់គេចុះម៉ូតូចេះ ក្រលេកឃើញគេដូចលោកស្រីចឹង យី!រំបល់យ៍អញស្មានថា ជិទាវមកពីណា អី!ឯងចាស់ភ្លាឈឺ បងឲ្យទៅលេង ខ្ញុំថាបងនៅណា បងនៅកោះកុងនោះ រាល់ថ្ងៃគាត់មកប៉ៃលិនទៅមកៗចេះ ខ្ញុំថាបងចាស់អីទេ គាត់ថាបងចាស់ជាងមុនបន្តិចណា ទៅលេងទៅរើយគ្នាក៏នៅនោះដែរ នៅផ្សារ ផល ប្រពន្ធពូអុលហ្នឹងគេនៅផ្សារ គេនៅប៉ៃលិន គេចុះមកគេលេងនៅជាមួយគ្នា បានដឹងថាអើយអញនឹកណាស់អើយ ប្រាប់បងផងថា អញចង់ទៅលេង ទេបងប្រាប់អញថា បើជួប ភាព ឯងឲ្យអញនាំទៅ តែសាហ៊ុយអីៗមិនបាច់ទេ ទៅខ្លួនឯងចាំមកវិញ សាហ៊ុយ មកពីនោះ ហើយបងឥឡូវគាត់គ្រប់គ្រងខាងមន្ទីរពេទ្យណាស់  គាត់និយាយចេះណាស់  គាត់គ្រប់គ្រងខាងមន្ទីរពេទ្យ ហើយឯងឈឺច្រើនចេះទៅ គ្រាន់បានថ្នាំមកប្រើខ្វះ ។

សុវណ្ណៈ	ចឹងគាត់ពេទ្យខាងរដ្ឋមីង?

ភាពៈ	គាត់ពេទ្យរដ្ឋដឹង គាត់ថានៅគ្រប់គ្រងកន្លែងពេទ្យ នៅកន្លែងពេទ្យធំចេះ ។

សុវណ្ណៈ	នៅទីរួមខេត្តកោះកុងឬក៏?

ភាពៈ	ឮថានៅកោះកុងមិនដឹងជាម្តុំណា ខ្ញុំក៏ភ្លេចសួរដែរ បងកេង កាលជិនាន់ប៉ុល ពត គាត់ប្រធានពេទ្យនៅប្រចាំ«៣២» ឥឡូវគាត់នៅជុំគ្នាគាត់ហ្នឹង ។

សុវណ្ណៈ	បងកេង?

ភាពៈ	ចាស!បងកេង ស្រីដែរ ពេទ្យដូចគ្នាហ្នឹង ថាបងៗនោះស្មើនិងម៉ែ ល្អណាស់ ។

សុវណ្ណៈ	ម៉េចបានមីងគិតថា គាត់ស្មើនិងម៉ែ?

ភាពៈ	ចុះគាត់ផ្គត់ផ្គង់អ៊ីៗសព្វគ្រប់ទៅទីណាកន្លែងណា  គាត់មិនដែលបោលណា  គាត់មិនភ្លេចទេត្បិតតែគាត់ធំប៉ុណ្ណឹង គាត់មិនភ្លេចទេ របស់គាត់សំខាន់ៗអីត្រូវឲ្យៗព្រុះតែម្តង ។

សុវណ្ណៈ	ប្រធានពេទ្យ«៣២»?

ភាពៈ	ចាស!ប្រធានពេទ្យ«៣២»ឈ្មោះ បងកេង ។

សុវណ្ណៈ	ស្រីដែរ?

ភាព៖ ស្រី ។

សុវណ្ណៈ ដល់ពេលសព្វថ្ងៃគាត់នៅកោះកុងជុំគ្នាទាំងអស់?

ភាព៖ រាល់ថ្ងៃបងកេង គាត់នៅកោះកុងដូចគ្នាហ្នឹង នៅជុំបងសុន ហ្នឹង ។

សុវណ្ណៈ នៅជុំបងសុន ហ្នឹងគាត់នៅកោះកុងធ្វើពេទ្យដែលសព្វថ្ងៃនេះ?

ភាព៖ ចាស!នៅជុំគ្នាគាត់ដែរ បងសុន គាត់ចាស់ហើយ បងកេង គាត់នៅក្មេងជាង តែបងកេង គាត់បែកពីខ្ញុំទៅគាត់អាចអាយុ៣០ ។

សុវណ្ណៈ ហើយមីងដែលបានទៅលេងគាត់ទេ.?

ភាព៖ ខ្ញុំមិនដែលបានទៅទេ ។

សុវណ្ណៈ ម៉េចចឹង?

ភាព៖ បើខ្ញុំជិះឡានមិនបាន ជិះឡានឆ្វាយវិញមុខ ។

សុវណ្ណៈ ចឹងដែលខលទាក់ទងលេង?

ភាព៖ មិនដែលទេ កាលដែលខលមកគេឲ្យលេខ គេឲ្យលេខទាក់ទងទៅគ្រាន់សួរថា បងអាចមកលេងខ្ញុំបានទេ គាត់ថាពីណា ខ្ញុំថាឈ្មោះ ភាព មីប្រកាច់អញស្មានថា ងាប់បាត់ហើយ គាត់ស្តាប់សម្លេងខ្ញុំបាន ខ្ញុំប្រាប់គាត់ថា ខ្ញុំឈឺខ្ញុំទៅមិនបានទេបង គាត់ថាមកចាំអញឲ្យថ្នាំយកទៅប្រើ មកលេងមួយខែពីរខែទៅចាំទៅវិញ ហើយគាត់សួរកូនចៅយ៉ាងម៉េចហើយ ខ្ញុំថា កូនមានប្តីអស់ហើយបង ឥឡូវនៅពីរនាក់យាយតា មានចៅអីអស់ហើយ ខ្ញុំសុំលេខគាត់បានទាក់ទង ដល់ពេលនេះទៅកូនវាទាញសៀវភៅចុះឡើងបាត់លេខទៅ ចាំមើលផលខែប្រាំងលោគេមក ផល ខែប្រាំងគេមក ។

សុវណ្ណៈ ចឹងគាត់មានថាមកលេងមីងវិញទេ?

ភាព៖ ចាស!គាត់ថា ឲ្យខ្ញុំទៅលេង គាត់អត់មានពេលមកទេ គាត់ពិបាកណាស់ ខ្ញុំថាបងឯងពិបាកតាំងពីណាពីណី ឥឡូវបងឯងមិននៅស្រួលខ្លះនៅតែពិបាក អញទៅណាសម្ភារៈគេពេញឃ្លាំងនោះបាត់របស់គេទៅយ៉ាងម៉េចអញ ទទួលបន្ទុកតាំងពីដើមហ្នឹងឯង ខ្ញុំថាងាប់ធ្វើធំអីៗមិនបេះខ្ចិលសោះ ខ្ញុំថាបេះ បងឯងធ្វើធំមិនបេះខ្ចិល ។

សុវណ្ណៈ ចឹងមីងថា ចូលបដិវត្តនៅឆ្នាំ៧១ ពេលចូលដំបូងមីងថាមានអារម្មណ៍ចង់ធ្វើទាហានអីចឹងត្រូវទេមីង?

ភាព៖ ទេ អារម្មណ៍មុនដំបូងទៅពីផ្ទះថា ចង់ធ្វើទាហាន ដល់ពេលទៅមន្ទីរអីចឹងទៅបានបីខែទៅបួនខែចាប់ផ្តើមនឹកផ្ទះ បងសុន គាត់ថា មុខមីហ្នឹងអត់ស្រស់ទេ សង្ស័យនឹកផ្ទះណាស់ ចឹងអញមិនឲ្យធ្វើយោធាអីទេ អញឲ្យធ្វើនេះវិញ ខ្ញុំរថាធ្វើអីបង អញឲ្យរៀនសិល្បៈ លោ

រៀនរាំទៅវាសប្បាយ វាមិននឹកផ្ទះ ដល់ចឹងទៅខ្ញុំរៀនសិល្បៈ ខ្ញុំចូលសិល្បៈបានប្រហែលជាកន្លះឆ្នាំ ចូលសិល្បៈគាត់ឲ្យរៀនដើរតួរឿង រៀនច្រៀងរៀនអីចឹងទៅបានប្រហែលជាកន្លះឆ្នាំដែរ ចឹងបានគាត់ឲ្យហាត់យោធា ។

សុវណ្ណៈ	ចឹងចូលសិល្បៈដំបូងបានកន្លះឆ្នាំងហ្នឹង នៅក្រោមការគ្រប់គ្រងរបស់ពីណាគេ?

ភាពៈ	គ្រប់គ្រងបន្ទាប់ពីគាត់ទៅវាមានភ្លេចបាត់ហើយ ។

សុវណ្ណៈ	ប្រធានសិល្បៈមីង?

ភាពៈ	ចាស!ប្រធានសិល្បៈឈ្មោះអីទេ ខ្ញុំភ្លេចបាត់ហើយក្មួយអើយ ។

សុវណ្ណៈ	តែស្រីឬប្រុសមីង?

ភាពៈ	ស្រី ។

សុវណ្ណៈ	ក្មេងឬមួយចាស់?

ភាពៈ	មួយស្រករគ្នាហ្នឹងណា គេឆ្លាតព្រោះគេរៀនពីដើមឡើងចប់ថ្នាក់ហើយនោះ ដល់ចឹងគេទៅជាបញ្ញាជន ជនបទហើយគេមានសញ្ញាប័ត្រ ។

សុវណ្ណៈ	នៅព្រះវិហារដដែលទេ?

ភាពៈ	ចាស!អ្នកព្រះវិហារដូចគ្នា ឆ្លាតៗណាស់ស្រីៗ ។

សុវណ្ណៈ	ប្រធានតំបន់គេ ឈ្មោះ បងសុន ហ្នឹងហើយ?

ភាពៈ	ចាស!បងសុន ។

សុវណ្ណៈ	ចឹងមីងចូលបានកន្លះឆ្នាំទៅ មីងចូលធ្វើទាហានទៅ?

ភាពៈ	ចាស ។

សុវណ្ណៈ	កាលហ្នឹងទាហាននៅក្រោមការគ្រប់គ្រងរបស់ពីណាគេដែរ?

ភាពៈ	ក្រោមការដឹកនាំរបស់បងគង់ ឈ្មោះ បងគង់ បងគង់ហ្នឹង គាត់នៅកំលោះទេ គាត់បង្រៀន គាត់បង្ហាត់លូនក្រោមអី ។

សុវណ្ណៈ	ឈ្មោះ បងពុំ?

ភាពៈ	បងគង់ គាត់បង្ហាត់ឲ្យបាញ់ បង្ហាត់ដោះកាំភ្លើង មុនដំបូងគាត់បង្រៀនដោះកាំភ្លើង យកកាំភ្លើងមកដោះអស់ចឹងទៅ ចាប់ផ្ដើមរៀបឡើងវិញ រៀបមួយសារអត់ត្រូវឲ្យដោះរៀបមួយសារទៀត រៀនដោះចេះហើយឲ្យរៀបបាញ់ម្ដង រៀនបាញ់ឲ្យបាញ់កាំភ្លើងគ្រប់ធុនលើកលែងតែអាធំ យើងបាញ់មិនកើត ។

សុវណ្ណៈ	មីងធ្លាប់បាញ់កាំភ្លើងអីខ្លះ?

ភាព: ខ្ញុំអាកាក៏ខ្ញុំចេះបាញ់ សេកាសេក៏ខ្ញុំចេះបាញ់ អាខ្វិក៏ខ្ញុំចេះ ខ្ញុំចេះបាញ់បានពីរបីធុនដែរ សាំសុនក៏ខ្ញុំចេះបាញ់តែធ្ងន់លើកមិនរួច ខ្ញុំកាលហ្នឹងកាន់តែកាប៉ាប៊ី កាប៉ាប៊ីបាញ់ត្រង់ ។

សុវណ្ណៈ ចឹងរៀនបានប៉ុន្មានខែគេឲ្យយើងបាញ់បាន?

ភាព: រៀនបាន៦ខែ ។

សុវណ្ណៈ ចឹងការហាត់ហ្នឹងតឹងរឹងទេ?

ភាព: តឹងរឹង ហាត់ដាក់ស្នឹកឈើលើខ្នងទៀតនោះ ហើយលូនអស់ហើយក្បាលជន្គង់កែងដៃ ហើយដើងដាក់មិនស្មើគេទាត់ជើងទាត់អី ហើយតាមចេះគិតពីទៅហើយខ្ញុំហាត់ ។

សុវណ្ណៈ ចឹងកងរបស់មីងសុទ្ធតែនារីទាំងអស់?

ភាព: ចាស ។

សុវណ្ណៈ ចឹងកងនារីតែម្ដង?

ភាព: កងនារី ។

សុវណ្ណៈ គេមានឈ្មោះ របស់គេទេមីង?

ភាព: ចាស! គេមានឈ្មោះ ។

សុវណ្ណៈ កងពលលេខប៉ុន្មានឬក៏ក្រុមលេខប៉ុន្មានអី?

ភាព: ពួកខ្ញុំគេហៅពួកក្រុមពិសេស«ខ២» ។

សុវណ្ណៈ ចឹងក្រុមពិសេស«ខ២»?

ភាព: ចាស ។

សុវណ្ណៈ «ខ»ហ្នឹងមានន័យថាយ៉ាងម៉េចមីង?

ភាព: ដឹងយ៉ាងម៉េចទេ គេចេះតែដាក់ៗទៅ ។

សុវណ្ណៈ អត់មានឈ្មោះ កងពលអីទេ?

ភាព: អត់ទេ និយាយមួយមាត់ទៅមួយក្រុមៗរបស់គេ គេដាក់មិនឲ្យច្រឡំគ្នាដូចថាយើងក្រុម១ ក្រុម២ចេះណា ។

សុវណ្ណៈ រស់នៅតែស្រីទាំងអស់ទេ?

ភាព: មានស្រីមានប្រុស ប្រុសនៅមួយប៉ែកខាងនោះ នោះប្រុសគេបង្រៀនបង្ហាត់ហើយអាហ្នឹង ប្រុសគេខាងបិតចំរូងណានិងឃ្លាលសេះ មើលសេះហើយមើលដីរ ខ្លះមើលដីរអ្នកខ្លះមើល សេះ តែសេះនោះសុទ្ធតែសេះជំនាញណាស់ គេហៅនិរសាគេ ត្រូវមានការអីនេះតែម្ដង ខ្ញុំមានមិត្តភក្ដិមួយប្រឡងសេះជាប់ ឈ្មោះ ញឹប មានការអីសេះគេមានតែមួយហ្នឹង

ដូចនៅក្នុងរឿង សេះ បើថាមានការអីទាញក្រមាចង់ប៉ាច់បេះបង្កេះបេះហើយមូលដៃទាញសេះបានឡើងភ្លេត ។

សុវណ្ណៈ ចឹងនៅក្នុងតំបន់១០៣ហ្នឹងមានប៉ុន្មានកងដែលមីង?

ភាពៈ មិនដឹងទេ មីងដឹងតែក្នុងមន្ទីរខ្លួនឯង បើថាឆ្ងាយៗមិនដឹងដែរ នៅនេះមួយក្រុមនោះមួយក្រុមទៅមិនដឹងជាប៉ុន្មានក្រុម ។

សុវណ្ណៈ ចឹងវាអាចមាន“ខ១ខ២ខ៣អី”?

ភាពៈ ចាស!វាមាន“ខ២ បើ“គ២នៅខាងពេទ្យ ខ២នៅកន្លែងមន្ទីរហើយនៅ“ក១នោះនៅជ័យសែននោះវាមានបី“ខ” តាមខ្ញុំដឹងមាន“គ២ មានខ២ មានក១” ។

សុវណ្ណៈ ចឹងអត់មាន“ខ១ខ៣អីទេ”?

ភាពៈ អត់មានទេ ។

សុវណ្ណៈ ចឹងគេដាក់ចន្លោះចឹងវិញ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងគេដាក់“ខ២”ជាទាហានរបស់ខាងនារី កងនារី?

ភាពៈ ចាស ។

សុវណ្ណៈ ដល់ពេល“គ២”ហ្នឹងខាងពេទ្យ?

ភាពៈ ពេទ្យ ។

សុវណ្ណៈ ចឹងដល់“ក១”?

ភាពៈ “ក១” នោះជាមន្ទីរធំរបស់ខាងគណៈតំបន់ ។

សុវណ្ណៈ មន្ទីរហ្នឹងជាមន្ទីរអីគេ?

ភាពៈ មន្ទីរធំរបស់គណៈតំបន់ ឧទាហរណ៍ថា និយាយមួយមាត់ដូចយើងរាល់ថ្ងៃដូចថា កន្លែងគេអ្នកធំ អ្នកមិនទុកចិត្តមិនឲ្យចូលណា លើកលែងតែអ្នកទុកចិត្តអ្នកជំនាញដៃស្តាំអីបានចេញចូលបានខាង“ក១” ។

សុវណ្ណៈ មានលេខមន្ទីរដែលអត់មន្ទីររបស់គេហ្នឹង?

ភាពៈ មានលេខ ។

សុវណ្ណៈ លេខអីគេ?

ភាពៈ គេគ្រាន់ដាក់ថា“ក១”ប៉ុណ្ណឹងឯង មន្ទីរ“ក១”ប៉ុណ្ណឹងឯង ។

សុវណ្ណៈ មន្ទីរ“ក១”?

ភាពៈ ចាស!កន្លែងតំបន់ទាំងអស់គេដឹងទាំងអស់ ក្នុងតំបន់សុទ្ធតែកូនចៅ មានកន្លែងគេធំហើយរោងគេធំទៀត កន្លែងគាត់នៅឆ្ងាយពីនេះទៅផ្ទះនោះ មានរោងអាធំខាងនេះដាក់ដីរ៉ឺពីរនៅនោះ បើអ្នកណាចង់ចូលចង់អីណា ទាល់តែមាននិរសាគេឯងចេញមកបានទៅជួបបាន ដូចជាប្រធានធំគេមិនទុកចិត្តណាស់ ចឹងហើយនៅតែមានភ្នាតបានទៀត ។

សុវណ្ណៈ ភ្នាតយ៉ាងម៉េចមីង?

ភាពៈ ភ្នាត ប្តីបងសុន ភ្នាតនិរសាផ្ទាល់ហ្នឹងណាបាញ់សាប់ហ្នឹង ភ្នាតបានដូចជាអ្នកមិនសោះត្រង់នៅជាមួយណា ដល់ចឹងនិរសាខ្លួនឯងបាញ់សាប់ទៅ ។

សុវណ្ណៈ ម៉េចក៏ចឹង?

ភាពៈ ហ្នឹងឯងបានថា ។

សុវណ្ណៈ រឿងអីគេ?

ភាពៈ ការពារប៉ុណ្ណោះហើយ រឿងស្អីអត់មានដឹងមូលហេតុសោះ បើធ្លាប់នៅបាយទឹកទៅណាមកណា ជិះម៉ូតូ ជិះឡានទៅជាមួយគ្នា ហើយវាមើលការខុសត្រូវអីទាំងអស់ អ្នកណាក៏ទុកចិត្តដែលដល់ពេលថ្ងៃមួយមិនដឹងជាយ៉ាងម៉េច គាត់សំរានលក់បាត់វាចូលទៅកន្លែងគាត់ ចុះមានពីណាចាប់អារម្មណ៍នឹកឃើញថា ដូចជាកូនដូចជាឪពុកហើយ ចឹងវាបាញ់គាត់សាប់ទៅបាញ់មានយកមកពេទ្យទាន់ណា ។

សុវណ្ណៈ បាញ់ឆ្នាំណាមីងកាលហ្នឹង?

ភាពៈ ឆ្នាំណាទេ ។

សុវណ្ណៈ ឆ្នាំ៧៥ឬមិនទាន់៧៥ទេ?

ភាពៈ ប្រហែលជា៧៥-៧៦ហ្នឹង ប្រហែលជា៧៥ ។

សុវណ្ណៈ វាយបានគ្រប់គ្រងភ្នំពេញហើយនៅ ៧៥ហ្នឹង មិនទាន់គ្រប់គ្រងភ្នំពេញណា?

ភាពៈ ទេ នៅទេ មុនចឹងបែប៧៤ដឹងយ៉ាង ។

សុវណ្ណៈ ចឹងមីងចូលហាត់ទាហានហ្នឹង មីងនៅក្នុង«ខពិសេស២»មីង?

ភាពៈ «ខ២» ។

សុវណ្ណៈ ចឹងមន្ទីរ«ខ២»?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងមន្ទីរ«ខ២»ហ្នឹងនៅខាងក្រុមនារីទេ?

ភាពៈ ចាស!សម្បូរតែនារីទេ យុទ្ធជនមានត្រឹម៥នាក់ទេ ក្រៅពីនោះសុទ្ធតែនារី ។

សុវណ្ណៈ យុទ្ធជនហ្នឹងធ្វើអីគេខ្លះ?

ភាព: យុទ្ធជនមានអី មាននៅយាមខាងក្រៅហ្នឹង កន្លែងនៅខាងក្នុងសុទ្ធនារីយាមបរិវេនចឹងទៅ ខាក្រៅទ្វារធំចេះទៅ គេមានយុទ្ធជនគេនៅការពារហើយមានសេះគេ បើមានការអីខាងក្នុង យ៉ាងម៉េចម៉ា ខាងក្រៅហ្នឹងឯងអ្នកនិរសាលឿន រាល់ថ្ងៃដូចថាមានទូរស័ព្ទអីៗ កាលហ្នឹង មានទូរស័ព្ទអីណា ត្រូវការមានការអីពីណាចង់បើកអីមានសេះហ្នឹងហើយលឿន ស្រឡឹង ប៉ាច់ទៅម្នាក់ឯងដូចគេពួយចឹង កងនារីពួកខ្ញុំបានសេះមួយបានបង ញឹប មីហ្នឹងឲ្យតែចាប់ សេះហើយ មិនបាច់ពីណាជិះក្រោយទេ ដាំងព្រឹសទៅប៉ុណ្ណឹងឯង ហើយដូចនៅក្នុងរឿង ហើយមីនោះរៀនថ្នាក់ខ្ពស់ជាងគេដង ឈ្មោះ បងញឹប គ្រូបង្រៀនទៀតណា ប្រជាជន រាប់រយរាប់ពាន់អី វាគ្រូបង្រៀន ចូលក្នុងសាលាសរសេរនិយាយប៉ុន្មានសរសេរប៉ុណ្ណោះ អាមាត់ចេះតែនិយាយអាដៃចេះតែសរសេរ ធ្វើអីក៏ឆ្លាតដែលមីនោះ មានតែមួយហ្នឹងឯង ដើងឯកជាងគេ ។

សុវណ្ណ: មីងមានគ្នាប៉ុន្មាននាក់ដែរ?

ភាព: គ្នាពួកខ្ញុំមាន១២នាក់ ។

សុវណ្ណ: ចឹងមន្ទីរទាំងមូលទាំងអស់តែម្ដង?

ភាព: ទេ ក្នុងក្រុមរបស់ខ្ញុំមាន១២នាក់ ។

សុវណ្ណ: ចឹងក្នុងក្រុមរបស់មីងមាន១២នាក់ទេ?

ភាព: ចាស ។

សុវណ្ណ: «១២»?

ភាព: «១២» ។

សុវណ្ណ: ចឹងមាន១២នាក់ទេ?

ភាព: ចាស ។

សុវណ្ណ: មានតិចចឹងមីង?

ភាព: គេមិនសូវយកអ្នកឆ្កែកឆ្កួច វាមានមួយក្រុមៗគេច្រើន ។

សុវណ្ណ: ចឹងទាំងមូលមន្ទីរ«១២»ហ្នឹង?

ភាព: ក្នុងក្រុមរបស់ខ្ញុំដូចថាមានមួយផ្ទះមួយក្រុមខ្ញុំ១២នាក់ ដល់មានគេទៀតខ្ញុំមិនបានដឹងទេ ខ្ញុំ មិនដឹងជាប៉ុន្មានៗទេ ។

សុវណ្ណ: ភាគច្រើនមកពីខាងណាវិញ១២នាក់ហ្នឹង?

ភាព: ចំរុះ ។

សុវណ្ណ: មកពីខាងណាខ្លះមីងមានដឹងទេ?

ភាព: ជួនកាលពួកមកពីស្រុកពីភូមិហ្នឹងឯង មកពីខាងខេត្តកណ្ដាលក៏មាន ខាងកំពង់ធំ កំពង់ស្ពឺអី មកពីខាងផាឡាបរិវ៉ាត់អី មកពីខាងកោះព្រះនគ្គ័លក៏មាន មានទាំងអស់មនុស្សចំរុះ ដល់ចឹងអត់មានដឹងអ្នកភូមិអ្នកស្រុកគេ ដឹងថាភូមិស្រុកគេនៅណាទេ ទាល់តែមេបានដឹង ព្រោះគេជាអ្នកក្ដាប់ប្រវត្តិរូប ។

សុវណ្ណៈ មីងជាជនជាតិឬអត់ទេ?

ភាព: ខ្ញុំមិនមែនជនជាតិទេ ។

សុវណ្ណៈ ចឹងមីងខ្មែរទេ?

ភាព: ចាស!ខ្ញុំខ្មែរ ។

សុវណ្ណៈ ខ្ញុំស្មានថាគេជ្រើសរើសជនជាតិឲ្យនៅមួយដុំមីង?

ភាព: អត់ទេ គេឲ្យនៅចំរុះ ។

សុវណ្ណៈ ហើយមីងមានខស្សាហ៍ជួបបងសុន ហ្នឹងទេ ពេលមីងនៅតំបន់១០៣ហ្នឹង?

ភាព: ខ្ញុំកាលពីមុនខ្ញុំនៅជាមួយគាត់ ចេញចូល១ ។

សុវណ្ណៈ ធ្វើអីខ្លះជាមួយគាត់មីង កិច្ចការអីទៅ?

ភាព: ជួនកាលនៅដាំបាយហូបចឹងទៅ ចេញទៅកន្ទែងបង ជួនណាគាត់ថា ពួកនេះអត់មានដាំបន្លែអីទេ ខ្ញុំថាដាំតើបង មើលដាំរួចហើយចំរះគៀនខាងអីជង អត់មានការងារអីទេ មានតែដាំបន្លែហូបហ្នឹង បោសផ្ទះ ហើយហាត់រៀន បើអ្នកណាចង់ដេរក៏ដេរទៅបើម៉ាស៊ីនមានបួនទៅប្រាំគ្រឿងដាក់ជន្ទែម៉ាស៊ីនចេះ អ្នកណាចង់ដេរ១ទៅ អ្នកណាចង់រៀនដេរក៏ដេរទៅចេះតែទំនេរដេរទៅ ជាងដេរនៅនោះពីរនាក់ដែរ គេអត់មានហាមអត់ឃាត់ទេ របស់រួមអ្នកចង់ដេរ១ទៅ ដេរវាំងនន ដេរខោ ដេរអាវ ដេរអង្រឹងអី ។

សុវណ្ណៈ ចឹងបន្ទាប់ពីធ្វើទាហានទៅ មីងធ្វើអីទៀតទៅ?

ភាព: អត់មានបានធ្វើអីទេ ។

សុវណ្ណៈ ចូលទៅធ្វើទាហានរហូតទៅ?

ភាព: ចាស!ធ្វើទាហានដល់ទៅ កាលនោះធ្វើទាហានទៅចាប់តាំងពីឆ្នាំ៧៦ ឆ្នាំ៧៦ខ្ញុំចេញពីនោះហើយ បងសុន គាត់ស្លាប់ប្ដីគាត់ទៅក៏គាត់ឈឺ ដល់ឈឺកូនគាត់នៅកោះកុង យកគាត់ទៅកោះកុងមួយរយៈ ដល់ចឹងខ្ញុំក៏នៅជាមួយបងកេង បងកេងថា ភាព អើយបងទៅបាត់ហើយមកនៅជាមួយបងនេះមក ខ្ញុំថាបងអើយខ្ញុំអត់ចង់នៅជាមួយបងឯងទេ ខ្ញុំចង់ទៅភ្នំពេញ ឆ្នាំ៧៥ហ្នឹង ខ្ញុំចង់ទៅភ្នំពេញ ។

សុវណ្ណៈ ចឹងយើងកុំអាលនិយាយដល់៧៥សិន?

ភាព: ចាស ។

សុវណ្ណៈ ចឹងដល់ច្បាស់ពីឆ្នាំ៧០ដល់មុន៧៥សិន ចឹងមីងនៅប៉ុន្មានឆ្នាំនៅធ្វើទាហានរហូតទៅ?

ភាព: ទេ ខ្ញុំធ្វើប្រហែលបានជាមួយឆ្នាំទេ ។

សុវណ្ណៈ ចឹងមួយឆ្នាំមីងឈប់ហើយ មីងធ្វើអីទៀត?

ភាព: ដល់ពេលខ្ញុំឈប់ខ្ញុំនៅធម្មតា ខ្ញុំចូលកន្លែងពេទ្យវិញ ខ្ញុំចូលធ្វើពេទ្យឆ្មប ។

សុវណ្ណៈ ចូលកាលហ្នឹងចូលនៅឆ្នាំណាមីង?

ភាព: ឆ្នាំ៧៦ ។

សុវណ្ណៈ ចឹងមានន័យថា មីងចូលទាហានចុងឆ្នាំ៧១ហើយ ចូលហាត់ទាហានមុនដំបូង៧១?

ភាព: ចាស!៧១ចូលវាមិនបានជាប់ ។

សុវណ្ណៈ ចឹងកន្លះឆ្នាំក្រោយមកចូលសិល្បៈ?

ភាព: ចាស ។

សុវណ្ណៈ ចឹងធ្វើទាហានរហូតដល់គេវាយបែកភ្នំពេញ?

ភាព: ធ្វើទាហានបានមួយឆ្នាំចេះទៅ បងថាទាហាននេះដឹងថាទាហានអីទេ ទាហានស្អរគ្រាប់ថាឲ្យខ្ញុំទាហានអីទេ វាធ្វើទាហានឈ្មោះទាហាន ពេលវាកាន់កាំភ្លើងពេលគេហៅដល់ពេលនេះវានៅញុកញៀវតែកន្លែងពេទ្យរកតែអ្នកជំងឺ បែបវាចង់កើតពេទ្យឆ្មបទេដឹង ពេលទៅ ។

សុវណ្ណៈ មានបានទៅសមរភូមិគេទេ?

ភាព: អត់មានដែលទៅទេ ។

សុវណ្ណៈ អត់ដែលបញ្ជូនទៅសមរភូមិទេ?

ភាព: មិនដែលទេ ខ្ញុំមិនដែលបានទៅណា គេឲ្យកាន់យាមយប់ ។

សុវណ្ណៈ ចឹងពេលឡើងវាយភ្នំពេញនោះ មីងមានបានវាយនិងគេដែលអត់ទេ?

ភាព: អត់ទេ អត់មានដែលស្គាល់ភ្នំពេញទេ ។

សុវណ្ណៈ នៅក្នុងភូមិរហូតទៅ?

ភាព: នៅក្នុងមន្ទីរគេហ្នឹងណា គេឲ្យការពារយាមយប់ៗកាលហ្នឹង ថ្ងៃឡើងទុកកាំភ្លើងយប់ឡើងទៅយកយាមប៉ុណ្ណោះឯង ។

សុវណ្ណៈ ដល់ពេលឆ្នាំ៧៦ចូលខាងពេទ្យវិញ?

ភាព: ចាស!ដល់ឆ្នាំ៧៦ខ្ញុំចូលពេទ្យឆ្មប ពេទ្យឆ្មបបានប្រហែលជាកន្លះឆ្នាំដែរ ។

សុវណ្ណៈ ចឹងមូលហេតុអីបានជាចូលពេទ្យឆ្មបមីង?

ភាពៈ បានជាខ្ញុំចូលព្រោះអី  កាលហ្នឹងដូចជាចិត្តចង់តែម្ដង  ឃើញគេសម្រាលជីងថាចង់ជួយអត់ខ្ពើមអត់មានរអើម ដល់ចឹងគិត បងសួរថា ពួកង៉ែងធ្វើពេទ្យឆ្មបកើតដែលអត់ ខ្ពើមឈាមខ្ពើមខ្ទុះអីទេជីង ខ្ញុំថាអត់ទេ អើអត់ទេ ចឹងទៅជាមួយបង ទៅដល់មនុស្សប្រុសប៉ុនក្អួយឯងហ្នឹង វាកើតកោបនោះ គេថាធ្លាក់ពោះវៀនអីនោះ ដល់ចឹងគាត់វះ ដល់វះទៅមានអី ដល់វះទៅគាត់ថា ខ្ញុំចាប់ជាប់តែម្ដង ខ្ញុំអត់មានខ្លាចឈាមអីទេ វះហើយគាត់ឲ្យខ្ញុំថែ ខ្ញុំទៅលើអាចម៍ លើនោម គួកខោអីដល់ចឹង បងថាយ៉ា មីនេះអាចធ្វើពេទ្យបានហើយចុះ ដល់ចឹងទៅឲ្យខ្ញុំរៀនពេទ្យឆ្មប គេហៅខ្ញុំតែយាយម៉បក្មេង ខ្ញុំកាន់ស្និទ្ធទៅ តែខ្ញុំវាមិនបានរៀនសូត្រអីទេ ។

សុវណ្ណៈ ចឹងនៅក្នុងមន្ទីរ «១២» ដែលទេ?

ភាពៈ ចាស! នៅមន្ទីរ១២ ខ្ញុំធ្វើនៅកន្លែងមន្ទីរ «៣២» ។

សុវណ្ណៈ ចឹងក្រោយមកដូរចូល «៣២» វិញ?

ភាពៈ ចាស! ព្រោះពេទ្យ «៣២» ។

សុវណ្ណៈ ចឹង «៣២» នៅជាមួយគ្នាកន្លែងដដែលឬមួយកន្លែងផ្សេង?

ភាពៈ ចាស! កន្លែង ទោះបីជាផ្លាស់កន្លែងក៏នៅតែគេយកឈ្មោះ «៣២» ហ្នឹង ។

សុវណ្ណៈ តែនៅក្នុងបរិវេនជាមួយ «១២» ដដែលឬមួយយ៉ាងម៉េច?

ភាពៈ អត់ទេ «១២» នៅផ្សេង ។

សុវណ្ណៈ ចឹងដូរទៅ៣២វិញ?

ភាពៈ ចាស ។

សុវណ្ណៈ ៣២ នៅម្ដុំខាងណាវិញ?

ភាពៈ ៣២កាលនោះនៅខាងជើងស្រុករវៀង ស្រុករវៀងខាងជើងនៅភូមិខ្វាំង ។

សុវណ្ណៈ ចឹង១២?

ភាពៈ ១២គេនៅខាងអន្លង់ស្វាយ នៅភូមិអន្លង់ស្វាយ ដល់ចឹងវាឆ្ងាយពីគ្នា ចង់ពីហ្នឹងទៅត្រពាំងប្រាសាទ បើមានការអីរហ័សដល់ ព្រោះយើងមានសេះលឿនណាស់ ។

សុវណ្ណៈ ដល់ពេលបងកេង ហ្នឹងជាប្រធានគ្រប់គ្រងរបស់មីង?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងបងកេងហ្នឹង ជាអ្នកស្រុកមកពីខាងណាវិញឬអ្នកស្រុកហ្នឹងដែរ?

ភាពៈ បងកេង កាលហ្នឹងគាត់នៅភ្នំពេញដែរ គាត់រៀនឱុកទ័រតាំងពីសង្គមមក ដល់ពីសង្គមគាត់ស្រាវជ្រាវតាមរយៈគាត់មក ខ្ញុំចូលទៅឃើញគាត់ប្រធានធំតែម្ដង ខ្ញុំមិនដែលបានសួររក

ភូមិស្រុកគាត់ទេ បើគាត់សុទ្ធតែចេះជំនាញៗ ឧកទ័រគេសុទ្ធតែធំៗគេ មិនដឹងជាគាត់មកពីណា ។

សុវណ្ណៈ ចឹងមិនដែលសួរនាំគាត់ទេ?

ភាពៈ ចាស! យើងម៉េចហ៊ានសួរគេ ។

សុវណ្ណៈ ចឹងមានដឹងប្រវត្តិគេថា មកពីណាពីណីទេ?

ភាពៈ អត់ដឹងទេ គាត់អ្នកមកជាមួយសួរថា បងស្រុកគាត់នៅណា បងគាត់មកពីភ្នំពេញណា គាត់ធ្វើតាំងពីសង្គម ដល់ចឹងចំណោះដឹងគាត់អត់មានបាត់បង់ទេ នៅជំនាន់នេះគាត់នៅមានការជួយបណ្តុះបណ្តាលដល់យើងគ្រប់គ្នា ឲ្យយើងចេះដឹង គាត់ចិត្តល្អណាស់បង ។

សុវណ្ណៈ ចឹងឆ្នាំ៧៦មីងធ្វើពេទ្យបានកន្លះឆ្នាំមីងធ្វើអីទៀត?

ភាពៈ ដល់ខ្ញុំឈប់ធ្វើពេទ្យខ្ញុំបានទៅនៅភ្នំពេញជាមួយគេ ។

សុវណ្ណៈ ចឹងទៅភ្នំពេញឆ្នាំ៧៦ដែលទេ?

ភាពៈ ចាស ។

សុវណ្ណៈ បន្ទាប់ចេញពីពេទ្យ?

ភាពៈ ចេញពីពេទ្យទៅខ្ញុំទៅភ្នំពេញ ។

សុវណ្ណៈ ទៅធ្វើអីគេនៅភ្នំពេញមីង?

ភាពៈ ចាស!ខ្ញុំទៅដឹកជញ្ជូន ទៅដឹកជញ្ជូនជាមួយគេ នៅខាងពាណិជ្ជកម្មរដ្ឋ គេហៅពួកឡានពាណិជ្ជកម្មរដ្ឋហ្នឹង ដល់ចឹងយកឥវ៉ាន់មកចែកតាមសហករណ៍ តាមសហករណ៍ទៀត មានខោអាវនិងសម្ភារផ្សេងៗ គេហៅឲ្យខ្ញុំទៅធ្វើពាណិជ្ជកម្មរដ្ឋ ។

សុវណ្ណៈ នៅកន្លែងណាវិញមីង?

ភាពៈ តំបន់១០៣ ។

សុវណ្ណៈ ចឹងដឹងថា ពាណិជ្ជកម្មរដ្ឋមីងនៅភ្នំពេញហ្នឹង?

ភាពៈ ចាស!ពាណិជ្ជកម្មរដ្ឋនៅ១០៣ ពេលនៅភ្នំពេញ មិនដឹងថានៅកន្លែងណាទេ ពេលជិះឡានទៅដល់ចុះព្រឹប គេដាក់ឡានហើយទៅទៀត គេផ្លាស់កន្លែងមិនដឹងជាស្អីណាណី នៅដែលតែមិនសូវបានដើរទេ ចង់ទៅកន្លែងណាជិះឡានទៅ នាំគ្នាឈរមើលបានកន្លះម៉ោងអីនាំគ្នាទៅវិញ ។

សុវណ្ណៈ មិនមែននៅកន្លែងជ្រោយចង្វារទេ?

ភាពៈ ចាស!ជ្រោយចង្វារហើយបាននៅ ។

សុវណ្ណៈ នៅឃ្លាំងរដ្ឋអី?

ភាព៖ បើអត់ស្គាល់ សុទ្ធតែអ្នកទៅពីនេះដូចគ្នា ចឹងខ្ញុំចេះតែនៅៗទៅ ។

សុវណ្ណៈ ចឹងបានន័យថា បន្ទាប់ពីកន្លះឆ្នាំចេញពីពេទ្យមកយើងទៅភ្នំពេញ យើងទៅធ្វើពាណិជ្ជកម្មរដ្ឋ កាលហ្នឹង?

ភាព៖ ចាស ។

សុវណ្ណៈ ចឹងនៅភ្នំពេញហ្នឹងមីងអាចសម្គាល់ថា នៅម្តុំណានៅខាងជ្រោយចង្វា អូរឫស្សី ផ្សារថ្មី?

ភាព៖ នៅមួយជួរផ្សារថ្មី ។

សុវណ្ណៈ ចឹងនៅមួយជួរផ្សារថ្មី មីង?

ភាព៖ ចាស ។

សុវណ្ណៈ នៅម្តុំខាងណាវិញ ម៉ាជួរផ្សារថ្មី ព្រោះយើងមានខាងផ្សារគោប៉ាង?

ភាព៖ ដឹងត្រង់ណា បើសួរគេថា កន្លែងនេះគេហៅកន្លែងអីអ៊ី គេហ្នឹងហើយផ្សារថ្មី គេផ្សារ កន្លែងផ្សារថ្មីត្រូថាល្បីណាស់ យ៉ាងម៉េចក៏ចឹងអី ទេអញពីដើម អញមិនដែលបានមកផង ខ្ញុំមិនបាច់ចង់ដឹងទេ គេនាំទៅណាទៅហ្នឹង គេមើលអីក៏មើលគេ ទៅ ព្រឹមល្ងាចឡើងជិះឡានទៅមើលកន្លែងទន្លេបួនមុខ ទៅស្ពានជ្រោយចង្វា កាលហ្នឹងដាច់ ហើយមិនទាន់ធ្វើណា ដាច់អស់បាត់ហើយ ស្ពានបាក់មួយកំណាត់ហើយណា ចឹងយើងឆ្លងមិនបានទេ ឆ្លងតែសាឡាង ។

សុវណ្ណៈ កាលទៅភ្នំពេញជិះអីទៅកាលហ្នឹងមីង?

ភាព៖ កាលហ្នឹងជិះឡាន កាលហ្នឹងឆ្លងសាឡាងទៅ ។

សុវណ្ណៈ ឡានអីគេ?

ភាព៖ ឡានរដ្ឋ ។

សុវណ្ណៈ ឡានកាំមីញ៉ុញឬឡានអី?

ភាព៖ ជួនកាលជិះអាអំម៉ាឡង់ ឡានអីគេជិះបួននាក់ៗនោះ ។

សុវណ្ណៈ អាកាម៉ង់កា?

ភាព៖ ចាស!អាកាម៉ង់កា ។

សុវណ្ណៈ ចឹងជួរឡានច្រើនដែលនៅតាមផ្លូវ?

ភាព៖ ចាស!ជួនកាលជិះអាអំម៉ាឡង់ ជួនជិះអាកាម៉ង់កា ជួនកាលជិះឡានអាកាត់ៗអាមេរិកគេនោះ អាខៀវៗ ដូចឡានដឹកស្រូវដែលតែវាស្អាតដូចឡានទាហាន បើឡានមានគ្រប់គុនឡើងណាក៏បានដែរ ឲ្យតែគេហៅទៅ ។

សុវណ្ណៈ ធ្វើដំណើរប៉ុន្មានថ្ងៃបានដល់ភ្នំពេញ កាលហ្នឹង?

ភាពៈ ថ្ងៃពីនេះទៅ ថ្ងៃខ្ពស់ជាងនេះដល់ភ្នំពេញបាត់ ។

សុវណ្ណៈ មួយថ្ងៃអី?

ភាពៈ ចាស!មិនដល់មួយថ្ងៃទេ ក្រឡិចក្រឡុកជួនកាលនៅដល់កំពង់ចាម ថាចង់ទៅខាងកំពង់ចាមកាលហ្នឹង ។

សុវណ្ណៈ មីងគេងដេកសម្រាក់តាមផ្លូវ?

ភាពៈ អត់មានដេកទេ ប្រជាជនជួបតាមផ្លូវរត់មកគោរព ឡានខ្ញុំជិះអាកាម៉ង់កា ខ្ញុំទៅដល់ចុះពីឡាន ម៉ែៗកំពង់តែស្ទូងស្រូវនិយាយពីគោរពសំពះបេះយកនំគ្នោតមកឲ្យ ខ្ញុំលូកទៅចាប់ដៃខ្ញុំថាម៉ែអើយមិនបាច់សំពះពួកខ្ញុំទេ ខ្ញុំអាយុស្មើកូនម៉ែ មិនបាច់សំពះទេ ។

សុវណ្ណៈ ម៉េចបានគេសំពះយើងចឹង?

ភាពៈ មិនដឹងជាយ៉ាងម៉េចបានគេចូលចិត្តសំពះននិងឯង ខ្ញុំដូចជាឆ្ងល់ ថាកូនអើយកូនឯងនៅខាងណា ខ្ញុំថានៅ១០៣ ម៉ែមិនដឹងថា១០៣នៅណាទេ ម៉ែឮតែឈ្មោះ ម៉ែមិនដែលឃើញថាកូនឯងហូបនំគ្នោតមួយពីរទៅ ខ្ញុំថាមិនបាច់ទេ ទុកពិសារទៅខ្ញុំទៅឥឡូវហើយ ខ្ញុំពាក់ស្បែកជើងពុម្ពកម្ពុជានោះល្អៗណាស់ អាខ្លះមកអង្អើលស្បែកជើង ដឹងសក្តិប៉ុន្មានទៅបានស្បែកជើងបេះពាក់ ខ្ញុំថាខ្ញុំមិនមានសក្តិយសអីទេ ម៉ែអើយខោអាវគេចែកទូទៅក្មេងៗស្រីៗទាំងអស់គ្នានេះឯង និយាយពីសំពះ បងអ្នកបើកឡានខឹងខ្ញុំពូកែរៀនរាប់ណាស់ ធុញណាស់ថ្ងៃក្រោយមិនបាច់ឈប់ឡានទេ ចាស់ស្មើម៉ែហើយមកសំពះដៃ១០អី ថ្ងៃស្មើឲ្យលុយមួយម៉ឺនពីរម៉ឺន លើកដៃ១០មិនធម្មតាទេ យើងត្រូវសំពះគាត់ហើយរៀបរាប់ឲ្យគាត់មានទឹកចិត្តប្រជាជនមិនថាម៉ែគេម៉ែខ្ញុំទេ ថ្ងៃក្រោយឃើញបេះប្រជាជនស្អប់ ដេញកាប់រត់ជិះឡានរត់មិនទាន់ គេថានិយាយច្រើនណាស់ អញធុញណាស់ នេះនៅក្មេងផង បើចាស់មិនដឹងជានិយាយយ៉ាងម៉េច ។

សុវណ្ណៈ ទៅគ្នាប៉ុន្មាននាក់កាលហ្នឹងមីង?

ភាពៈ ទៅបួននាក់ ។

សុវណ្ណៈ ស្រីទាំងអស់?

ភាពៈ ចាស!ស្រីបីនាក់ ។

សុវណ្ណៈ ចឹងពីណាអ្នកបើកឡានប្រុស?

ភាពៈ អ្នកបើកឡានប្រុស ។

សុវណ្ណៈ ប្រុសហ្នឹងនៅខាងណាវិញ?

ភាពៈ ប្រុសនៅជាមួយគ្នាហឹង ។

សុវណ្ណៈ	បីនាក់ហ្នឹងទៅធ្វើកន្លែងជាមួយគ្នាឬទៅធ្វើកន្លែងខុសគ្នា?

ភាពៈ	អត់មានខុសគ្នាទេ ទៅនៅជាមួយគ្នាហ្នឹង នៅបីបួនថ្ងៃចង់មកវិញមក បើបានទៅមកៗ បានអត់លុយបានជិនាន់នោះយើងឡើងជិះ មានពិបាកអស់លុយអីមួយរៀលចង់ឡើងៗ ឡើងមក ចង់ទៅៗ ។

សុវណ្ណៈ	យើងជិះតាមផ្លូវជាតិរាល់ដងហ្នឹងមីង?

ភាពៈ	ចាស ។

សុវណ្ណៈ	ផ្លូវកាលហ្នឹងបិបាកឬមួយយ៉ាងម៉េចដែរ?

ភាពៈ	ផ្លូវជាតិលេខ១២ចេញពីព្រះវិហារទៅ ទៅដល់កំពង់ធំភ្នំពេញអី អត់មានពិបាកទេ ផ្លូវអត់សូវមានខូចទេ កាលហ្នឹង ផ្លូវនៅទេ ។

សុវណ្ណៈ	ចឹងផ្លូវនៅល្អទេ?

ភាពៈ	ចាស ។

សុវណ្ណៈ	ចឹងអត់មក្រឡុិចក្រឡុកទេ?

ភាពៈ	ចាស!អត់មានក្រឡុិចក្រឡុកទេ ។

សុវណ្ណៈ	ចឹងនៅពេលទៅដល់ហ្នឹង បីនាក់នៅក្នុងមន្ទីរជាមួយមីងក្នុងពេទ្យហ្នឹង?

ភាពៈ	ចាស ។

សុវណ្ណៈ	ពេលក្រោយមកទៅធ្វើការនៅពាណិជ្ជកម្មរដ្ឋ?

ភាពៈ	ចាស ។

សុវណ្ណៈ	ពីណាគេជាអ្នកគ្រប់គ្រងនៅមន្ទីរពាណិជ្ជកម្មរដ្ឋនិងមីង?

ភាពៈ	ពាណិជ្ជកម្មរដ្ឋភ្លេចអស់ហើយ ព្រោះគេផ្លាស់ផាកផ្លាស់ៗ បន្តិចឲ្យអ្នកនេះបន្តិចឲ្យអ្នកនោះ គេផ្លាស់ទៅនេះផ្លាស់ទៅនោះ អត់មានពីណានៅជាប់ទេ ។

សុវណ្ណៈ	មីងនៅជួបជំបូងទៅជួបឈ្មោះពីណាគេ អ្នកគ្រប់គ្រងនៅហ្នឹង?

ភាពៈ	ខ្ញុំធ្លាប់នៅជាមួយឈ្មោះ បងស៊ូ ។

សុវណ្ណៈ	ចឹងបងស៊ូ?

ភាពៈ	ចាស ។

សុវណ្ណៈ	ខ្ញុំធ្លាប់ឮបងស៊ូ?

ភាពៈ	នេះគាត់ធ្វើការនៅសំរោងរាល់ថ្ងៃនេះ គាត់កំបុតដៃម្ខាង ។

សុវណ្ណៈ	ឈ្មោះស៊ូ ហ្នឹងប្រុសឬស្រី?

ភាពៈ	ប្រុស កាលពីដើមគាត់ជាគ្រូបង្រៀន ។

សុវណ្ណៈ ឈ្មោះ ស៊ូ ឥឡូវនៅរស់ទេ?

ភាពៈ នៅរស់ គាត់មកលេងខ្ញុំរហូតហ្នឹង ។

សុវណ្ណៈ គាត់នៅសំរោង?

ភាពៈ គាត់នៅសំរោង ប្រពន្ធគាត់នៅប៉ៃលិន ប្រពន្ធគាត់នៅលិចហើយតែមិនដឹងជានៅត្រង់ណា គាត់សុទ្ធតែធ្វើការអន្តការហើយ ។

សុវណ្ណៈ ចឹងនៅមន្ទីរពាណិជ្ជកម្មរដ្ឋហ្នឹង ពេលហ្នឹងមឹងធ្វើអីខ្លះ?

ភាពៈ មានអី មានតែលើកឥវ៉ាន់ដាក់ឡាន ដឹកជញ្ជូនទៅឲ្យតាមសហគមន៍គេ ហើយចឹងទៅនៅធម្មតាទៅ ទៅកន្លែងវិញទៅ ។

សុវណ្ណៈ ឥវ៉ាន់ហ្នឹងមានអីខ្លះ?

ភាពៈ ឥវ៉ាន់មានខោអាវមានចានមានឆ្នាំងមានសម្ភារសព្វគ្រប់ចឹងទៅ ខោអាវម៉ុងភ្លួយស្អីៗយកមកឲ្យប្រជាជនតាមសហគមន៍អីៗ ខោអាវពួកភ្នំពេញណាស់ យកមកឲ្យតាមសហគមន៍អីចែកកុមារចែកមីងៗអីស្លៀកពាក់ គ្មានស្អីក្រៅពីរបស់អស់ហ្នឹងទេ ពួកពាណិជ្ជកម្មរដ្ឋ ។

សុវណ្ណៈ ហើយឥវ៉ាន់ទាំងអស់ហ្នឹងបានមកពីណា?

ភាពៈ យកពីភ្នំពេញមក ។

សុវណ្ណៈ ចង់និយាយថា មកពីភ្នំពេញហើយ តែខ្ញុំចង់ថាយកមកពីខាងណាមានប្រទេសចិនជំនួយឬឥឡូវនៅក្នុងក្រុងភ្នំពេញ?

ភាពៈ ឥវ៉ាន់នៅក្រុងភ្នំពេញ និយាយមួយមាត់ទៅដូចថារាល់ថ្ងៃចឹងឥវ៉ាន់ជជុះណាស់ ដូចថាសម្ភារជជុះ ។

សុវណ្ណៈ របស់ជ័យភ័ណ្ឌ?

ភាពៈ របស់ជ័យភ័ណ្ឌ ។

សុវណ្ណៈ សល់ពី លន់ នល់ មក?

ភាពៈ សល់គេដាក់នៅក្នុងផ្ទះមួយៗ ផ្ទះណាធំគេស្តុបទុកទៅ ហើយគេយកមកចែកតាម សហករណ៍ឲ្យប្រជាជនទៅ ស្លៀកពាក់សម្រាប់ធ្វើស្រែណា ចឹងទេ គ្មានរបស់អីថ្មីៗចំឡែកប៉ុន្មានទេ ប្រជាជនយើងក្រីក្រ មានពីណាសម្បូរបែបអី ខ្លះខោមានតែមួយចង្កេះស្អូរថា ផ្លូតទឹកទៅផ្លាស់ហាលស្ងួតលើកស្លៀកវិញហ្នឹង មួយជំនាន់នោះភូមិណាខ្លះៗក្រណាស់ ខ្ញុំធ្វើការនៅតំបន់ ខ្ញុំទៅភូមិខ្ញាវខ្ញុំទៅប្រជុំ ខ្ញុំឲ្យឡើងអស់រលីង ស្តាយតែសាក់កាដូមួយទៅផ្ទះវិញទៅកន្លែងវិញ ខ្ញុំយកសំពត់មកបីខោមួយ សម្រាប់ស្លៀក និយាយមកដល់ពូម្នាក់នោះគាត់យកប្តីប្រពន្ធហើយ ប្រពន្ធពោះធំ នៅក្មេងៗប្រពន្ធកំលោះក្រមុំអាយុ១៧-១៨ដល់ពេល

នេះប្រពន្ធពោះធំហើយ ស្បៀកចឹងអត់មានអាវទេ ឃើញយកតែក្រមាចងពង់ពីលើសំពត់ សំពត់និយាយពីប៉ះថ្មេប្រវែង១នេះ ហើយមានយាយម្នាក់អត់មានអាវឃើញនិយាយពី ថ្ងាយបន្តិលូនក្រាប១ ខ្ញុំទៅឃើញប្រជាជនចឹងពេក មានអីខ្ញុំឲ្យអស់រលីងក្រមែនទែន ខ្លះ យកការ៉ុងអំបិលការ៉ុងប្រកស្រូវយើងកាត់ស្បៀកធ្វើខោក៏មានដែរ ពេលមកហូបបាយពេល វាយជួងមកហូបបាយ មើលទៅខោអាវមិនគួរនាចង់មើលទេ ដូចជាមិនមែនមនុស្ស បើ យើងមានប៉ុន្មានសឹកថាឲ្យអស់ពីខ្លួន ដល់ថ្នាក់ដោះអាវពីខ្លួនឲ្យ ទុកអាវដៃខ្លីទៅផ្ទះ ទៅរៀប រាប់ប្រាប់បងប្រាប់គណៈតំបន់ថា បងអើយសហគមន៍នៅភូមិខ្វាវ វេទនាណាស់ បងជួយ ដោះស្រាយបន្ទាន់ បើមិនចឹងទេ ប្រជាជនយើងយ៉ាប់សំបើមហើយ ឯងទៅយ៉ាប់របៀប យ៉ាងម៉េច បងយ៉ាប់ស្បៀកពាក់ ហើយហូបចុកក៏សំបើមដែរ ហូប បងអើយបងឯងទៅ មួងទៅ កុំថាខ្ញុំម៉េចម៉ា ខ្ញុំអាណិតប្រជាជនណាស់ អើ ចាំពីភ្នំពេញមកចាប់ផ្ដើមបែកទៅ យកមកឲ្យនិយាយពីប្រជាជននិយាយពីអរ លើកដៃ១០ និយាយពីជូនពរយើង ដល់ចឹង ទៅភូមិមួយទៀត ក្រដូចគ្នាក្រហើយលូង់ទៀត លូង់នាំគ្នាកាប់មាន់បាននាំគ្នាអាំង អាខ្លះដុត ហើយបានត្រឹមកខ្លះអាំងខ្លះដុត បានលីងអំបិលម្ទេសបានបុករៀបហូបបាយចាប់ស្លាបព្រា មួយដាក់ពីលើបាយ មិនចេះស្លមិនដឹងជាស្លយ៉ាងម៉េចទេ ខ្ញុំថាបងឯងមិនស្ល គាត់ថាមិនដឹង ស្លយ៉ាងម៉េចទេ មីអូន ខ្ញុំថា ផ្លែត្រយូងចេកអីយកមកស្លម្ជូរទៅស្លឹកអំពិល ក្រសាំងយើង មាន បងអើយមាន់ប៉ុននេះស្ងោត្រយូងចេកឆ្ងាញ់ណាស់ អើយមិនដឹងស្លមិញទេអូន បង មិនចេះស្លទេ ចេះតែពុះស្ងោប្រលក់ប្រហុកទៅ ភូមិគេហ្នឹងមានប្រហែល១២ផ្ទះអី គេចេះ តែនៅត្រូវគ្នាគេប៉ុណ្ណឹងឯង តែនិយាយពីក្រ ឥឡូវបែបនេះហើយដឹង ខ្ញុំបែកយូរហើយខ្ញុំ បែកតាំងពីខ្ញុំនៅក្រមុំ ឥឡូវខ្ញុំបែកមករហូតទៅមិនដែលបានទៅទៀត ។

សុវណ្ណៈ មីសុំកាត់បន្ដិច បងស៊ូ និងគាត់អ្នកមកពីខាងណាវិញមីង?

ភាពៈ បងស៊ូ ។

សុវណ្ណៈ អ្នកគ្រប់គ្រងនៅខាងពាណិជ្ជកម្មរដ្ឋហ្នឹង?

ភាពៈ បងស៊ូ គាត់នៅខាងខេត្តព្រះវិហារដូចគ្នាដែរ ។

សុវណ្ណៈ ម៉េចបានដឹងថា គាត់នៅខេត្តព្រះវិហារ?

ភាពៈ ចាស!ពីដើមគាត់នៅគ្រូបង្រៀន គាត់ជាគ្រូបង្រៀនកាលពីសង្គមណាស់ ដល់ពេលចូលបដិវត្តចេះទៅក៏ គាត់ចេញពីគ្រូទៅគាត់ឈប់ ក៏គាត់នៅក្ដោបក្ដាប់កន្លែងពាណិជ្ជនៅវាងណាស់ ដល់ចឹងកាលដឹកជញ្ជូនពាណិជ្ជកម្មអីរបស់របរអីក៏ធ្លាក់នៅលើគាត់ហ្នឹងឯង គាត់អ្នកគ្រប់គ្រងចែកចាយណាស់ ចឹងអ្នកដែលធ្វើការជាមួយគាត់ចុះឡើងអីគាត់ គេស្គាល់គាត់

ភាគច្រើនណាស់ ឲ្យតែពួក១០៣គឺស្គាល់គាត់ទាំងអស់ ១០៣ពួកខាងព្រះវិហារហ្នឹងប្រវត្តិគាត់វែងណាស់ ។

សុវណ្ណៈ គាត់ជាគ្រូបង្រៀនខាងបឋមឬគ្រូបង្រៀនខាងអនុវិទ្យាល័យ?

ភាពៈ ទេ នៅស្រុកហ្នឹងមិនដល់អនុទេដឹង បឋមដឹងគ្រូ ព្រោះអីបង្រៀននៅស្រុកស្រែយើងពីដើមអស់ហើយថ្នាក់ទី៨ថ្នាក់ទី៩ ទី៩ទី៨អីគេទៅរៀនកន្លែងផ្សេង ព្រោះតំបន់តាមស្រុកពីដើមតែចូលថ្នាក់ទី៨ហើយអត់មានសាលាទេ នៅក្នុងខេត្តមួយៗអត់មានទេ ដល់បញ្ជូនទៅកំពង់ធំទៅកំពង់ចាម តែចូលថ្នាក់ទី៨ហើយនៅឆ្ងាយហើយ បងប្រុសមីងដែលស្លាប់គាត់ទៅរៀននៅកំពង់ចាមនោះ គាត់រៀនបានខ្ពស់ណាស់បង ដល់រដ្ឋប្រហារទាន់ទៅគាត់មិនបានធ្វើអីរៀនដូចប្រពន្ធលោកខៀវ សំផន នេះសុទ្ធតែបានខ្ពស់ៗហើយ រៀនសាលាឆ្ងាយៗ ។

សុវណ្ណៈ ហើយអ្នកដឹកជញ្ជូនធ្វើការជាមួយគ្នាហ្នឹងមានប៉ុន្មាននាក់មីង?

ភាពៈ ខាងដឹកជញ្ជូនពាណិជ្ជហ្នឹងនៅជុំគ្នាមានតែបីបួនប្រាំងនាក់ទេ គ្មានគ្នាច្រើនទេ ស្រីៗ ។

សុវណ្ណៈ តែអ្នកធ្វើការនៅក្នុងមន្ទីរទាំងមូលតែម្តងមានប៉ុន្មាននាក់មីងមានដឹងទេ?

ភាពៈ មានច្រើនសុទ្ធនៅផ្ទះបេះៗ មិនដែលបានរាប់ទេ ។

សុវណ្ណៈ អាចថាប្រហែលបានទេ?

ភាពៈ ប្រហែល១០ទៅ២០នាក់ដឹង មានយុទ្ធជនខ្លះនារីខ្លះ ពួកខ្ញុំចុះមកនៅតែកន្លែងស្រីៗដូចគ្នាហ្នឹងមិនដែលទៅជិតយុទ្ធជនអីទេ អ្នកណាមានប៉ុន្មានអីប៉ុន្មាន តែច្រើនយុទ្ធទេវាមក ព្រោះមានស្រីស្អាតៗ នារីស្អាតៗវាចង់មកលេងមកអី វាធ្វើជាមកដេរខោអីទៅតាមពិតចង់មកនិយាយលេង មកព្រោកប្រាជ្ញអី ។

សុវណ្ណៈ អ្នកមកធ្វើការនៅហ្នឹងភាគច្រើនមកពីខាងណាខ្លះមីង?

ភាពៈ ចំរុះ ។

សុវណ្ណៈ មានចំរុះតែម្តង?

ភាពៈ ចាស!សម្បូរកូនលាវណាស់ មានស្អាតជាងគេមួយ ឈ្មោះ សម្បត្តិ ស្អាតណាស់មីនោះយុទ្ធណាក៏ចង់ផ្លាស់មកនៅក្រុមហ្នឹងដែរ ក្រុមយ៉ាងម៉េចបើច្បាប់ទម្លាប់គេមិនទទួលមនុស្សស្រីប្រុសណា គេឲ្យនៅកន្លែងដោយឡែក បើចង់បានគេសួរតាមមេតាមកើយទៅគ្មានសិទ្ធអីមកនិយាយបេះចុះបានទេ ការនិយាយស្តីអី អ្នកណាចង់បានអ្នកណាអី ចង់និយាយគ្នាអីបានអត់មានទេ ឧទាហរណ៍ដូចក្មួយឯងចឹង ស្រីឬមួយមិត្តប្រុសនៅនោះចង់បានចង់ជួបនិយាយបេះចុះអីដើម្បីសួរចិត្តអីអត់បានទេ អត់បានសោះ តែដឹងដល់មេដឹងថាក្តៅខ្លួន

ហើយ ខ្ញុំមិនដែលត្រូវមាត់ទេ ចឹងៗមិនដែលរវល់ទេ អ្នកណាស្អាតយ៉ាងម៉េចស្អាតទៅអ្នកណាលេងខ្លួនយ៉ាងម៉េចលេងទៅ ខ្ញុំមិនដែលឈឺក្បាលហាលថ្ងៃទេ ។

សុវណ្ណៈ	ចឹងពេលដែលមីងទៅភ្នំពេញហ្នឹង មីងមានប្រមូលផលវ៉ាន់មកតាមផ្ទះមកស្តុកទុកកន្លែងមន្ទីររបស់មីងទេ?

ភាពៈ	អត់ទេ មកដល់ប្រាប់តាមភូមិគេ ក្នុងមួយភូមិចេះមានសហគមន៍គេ ប្រជាជនគេមានប៉ុន្មានឧទាហរណ៍ប្រជាជនគេមាន៣០០គ្រួសារហើយមានចំនួនមនុស្ស៥០០ចេះទៅគេផ្ញើបញ្ជីរទៅ គេឲ្យសហគមន៍នេះឲ្យប្រធានគេណាស់ បរទេះទៅដឹកផលវ៉ាន់យកមកចែកប្រជាជនគេគេមិនចេះតែនេះទេណា ក្នុងមួយភូមិមានប៉ុន្មានក្រុមប៉ុន្មានសមាគន៍អីអាហ្នឹង គេឲ្យទៅតាមគ្រប់ចំនួនហ្នឹងឯង អត់មានឲ្យនេះទេ មិនមកដល់ស្រេចចិត្តអ្នកណាចង់ទុកអានេះចង់ទុកអានោះអត់បានទេ កុំឲ្យថាពួកខ្ញុំទៅដឹកទៅជញ្ជូនទៅលើកអី ចង់រើសយកអានេះស្អាតអីស្អាតអត់បានទេ ពួកយើងអ្នកគំរូ កុំធ្វើអីលើសពីមហាជន ព្រោះយើងប្តេជ្ញាថាយើងបំរើប្រជាជន បំរើមហាជន អ៊ីលើសពីប្រជាជនគឺកុំធ្វើ ពាក្យថាបំរើប្រជាជនមួយមាត់គឺប្តេជ្ញាគ្រប់យ៉ាង មិនថាយប់ថ្ងៃទេ ប្រជាជនពឹងពាក់លើយើង ឈឺស្កាត់អីក៏ដោយយើងត្រូវផ្តល់ពត៌មាន យើងរុញត្រូវប្រានកុំឲ្យប្រជាជនគ្រោះថ្នាក់ ធ្វើអីក៏ដោយ យើងប្តេជ្ញាប្រជាជនគឺស្មោះប្រជាជន នៅជំនាន់នោះបរិសុទ្ធ ទៅណាមកណាទៅណាមានកូនក្រមុំអី ខ្លាចកូនទៅវាចេះទៅវាចុះអត់មានពិបាកទេ គេមានសីលធម៌ពិតប្រាកដណាស់ និយាយពីបរិសុទ្ធរបស់គេណាស់ មិនហ៊ាន បរិសុទ្ធណាស់នារីជំនាន់ពួកខ្ញុំនេះ ។

សុវណ្ណៈ	ចឹងពេលហ្នឹងទិដ្ឋភាពនៅក្នុងទីក្រុងភ្នំពេញយ៉ាងម៉េចដែលពេលហ្នឹងមីង?

ភាពៈ	អត់មានអីទេ ។

សុវណ្ណៈ	ស្ងាត់ឬមួយអ៊ូអរ?

ភាពៈ	មិនអ៊ូអរទេ នៅតែអ្នកធ្វើការ ។

សុវណ្ណៈ	ចឹងកាលហ្នឹងមីងថា សារក្រោយមកផ្សារថ្មីយ៉ាងម៉េចចឹងវិញ អាហ្នឹងមានន័យថាយ៉ាងម៉េចកន្លែងហ្នឹង?

ភាពៈ	ចុះទៅអត់មានឃើញមនុស្សឃើញអី តែពីដើមយើងមិនដែលឃើញ ដល់ពេលយើងទៅឃើញ ឃើញតែអ្នកធ្វើការ ដល់ចឹងវាអត់មានមនុស្សអ៊ូអរ អត់មានផលវ៉ាន់អត់មានអីវាស្ងាត់ចឹងទៅចេះតែឆ្ងល់ ចុះគេថាភ្នំពេញសប្បាយមានមនុស្សអ៊ូអរចុះយ៉ាងម៉េចបានជាស្ងាត់ម្ល៉េះ ដឹងអី អញក៏ដូចគ្នាមិនដែលបានឃើញដែរ ។

សុវណ្ណៈ	ចឹងគេមានលក់អីដែលនៅផ្សារថ្មីហ្នឹង មួយអាទិត្យលក់ម្តងឬប៉ុន្មានថ្ងៃលក់ម្តង?

ភាព:	អត់មានលក់ទេ ស្ងាត់ឈឹងតែម្តង ស្អីក៏គ្មានលក់ដែរ អត់មានលក់អីទេ ។

សុវណ្ណ:	ចឹងក្រោយមកមួយអាទិត្យគេលក់ម្តងអីមានទេ?

ភាព:	មួយអាទិត្យក៏អត់មានដែរ ។

សុវណ្ណ:	ប៉ុន្មានថ្ងៃគេលក់ម្តង?

ភាព:	មិនដែលឃើញលក់ អ្នកត្រូវការហូបចុកអីគេដឹកទៅពីអង្គភាពទៅផ្ញើនៅអង្គភាពគេហូបទៅណា មានត្រីមានសាច់មានបន្លែបង្ការអី កន្លែងយើងផ្ញើយកទៅ ដូចជាត្រីគេយកមកពីស្ទួងពីទន្លេសាប មកដល់ដាក់ក្នុងអង្គភាពគេប្រឹបៗ ពួកខាងចង្ក្រានបាយគេចាត់ចែងទៅ ត្រូវផ្ញើបង្អែមឬផ្លែឈើអី តាមភូមិគេយកមកមានខ្នុរមានដូង ដាក់មួយកន្លែងចេះទៅយើងទៅហូបចុកក៏ហូបនោះទៅ អត់មានដើរទិញឆ្អែកឆ្ងាចអីណា មានលក់អីណាអត់មានសោះ ចឹងយើងឃើញទៅថា មិនអ៊ូអរមិនសប្បាយចឹងឯង ផ្ញើក្នុងពេលសភាពការណ៍វាស្ងាត់ស្ងៀមណាស់ ចឹងមីងគ្រាន់តែដឹង វាមិនបានដឹងថាអ្នកណាមេអ្នកណាកើយអី រឿងប្រវត្តិហ្នឹងភ្លេចមែន ដឹងណាចាំដឹងអ្នកណាអីទេ ភ្លេចភាគច្រើនចាំតិច ភ្លេចច្រើន ។

សុវណ្ណ:	ចឹងកាលនៅភ្នំពេញមានដើរទៅណាទៅណីបានទេមីង?

ភាព:	អត់មានដើរបានទេ ដើរបានតែខ្ទិលដើរ ។

សុវណ្ណ:	យ៉ាងម៉េចចឹងមីង?

ភាព:	ខ្ទិលដើរ ដើរអីបើដើរស្ងាត់ៗ មានមនុស្សអីដឹងដើរយ៉ាងម៉េច បើគ្មានមនុស្សផង ខ្លះណាស់ទៅអង្គុយតាមកំពង់ផែមើលទឹកហូរអី បើកាណូតកប៉ាល់ទឹក កាណូតទូក មិនសូវមានទូកទេ ។

សុវណ្ណ:	ចឹងកប៉ាល់ខស្ស្រាប់ចេញចូលដែរ?

ភាព:	ចាស!កប៉ាល់ចេញចូល ។

សុវណ្ណ:	គេដឹកអីគេកប៉ាល់ហ្នឹង?

ភាព:	កប៉ាល់ដឹងថា ដឹកស្អីទេ កប៉ាល់ទន្លេមេគង្គ កប៉ាល់ធំៗ ដឹងថាដឹកអីកប៉ាល់គេអត់មានឈប់រហូតទៅរហូតមក មិនដឹងថាគេដឹកស្អី ។

សុវណ្ណ:	គេចេញចូលរាល់ថ្ងៃឬមួយយូរៗឃើញម្តង?

ភាព:	ទេ ខ្ញុំនៅនោះខ្ញុំចេញទៅឃើញកប៉ាល់រហូតហ្នឹងហើយនិងកាណូត ភ្ញៀវមករហូតៗហ្នឹងកាណូតភ្ញៀវ អាកាណូតពណ៌ ។

សុវណ្ណ:	ភ្ញៀវមកពីខាងណាមីងមានដឹងទេ?

ភាព: ដូនកាលពួកលាវ ដូនកាលមានចិនមានកូរ៉េ មានភ្ញៀវចិន កូរ៉េអីមានមក ឲ្យតែឃើញកាណូតពណ៌ហើយសុទ្ធកាណូតភ្ញៀវហើយ ។

សុវណ្ណៈ ពណ៌អីគេមីង?

ភាព: កាណូតគេហៅថា កាណូតរត់ឈ្នួលធម្មតា អាហ្នឹងគេមិនសូវលាបពណ៌ទេ បើកាណូតភ្ញៀវគឺមានពណ៌ ។

សុវណ្ណៈ តែពណ៌អីគេ?

ភាព: ដូនកាលមានពណ៌ក្រហម មានពណ៌លឿង សម្បូរពណ៌ស្អាតៗ ចឹងបើឃើញកាណូតមកកាណូតភ្ញៀវមកហើយ គ្រាន់តែកាណូតអត់មានប្រទ្បាំគ្នាដែរ ។

សុវណ្ណៈ ចឹងជំនាន់មីងនៅភ្នំពេញហ្នឹងគេមានកម្មវិធីជួបជុំគ្នា ហូបចុកអីមានទេ កម្មវិធីកម្សាន្តទៅមើលមើលល្ខោន?

ភាព: អត់មានទេ ជំនាន់នោះតាំងពី៧៥-៧៦មក គ្មានល្ខោនអីស្ងាត់អស់ និយាយមួយមាត់មកប្រជាជននៅទីក្រុងភ្នំពេញ ជម្លៀសទៅតាមសហករណ៍អស់ ទាំងចិនទាំងយួនទាំងគ្រូបង្រៀនទាំងនិសិត្សនិយាយមួយមាត់មកពួករស់នៅទីក្រុងគេជម្លៀសទៅជនបទ បញ្ជូនអ្នកដែលនៅជនបទឆ្ងាយៗទៅភ្នំពេញវិញចឹង ។

សុវណ្ណៈ ចឹងមីងម៉េចដឹងថា គេជម្លៀសប្រជាជនចឹង?

ភាព: មិនដឹងដែរ គេជម្លៀសមីងមិនទាន់បានទៅទេ ដល់មីងទៅគេជម្លៀសស្ងាត់អស់ហើយ ។

សុវណ្ណៈ ដល់ពេលគេជម្លៀសចេញអស់ចឹង មីងមានអារម្មណ៍យល់ឃើញយ៉ាងម៉េចដែលនៅភ្នំពេញហ្នឹង?

ភាព: មានម៉េច ផ្ទះថ្ម អូតែល ពូអ្នកលក់ដូរអីឃើញរោង ឃើញផ្ទះសំបែង ឃើញផ្លូវដើរឃើញសាលារៀនអី ទៅដល់នៅឃើញម្ចាស់មិនដឹងថាទៅណាណី ទៅដល់ណាដល់ណី ស្តាយមិនដឹងជាយំសោកយ៉ាងណាដុបម៉ែ ជុំឪ ទៅណាទៅណីគេដាក់ធ្វើស្រែធ្វើចម្ការ ខ្លះចេះធ្វើខ្លះមិនចេះធ្វើ ខ្លះកូនគេអ្នកមានគេនៅទីក្រុងសូម្បីដើមស្រូវគេមិនស្គាល់ផង ហើយយកមកដាក់ជនបទឲ្យស្ទូងឲ្យដកមិនចេះមិនអី តែបើយើងនៅទីក្រុងយើងនៅបាននៅស្រែក៏យើងនៅបានដែរ សំខាន់អ្នកទៅទីក្រុងទៅស្រែទំរាំចេះ នៅជនបទស្រុកតូចស្រុកធំចេះតែនៅទៅទៅណាទៅណី ផ្ទះឡើងឈឹងៗ ម្ចាស់ឡើងសោកសៅនឹកឃើញទៅអាណិតម្ចាស់មិនដឹងជាទៅដល់ណាដល់ណី ឃើញតែផ្ទះឡើងស្ងាត់ឈឹង ។

សុវណ្ណៈ ចឹងពេលអារម្មណ៍មីងទៅដំបូងមីងគិតថា ភ្នំពេញយ៉ាងម៉េចដែរ ទៅដំបូងមិនទាន់ដឹងគិតថាសប្បាយទៅដល់?

ភាព៖ គិតថាសប្បាយខ្លាំងហើយ ផ្ទះគេឬក៏មានភ្លើងពណ៌អីសព្វបែបសព្វយ៉ាងបានឃើញទីក្រុងភ្នំពេញ ថាម្ដងនេះបានឃើញហើយ ស្រាប់តែទៅអញលែងចង់ទៅហើយ ស្ងាត់គ្មានមនុស្សអីមានតែគ្នាឯង តែយើងបានឃើញទន្លេបានឃើញកំពង់ផែអី ពីដើមមិនគេសប្បាយយ៉ាងណា ។

សុវណ្ណៈ ចឹងមីងមានបានទៅណាទៀតទេ ក្រៅពីកន្លែងទាំងអស់នោះ?

ភាព៖ តាំងពីនោះមកខ្ញុំមិនដែលបានទៅណាទេ ខ្ញុំខ្ជិលខ្ញុំដល់ចឹងខ្ញុំយកគ្រួសារ ។

សុវណ្ណៈ ចឹងមីងសុំកាត់បន្តិច មីងគេមានហៅទៅប្រជុំបុណ្យខួបបក្សអីទេ មានទេ?

ភាព៖ អត់ទេ!ខ្ញុំមិនដែលទៅទេ ។

សុវណ្ណៈ អត់មានទៅចូលរួមជាមួយគេដែរ?

ភាព៖ ខ្ញុំមិនដែលទៅទេ ។

សុវណ្ណៈ ចឹងមានទៅទទួលគណៈធិបតេយ្យគេមកតាមព្រលានយន្តហោះអី មីងមានបានទៅទទួលឈរអមអីមានទេ?

ភាព៖ អត់ទេ អត់ដែលទៅទេ ។

សុវណ្ណៈ អត់ទៅទទួលហ្នឹងគេដែរ?

ភាព៖ ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងមានដឹងថាប្រជុំបក្សអី កាលហ្នឹងមីងមានដឹងទេ?

ភាព៖ គេប្រជុំតែមេៗពួកអ្នកសំខាន់ៗ ដល់ចឹងយើងអ្នកនេះគេមានឲ្យដឹងណា ក្មួយអើយគេមានផ្ទៃក្នុងផ្ទៃក្រៅគេ ។

សុវណ្ណៈ គេមានខួបបក្សគេប្រជុំធំនៅស្តាតអីណា មានចូលរួមអីអត់ទេ បុណ្យខួបអី?

ភាព៖ អត់ទេ ។

សុវណ្ណៈ ចុះពេលទទួលគណៈប្រតិភូគេមកម្តងៗមានទៅទទួលនិងគេដែលអត់?

ភាព៖ អត់ ។

សុវណ្ណៈ ចឹងមីងមានដឹងថាគេមានមកទេ?

ភាព៖ អត់ដឹង បើមិនដែលបានទៅ បើតំបន់ខ្លួនឯងបានដឹង ដឹងថាជួបគ្នាឯងណាស់ អាហ្នឹងគេហៅមេទិញ កាលជំនាន់ហ្នឹងគេហៅមេទិញ ទទួលបងនេះបងនោះគណៈភូមិភាគមកពីនេះមកពីនោះអី អាហ្នឹងបើនៅតំបន់ឯងមាន មានធ្វើពីជប់លៀងកាប់ជ្រូកអីទទួលណាស់ តែបើភ្នំពេញនេះអត់មានទេ ។

សុវណ្ណៈ ចឹងអត់មានបានចូលរួមនៅណាដែរ?

ភាពៈ អត់ដែលទៅទេ គ្រាន់ទៅឃើញស្គាល់ចឹងឯង មិនបានទៅដប់លៀងទៅទទួលអី ។

សុវណ្ណៈ ចឹងគេមានផ្លាស់មីងទៅធ្វើខាងណាទៀតទេ?

ភាពៈ អត់ទេ ។

សុវណ្ណៈ ចឹងនៅធ្វើតែមន្ទីរពាណិជ្ជកម្មរដ្ឋនិងទៅ?

ភាពៈ ចាស! នៅធ្វើពាណិជ្ជកម្មរដ្ឋហើយដល់ពេលចឹង ខ្ញុំយកគ្រួសារទៅខ្ញុំឈប់ ឈប់ទាំងអស់ ។

សុវណ្ណៈ ចឹងនៅមន្ទីរពាណិជ្ជកម្មរដ្ឋហ្នឹងគេមានហៅឈ្មោះ លេខអីទៀតទេ?

ភាពៈ អត់ទេ ។

សុវណ្ណៈ មាន"ក១មាន៧០ប៉ុន្មានលេខប៉ុន្មានអីទេ?

ភាពៈ អត់ទេ ។

សុវណ្ណៈ អត់មានទេ?

ភាពៈ ចាស! គេហៅតែពាណិជ្ជៗហ្នឹង ។

សុវណ្ណៈ ចឹងហៅតែពាណិជ្ជកម្មរដ្ឋទៅ?

ភាពៈ ចាស! ហៅពាណិជ្ជប៉ុណ្ណោះឯង អត់មានពាណិជ្ជកម្មទេ ភាគច្រើនគេប្រើពាក្យថា ពាណិជ្ជ ។

សុវណ្ណៈ ចឹងមានថ្នាក់ធំលើៗគេមានមកចូលមើលនៅកន្លែងមីងទេ ដូចជាប៉ុល ពត ដូចជាខៀវសំផន អី នួន ជាអី មីងស្គាល់ទេ?

ភាពៈ ពួកខ្ញុំនៅពីមុនមិនដែលឮឈ្មោះ ប៉ុល ពត ទេ ខាងតំបន់ខ្ញុំមិនដែលឮឈ្មោះ ខ្ញុំមកឮឈ្មោះប៉ុល ពត ហ្នឹង ពេលខ្ញុំឡើងភ្នំហើយទេ បើកាលពីមុនអត់ស្គាល់ទេ បើលោកខៀវសំផន ខ្ញុំស្គាល់ ខ្ញុំស្គាល់តាំងពីគាត់មិនទាន់យកបងស្រី ខ្ញុំស្គាល់គាត់តាំងពីនៅកំលោះ បានជាខ្ញុំស្គាល់ កាលមុនខ្ញុំនៅជាមួយប្រពន្ធគាត់ ប្រពន្ធគាត់កាលមុនជាប្រធានក្រុមពួកខ្ញុំប្រធានក្រុមយើងធម្មតា ។

សុវណ្ណៈ ប្រពន្ធគាត់ឈ្មោះអីគេមីង?

ភាពៈ ប្រពន្ធគាត់កាលពីដើមឈ្មោះ រិន ។

សុវណ្ណៈ ស្អីគេ រិន?

ភាពៈ ឈ្មោះ អីទេ ឈឹម រិន ដឹង តាគាត់ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែឪគាត់ ឪគាត់ឈ្មោះ ឈឹម តែមិនដឹងតាឈ្មោះ អី ។

សុវណ្ណៈ ហើយប្រពន្ធគាត់អ្នកស្រុកណា?

ភាពៈ ប្រពន្ធគាត់អ្នកនៅរវៀង ចឹងខ្ញុំនៅស្នាក់អាស្រ័យទីហ្នឹងផ្ទះបងរិន ហ្នឹងឯងហើយទៅណាទៅណីបងរិន បបួលខ្ញុំជាប់ ដល់ចូលចឹងទៅធ្វើប្រធានក្រុមពួកខ្ញុំ ដល់ពេលនេះលោកខៀវ

សំផន មកចេះទៅគាត់ឃើញ គាត់ឃើញគាត់ចង់បាន ចឹងគេឲ្យបងរិន ទៅរៀននៅភូមិភាគ ដល់ចឹងទៅលោកខៀវ សំផន ដណ្តឹងយកទៅ ។

សុវណ្ណៈ ចឹងគាត់ការឆ្នាំណាកាលហ្នឹង?

ភាពៈ បងគាត់ការឆ្នាំ១៩៧៤ដឹង ៧៤ហ្នឹង ។

សុវណ្ណៈ ពេលតស៊ូ?

ភាពៈ ចាស!គាត់ទៅពី៧៤ ទៅបែកពីពួកខ្ញុំទៅ ទៅឆ្នាំ៧៤ គាត់ប្រកែកថាមិនយកផង បងរិនគាត់ថាមិនយកទេ ប្តីអ្នកធំពេក គាត់មិនចង់បានទេ ។

សុវណ្ណៈ គាត់ថាយ៉ាងម៉េច?

ភាពៈ ឪពុកម្តាយ ចឹងលោកខៀវ សំផន ថាគាត់ជ្រើសរើសយកកូនអ្នកកសិករសុទ្ធសាធ កូននាយទុន កូនអ្នកសក្តិភូមិគាត់មិនយកទេ បើកូនកសិករសុទ្ធសាធគាត់យក គាត់យកគាត់មកមើលផ្ទះ មកមើលផ្ទះគាត់ថាកសិករកណ្តាលដែរ គាត់មានដីមានផ្ទះមានអីត្រឹមត្រូវកូនគាត់សុទ្ធតែអ្នកកណ្តាលទាំងអស់ ដល់ចឹងបងរិន គាត់ថាពុកម៉ែថាឲ្យយកគាត់យកទៅ ខ្ញុំថាបងយកទៅគ្រាន់ខ្ញុំបានទៅលេងភ្នំពេញអីផង ខ្ញុំចេះតែរុញ គាត់ថាចេះតែឲ្យអញយកអញខ្លាចណាស់ តានោះ ខ្ញុំថាបងឯងម៉េចបានខ្លាច គាត់ថាបើពាក់វ៉ែនតាមិនដែលបើកសោះ មិនដែលបើកវ៉ែនតាទេ កាលនោះលោកខៀវ សំផន គាត់ពាក់វ៉ែនតាឡើងខ្មុបៗ ។

សុវណ្ណៈ វ៉ែនតាអីគេមីង វ៉ែនតាខ្មៅ?

ភាពៈ វ៉ែនតាខ្មៅ យើងមើលគាត់មិនច្បាស់ គាត់ស្រឡាញ់ពីរនាក់កាលនោះ ម្នាក់ទៀតស្អាតជាងប្រពន្ធគាត់ទៀត គេនៅក្មេងជាង ដល់ចឹងគាត់សុខចិត្តយកបងរិន ចុះគាត់អត់យកមីសុវណ្ណ សុវណ្ណ ស្អាតណាស់ គាត់ចង់បានដែលតែគាត់មិនយក បានគាត់យកបងរិន បងរិន កាលពីដើមគាត់ឈ្មោះ រឿន ឈ្មោះនៅម៉ែឪគាត់នៅកូនសិស្សពីដើម ពេលគាត់យកខៀវ សំផន គាត់ប្រែឈ្មោះ រិន ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងជួបគាត់នៅក្មេងចឹង គាត់អាយុប្រហែលជាប៉ុន្មានហើយ អ៊ំខៀវ សំផន ហ្នឹង?

ភាពៈ កាលហ្នឹងអាយុ៣៥ ហើយដឹងឬក៏៤០ ហើយដឹង បើគេអ្នកធំគេអ្នកធ្វើការចុះសាច់គាត់នៅហាំដែលតាហ្នឹង តែក្បាលគាត់ឆក គេអ្នកធ្វើការមានលំបាកអី សាច់គេនៅរលោងហ្នឹង ។

សុវណ្ណៈ រាងរៅគាត់យ៉ាងម៉េចដែរ?

ភាពៈ រាងគាត់មិនជាមាំប៉ុន្មានទេ ហើយក៏មិនមាឌធំបងប៉ុន្មានដែរ គាត់ម៉ាសមម៉ាស្អាត តានោះគាត់ស្អាត តែគាត់ស្អាតមិនដល់អ៊ំ នួន ជា ទេ ក្នុងហ្នឹងទាំងអស់អ៊ំនួន ជា ស្អាតជាងគេ ។

សុវណ្ណៈ ហើយសំដីសំដៅគាត់យ៉ាងម៉េចដែលមីង?

ភាពៈ គាត់និយាយស្ដី គាត់និយាយមួយៗដែរ មិនសូវនិយាយច្រើនទេ និយាយមួយៗសួរម៉ាត់ៗហើយៗ គាត់អត់មាននិយាយព្រោកប្រាជ្ញអីដូចយើងធម្មតាទេ ។

សុវណ្ណៈ ចុះចរិកពុកពាររបស់គាត់?

ភាពៈ ពុកពាររបស់គាត់បើគាត់មកតែមួយភ្លែតៗ គាត់ជិះឡានមក មកព្រោកប្រាជ្ញប្រហែលជាពីរម៉ោងទៅវិញហើយ បងប្អូនព្រោកប្រាជ្ញចាស់ទុំអីដល់ម៉ោងឡើងឡានទៅវិញហើយ ។

សុវណ្ណៈ កាលហ្នឹងគាត់នៅខាងណាមីង?

ភាពៈ កាលហ្នឹងគាត់នៅភ្នំពេញដឹង តែគាត់មកនេះ អត់មានសម្រាកផង មិនដែលដេកទេ ។

សុវណ្ណៈ គាត់មកនេះធ្វើអី?

ភាពៈ មកជួបប្រពន្ធគាត់ហ្នឹងណា ។

សុវណ្ណៈ ចឹងកាលពីគាត់មិនទាន់ការ គាត់មកធ្វើអីកាលហ្នឹង?

ភាពៈ ទេ មិនដឹងជាគាត់មកធ្វើអី គាត់តាមរយៈគ្នាគាត់ដឹង គាត់មកគាត់ឃើញ គាត់មកមួយភ្លែតៗគាត់ឃើញ បែបសួរតាមរយៈប្រធានៗបែបគេប្រាប់ ។

សុវណ្ណៈ អាចថាគាត់មកឃោសនាអីទេ កាលហ្នឹងមីង?

ភាពៈ អត់ទេ គាត់មិនដែលចេញមុខ មានពីណាស្គាល់ទេ មិនដែលនិយាយអីទេ បើគាត់មកមុនកិច្ចការអីគាត់ទៅវិញហើយ មានពីណាស្គាល់ទេ សូម្បីតែបងប្អូនខាងប្រពន្ធគាត់មិនសូវពីណាស្គាល់គាត់អស់ គាត់មិនដែលមកឃោសនាទេ ព្រោះតំបន់គេយើងមិនអាចមកជ្រែតជ្រែកទេ គ្រាន់តែគេមកមួយឆាបៗដល់ហើយគេទៅវិញ គាត់មិនដែលដេកអីទេ ។

សុវណ្ណៈ មីងការកាលហ្នឹងឆ្នាំប៉ុន្មានមីង ការគ្រួសារដំបូង?

ភាពៈ ពីណា ។

សុវណ្ណៈ មីងនៅភ្នំពេញហ្នឹង មីងការគ្រួសារនៅភ្នំពេញ?

ភាពៈ ទេ ខ្ញុំការនៅតំបន់នេះទេ ការនៅស្រុកនេះទេ ។

សុវណ្ណៈ ចឹងត្រឡប់មកនេះវិញឆ្នាំណា?

ភាពៈ ខ្ញុំមកនេះវិញ ។

សុវណ្ណៈ គេវាយបែកភ្នំពេញ?

ភាពៈ ចាស ។

សុវណ្ណៈ	បានមកវិញ?

ភាពៈ	ចាស!ទេ ពេលគេបែកភ្នំពេញបានខ្ញុំទៅ ។

សុវណ្ណៈ	ខ្ញុំចង់និយាយថា ទាហានវៀតណាមវាយបែកភ្នំពេញឆ្នាំ៧៩ បានមីងត្រឡប់មកវិញឬមុនគេវាយបែក?

ភាពៈ	អូ១!បើនិយាយពីឆ្នាំ៧៩នោះ មីងទើបឡើងភ្នំ ខ្ញុំនិយាយពី៧៣-៧៤-៧៥ទេ ។

សុវណ្ណៈ	ចឹងកុំអាលមីង មីងទៅភ្នំពេញឆ្នាំ៧៦ត្រូវទេ?

ភាពៈ	ចាស!ឆ្នាំ៧៦ ឆ្នាំ៧៥មិនគេរំដោះភ្នំពេញ ។

សុវណ្ណៈ	បាទ ។

ភាពៈ	ដល់៧៦ទៅថាអង្គការរៀបរយជម្លៀសប្រជាជនចេញទៅ ទៅចូលទៅអង្គភាពផ្សេងៗទៅប្រមូលជ័យភ័ណ្ឌចែកឲ្យប្រជាជនតាមសហគមន៍តាំងពី៧៦នោះ ។

សុវណ្ណៈ	ចឹងមីងក្រៅពីធ្វើការនៅមន្ទីរពាណិជ្ជហ្នឹងមានដែលទៅប្រមូលរបស់របរតាមផ្ទះអីយកមកដាក់នៅមន្ទីរទេ?

ភាពៈ	អត់ទេ ក្នុងមន្ទីរគ្មានស្អីទេ យកមកគេចែកសហគមន៍ព្រោងព្រាតអស់ហើយអត់មានស្តុបទុកទេ ។

សុវណ្ណៈ	ចឹងក្រៅពីហ្នឹងមីងធ្វើអីទៀត ក្រៅពីធ្វើការនៅមន្ទីរហ្នឹង?

ភាពៈ	ធ្វើការនៅមន្ទីរហើយ ក្រៅពីនោះខ្ញុំឈប់ ។

សុវណ្ណៈ	មីងឈប់កាលហ្នឹងនៅឆ្នាំណា?

ភាពៈ	ខ្ញុំឈប់ឆ្នាំ៧៧ ។

សុវណ្ណៈ	មូលហេតុអីបានឈប់មីង?

ភាពៈ	ឈប់ខ្ជិលដើរចុះឡើង ខ្ញុំនឹកឃើញបងប្អូនកំព្រាតូចៗផង ខ្ញុំនៅអង្គភាពធម្មតា ខ្ញុំនៅអង្គភាពសាធារណការ កន្លែងអារឈើ កន្លែងដឹកឈើ ខ្ញុំនៅកន្លែងសាធារណការ ។

សុវណ្ណៈ	ចឹងមីងឈប់ទៅខាងសាធារណការវិញ?

ភាពៈ	ចាស!ខ្ញុំទៅនៅខាងសាធារណការវិញ កន្លែងធ្វើសំណង់ធ្វើអីៗ ។

សុវណ្ណៈ	សាធារណការហ្នឹងធ្វើអីគេកាលហ្នឹង?

ភាពៈ	អត់មានធ្វើអីទេ សាធារណការគ្រាន់តែនៅដាំបន្លែ មើលកូនក្មេង អ្នកមានកូនតូចៗហ្នឹងដល់ចឹងខ្ញុំមើលកូនឲ្យគេទៅ ដល់ពេលដាក់វេនគ្នា ដល់ចឹងខ្ញុំមើលកូនឲ្យគេ ម៉ែគេទៅធ្វើនេះធ្វើនោះទៅហើយដាំបន្លែ បម្រើអង្គភាពណាស់ ។

សុវណ្ណៈ	កន្លែងសាធារណការហ្នឹងគេធ្វើអីគេ?

ភាពៈ មើលកន្លែងសាធារណការ មានកន្លែងរោងចក្រអារឈើ មួយផ្នែកខាងរោងចក្រអារឈើ មួយផ្នែកនោះខាងកន្លែងចាក់ផ្សាំង ចាក់ស្លាបព្រា មួយផ្នែកទៀតនោះខាងដើរធ្វើផ្ទះ ធ្វើមន្ទីរធំៗ ធ្វើមន្ទីរពេទ្យ ធ្វើផ្ទះឲ្យអគ្គភាព ធ្វើឲ្យមន្ទីរពេទ្យ ធ្វើសាលារៀនអីណាស់ អាហ្នឹងគេមានពីរបីផ្នែក ចឹងយើងស្រីៗមិនសូវមានទេ មានតិចយើងសម្រាប់តែធ្វើបាយគ្រប់កន្លែងដែលនៅ កន្លែងនៅមានគ្នា៨០០នាក់ អ្នកដាំបាយមានពី៣០ទៅ៤០នាក់នោះបានធ្វើទាន់ ដល់ចឹងខ្ញុំនៅតែកន្លែងដាំបាយហើយមើលកូនឲ្យគេហើយដាំបន្លែដាំអី ដល់ចឹងឆ្នាំ៧៨ ខ្ញុំយកគ្រួសារទៅ ។

សុវណ្ណៈ សាធារណការហ្នឹងនៅម្តុំណាមីង?

ភាពៈ នៅនេះនៅរវៀង ។

សុវណ្ណៈ ចឹងមីងត្រឡប់មករវៀងវិញទេ?

ភាពៈ ចាស!ត្រឡប់មករវៀងវិញ ។

សុវណ្ណៈ ឆ្នាំ៧៧ហ្នឹង?

ភាពៈ ចាស!ខ្ញុំមិនចេះទៅស្រុកគេទេ ។

សុវណ្ណៈ ចឹងនៅស្រុករវៀងទីរួមខេត្តកាលហ្នឹង?

ភាពៈ ទីរួមខេត្តគេនៅនេះទេ ទីរួមខេត្តគេនៅខាងកំពង់តាណាតនេះទេ ខាងខេត្តព្រះវិហារយើងថ្មីនេះទេ រវៀងហ្នឹងទីរួមស្រុកតើ ។

សុវណ្ណៈ ចឹងមានមូលហេតុអីបានជាត្រឡប់មកវិញមីង?

ភាពៈ ខ្ញុំខ្ជិលដើរចុះឡើងពេក ខ្ញុំនឹកឃើញប្អូនដែលនៅផ្ទះនេះ ។

សុវណ្ណៈ ដល់ពេលប្រាប់ចឹងគេថាយ៉ាងម៉េច?

ភាពៈ គេមានថាម៉េច គេអត់មានថាម៉េចទេ នៅក៏នៅទៅមានស្អី ដល់ចឹងខ្ញុំមកនៅសាធារណការហើយក៏ឲ្យប្អូនខ្ញុំទៅលេងទៅកុំឲ្យពិបាក ខ្ញុំនៅឆ្ងាយប្អូនខ្ញុំវាពិបាកទៅ វាបិបាកមកវាតូចៗ ដល់ចឹងខ្ញុំនៅនេះ នៅៗរហូតដល់ឆ្នាំ៧៨ខ្ញុំយកប្តី គេរៀបចំឲ្យខ្ញុំយកដល់យកទៅឆ្នាំ៧៩ក៏រត់បែកគ្នាទៅ ។

សុវណ្ណៈ ចឹងមីងកុំអាល សាធារណការហ្នឹងមានគេហៅឈ្មោះអីផ្សេងទៀតទេ លេខរាងលេខអីមានដែលអត់?

ភាពៈ អត់មានទេ មានតែកន្លែងសាធារណការ ។

សុវណ្ណៈ គេហៅមន្ទីរសាធារណការឬមួយគេហៅអីគេ?

ភាពៈ គេហៅមន្ទីរសាធារណការតែម្តង សាធារណការ១០៣ចឹងតែម្តង ។

សុវណ្ណៈ	នៅខាង១០៣មីង?

ភាពៈ	ចាស!សាធារណការ១០៣តែម្តង ។

សុវណ្ណៈ	ហើយកន្លែងហ្នឹងពីណាគេជាអ្នកគ្រប់គ្រង សាធារណការហ្នឹង?

ភាពៈ	កន្លែងនោះឈ្មោះ បងលន់ គាត់នៅគ្រប់គ្រង ។

សុវណ្ណៈ	គាត់អ្នកនៅរវៀងហ្នឹងដែលទេ?

ភាពៈ	ចាស!នៅនោះដែរ ។

សុវណ្ណៈ	ស្រីឬប្រុសមីង?

ភាពៈ	ប្រុស ។

សុវណ្ណៈ	ហើយនៅកន្លែងហ្នឹងមានអ្នកធ្វើការមានគ្នាប៉ុន្មាននាក់ដែរ?

ភាពៈ	មានច្រើនណាស់ បន្ទាប់ឲ្យអ្នកមានគ្រួសារក្នុងមួយផ្ទះចេះមាន៣០បន្ទប់ហើយមានមួយបន្ទប់ៗៗបន្ទប់បង់លេខស្រាប់លេខ១ដល់លេខ៣០ ខ្ញុំនៅបន្ទប់លេខ២៩ បន្ទប់គេមានកន្លែងដាំបាយមានកន្លែងធ្វើអី បន្ទប់ដូចផ្ទះជួលគេចឹងណា ។

សុវណ្ណៈ	ចឹងនៅទីរួមស្រុកទេ មន្ទីរសាធារណការហ្នឹង?

ភាពៈ	ចាស ។

សុវណ្ណៈ	ចឹងនៅស្រុករវៀង?

ភាពៈ	ស្រុករវៀង ហើយគេធ្វើផ្ទះល្វែងនោះ ដល់ចឹងគេដាក់តាមគ្រួសារមួយបន្ទប់ៗបន្ទប់ធំៗវែងៗនៅម្យ៉ាងរបស់គេទៅ ហើយមានរោងចក្រអារឈើនៅខាងមុខ ។

សុវណ្ណៈ	ចឹងមីងសូមបកនៅភ្នំពេញវិញ កាលហ្នឹងការហូបចុកអីយ៉ាងម៉េចដែលពេលហ្នឹង លំបាកក៏មិនសូវលំបាកទេ?

ភាពៈ	អត់មានលំបាកទេ ។

សុវណ្ណៈ	ចឹងហូបមួយថ្ងៃប៉ុន្មានពេលដែរ?

ភាពៈ	ហូបបាយអន្តភាពគេ ពេលម៉ោងប៉ុននេះគេហូបបាយហើយ បាយហូបធម្មតា តែខ្ញុំវាមិនសូវចេះនៅ ឃើញច្រើនតែហូបឆាហូបខហូបស្ងោៗគាពាសខ្ញុំអត់ចូលចិត្ត ចឹងបានខ្ញុំនៅមិនបានយូរ ខ្ញុំចូលចិត្តតែកប់កូនត្រី ឬស្លម្ជូរប្រលិតត្រកួនអីឬគ្រប់អីខ្ញុំចូលចិត្ត ចូលចិត្តបន្លែស្រែៗ ទៅដល់គេសម្ងួតរាល់ថ្ងៃអើយ ខ្ញុំមិនចេះនៅទេ ខ្ញុំនៅយូរខ្ញុំឈឺហើយខ្ញុំហូបបាយមិនដែលឆ្អែតទេ មិនដឹងថាជាយ៉ាងម៉េច សម្ល៉ាកនេះខ្ញុំឆាប់ហើយ ហើយបើយើងនៅហ្នឹងយើងហូបតាមចិត្ត យើងធ្វើអីរបៀបស្រែយើងត្រី ចង់អាំង ចង់ជាន ចង់ដុត ចង់ម្ជូរស្ងោយ៉ាងណាក៏បាន បើនៅនោះ យើងធ្វើនេះយ៉ាងម៉េចបើអន្តភាពគេតម្រូវរួមច្រើន

អ្នកណាទៅតម្រូវបុគ្គលយើងម្នាក់ ចឹងមិនខុសគេទេ ខុសពីយើង យើងស៊ីមិនដូចគេ ខ្ញុំមិនចេះនៅយូរទេ ទីក្រុងខ្ញុំប្រាប់ក្មួយឯងត្រង់ចេះ អឹមិនសូវចេះទេ ហូបផ្សារអី ៗ

សុវណ្ណៈ តែម្ហូបគេអត់មានខ្វះខាតទេ ហូបចុកអីហូបបីពេល?

ភាពៈ ចាស ៗ

សុវណ្ណៈ គេហូបម៉ោងប៉ុន្មានខ្លះ?

ភាពៈ ប្រលឹមឡើងនំប៉័ង នំប៉័ងអាបួនជ្រុង មាននំប៉័ងគេសម្ងការីអី ខ្ញុំបាននំប៉័ងហើយរកស្ករ បើមិនស្ករទឹកដោះគោ មិនចេះជ្រលក់សម្ងការីអីទេ ហើយដល់ពេលថ្ងៃត្រង់បាយ ល្ងាចក៏បាយ ហើយសម្លគេដូចសម្លផ្សារគេលក់ចឹង គេធ្វើឆ្ងាញ់ៗតែខ្ញុំវាមិនសូវចេះ ចឹងបានជាខ្ញុំនៅមិនបានយូរ ចឹងបានថាទីក្រុងភ្នំពេញ បើថាឲ្យទៅលេងទៅបានបើថាឲ្យទៅរបស់អីឆ្ងាញ់ដើម្បីជិតនៅក្នុងចិត្តអនុស្សាវរីយ៍អីគ្មានទេ អញរឿងភ្នំពេញមិនចង់ទៅទេ ៗ

សុវណ្ណៈ យើងធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាននៅភ្នំពេញហ្នឹង?

ភាពៈ មានធ្វើការអីផង លើកឥវ៉ាន់ដាក់ឡានហើយនៅធម្មតា ៗ

សុវណ្ណៈ ចាប់ផ្ដើមការម៉ោងប៉ុន្មានចប់ម៉ោងប៉ុន្មានអី?

ភាពៈ ជួនកាលឲ្យតែឡានត្រូវការម៉ោងប៉ុន្មានក៏ធ្វើដែរ ឲ្យឡានទៅដល់លើកដាក់ហើយក៏ចប់តែម្ដងកាលនោះ ៗ

សុវណ្ណៈ ចុះយើងប្រជុំអី មួយអាទិត្យប្រជុំម្ដងឬមួយខែប្រជុំម្ដង?

ភាពៈ គេប្រជុំគ្រាន់ថា យើងធ្វើការផាវអីកុំខ្ជីខ្ជារថែរបស់របរួមកុំប៉ះពាល់ត្រូវការឡានទៅដឹកអីត្រូវរួសរាន់ឲ្យទាន់ពេលវេលា ដើម្បីគេដឹកទៅចែកតាមសហគមន៍អី កុំឲ្យខុសកាលកំណត់របស់អង្គការ ហើយឃើញឡានមកអីសំខាន់ សង្កត់មែនទែនគឺការស្មោះត្រង់ ឲ្យត្រង់ជាមួយអង្គការ ឃើញមាសឃើញប្រាក់អីក៏ដោយកុំឲ្យសោះ តិចឃើញខ្សែក ឃើញជញ្ជៀនអីយកដាក់ខោប៉ៅខោមិនបានទេ ឃើញមីងនៅភ្នំពេញ មីងនៅរហូតដល់ណាណីមួយជិនាន់មីង មីងនៅរហូតដល់សព្វថ្ងៃហ្នឹងមីង មីងត្រង់ណាស់ បើសុំគឺសុំ តែបើលួចហាមក្នុងចិត្តថាហាមរបស់គេគឺមិនប៉ះពាល់ ដល់ចឹងអង្គការទោះបីជាយ៉ាងណាក៏ដោយមនុស្សត្រង់គឺស្រឡាញ់ណាស់ ស្រឡាញ់តែស្មោះត្រង់ យើងត្រង់ចំពោះទ្រព្យសម្បត្តិគេដែលវាសំខាន់ណាស់ ៗ

សុវណ្ណៈ ចឹងពេលត្រឡប់មកស្រុករៀងវិញ យើងធ្វើការយ៉ាងម៉េចដែលពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានអី?

ភាពៈ ខ្ញុំធ្វើការពីម៉ោង៧ដល់ម៉ោង១១ ចាប់ពីម៉ោង១រហូតដល់ម៉ោង៤កន្លះ ម៉ោង៥ហូបបាយហើយ ។

សុវណ្ណៈ ចឹងហូបចុកមានខ្វះខាតទេ?

ភាពៈ ហូបចុកមិនដែលខ្វះទេ ព្រោះឡានដឹកត្រីមកពីទន្លេ ។

សុវណ្ណៈ យើងហូបបាយឬមួយហូបបបរមីង?

ភាពៈ ហូបបាយ ។

សុវណ្ណៈ មួយថ្ងៃប៉ុន្មានពេល?

ភាពៈ មួយថ្ងៃពីរពេល ។

សុវណ្ណៈ ព្រឹក ថ្ងៃត្រង់?

ភាពៈ ព្រឹកធ្វើការដល់ម៉ោងថ្ងៃត្រង់ហូបបាយ ល្ងាចហូបបាយ ដល់ពេលថ្ងៃអាទិត្យបេះទៅគេធ្វើបន្លែមម្ដង មានតាំងពីកន្លែងចិញ្ចឹមជ្រូកដាក់មួយក្រោលពីបេះទៅ ដូចថាមួយខែបេះជប់លៀងកម្មករគេម្ដងណា ជប់លៀងម្ដងកាប់ជ្រូក២០ទៅ៣០អីនោះ ជ្រូកគេប៉ុននេះៗហើយចិញ្ចឹមជ្រូកហ្នឹងមានគ្នា៦នាក់ មានអ្នកចិញ្ចឹមជ្រូក មានអ្នកដាំបន្លែ មានអ្នកដាំបាយមានអ្នកមើលក្មេងទាំងអស់ ។

សុវណ្ណៈ ចឹងហូបចុកអត់មានជួបការខ្វះខាតអីទេ?

ភាពៈ ចាស!អត្តភាពខ្ញុំមិនសូវខ្វះខាតទេ ។

សុវណ្ណៈ ចឹងមិនសូវមានបញ្ហារឿងហូបចុកអីដែរ?

ភាពៈ ចាស!មិនសូវមានបញ្ហាអីទេ តែអ្នកខ្លះគេថា បងឯងនៅចំកន្លែងស្រួល ចឹងពួកខ្ញុំជួបការលំបាកណាស់ ខ្ញុំថាមិនដឹងជាយ៉ាងម៉េចទេ អត្តភាពខុសគ្នា តែខ្ញុំតាំងពីចូលមកខ្ញុំមិនសូវមានការលំបាកអីប៉ុន្មានទេ ខ្ញុំនៅជំនាន់យើងនៅក្នុងដីខ្មែរនោះ ខ្ញុំមកដីថៃទេ ខ្ញុំមកលើភ្នំទេ បានលំបាក លំបាកក្នុងការរត់គេច លំបាកនិងស្ពាយកូន លំបាកដូចថាធ្វើដំណើរអី ជួនកាលប៉ះភ្លៀងប៉ះអីយើងដេកហាលថ្ងៃ ដេកលើថ្ម ដេកលើម្លប់ឈើ កូនឃ្លានបាយដាច់ទឹកដាច់អីទៅចឹងវាលំបាក លំបាកជាងនៅដីខ្មែរ យើងជំនាន់៧៦-៧៧-៧៨អី ដល់ឆ្នាំ៨២-៨៣នេះអាហ្នឹងលំបាករហូត ។

សុវណ្ណៈ ចឹងនៅក្នុងអំឡុងសម័យ៧៥ដល់៧៩ហ្នឹង មីងមានដែលឃើញគេធ្វើទារុណកម្មប្រជាជនឬធ្វើបាបសម្លាប់ប្រជាជនមានទេ មានដែលឃើញទេ?

ភាពៈ អត់ដែលឃើញទេ ។

សុវណ្ណៈ ចឹងនៅស្រុករវៀង មីងមានដឹងថា កន្លែងណាជាគុកមួយរបស់ខាងរបបហ្នឹងមានទេ របបបីឆ្នាំ?

ភាពៈ ចាស!មិនដឹងទេ គ្រាន់ឮថា មានកន្លែងវាយកន្លែងអីឮគ្នាឯងចេះតែខ្សិបខ្សៀវចុះជំនាន់នោះគេមិនឲ្យដឹងមិនឲ្យឮ គេមិនឲ្យដឹងទេ ឧទាហរណ៍ថា នៅជាមួយគ្នាស្រាប់តែបាត់ទៅគេសួរថា បាត់អ្នកនេះៗដូចជាមិនឃើញ មិនដឹងមិនឮមិននិយាយអីតគ្នាសោះ សូម្បីឧទាហរណ៍ថា ដូចក្មួយឯងដើរទៅឃើញគេវាយ ឃើញគេតប់ឃើញគេបាញ់ឬសម្លាប់អីមកវិញក៏មិនហ៊ាននិយាយប្រាប់អ្នកណាដែរ ដឹងតែក្នុងចិត្តឯង ទុកតែក្នុងចិត្តប៉ុណ្ណោះ អត់ហ៊ាននិយាយអីទេ ចឹងអ៊ីផ្សេងៗគឺម្នាក់ៗគឺដូចចាស់ៗនិយាយថា គាត់ឲ្យដាំដើមគ ឪពុកខ្ញុំគាត់រៀបស្លាប់គាត់ថា កូនអើយកូនពីថ្ងៃហ្នឹងទៅត្រូវដាំដើមគក្នុងមាត់ យ៉ាងម៉េចដាំដើមគក្នុងមាត់ឲ្យជាប់កុំឲ្យភ្លេច ចឹងបានថាដើមគក្នុងមាត់ដូចការនិយាយដឹងឮរឿងច្រើនណា ចាស!មិនឲ្យដឹងមិនឲ្យឮទេ ក្រៅពីយើងនិយាយធម្មតា ក្រៅពីដឹងឮឃើញអ៊ីក៏ដោយកុំធ្វើដឹងឮធ្វើគធ្វើថ្លង់ទៅនៅជាធម្មតាៗទៅ ខ្ញុំកាលគាត់នៅរស់គាត់ថា សង្គ្រាមក្រឡាប់ចាក់ហើយ ចឹងយើងត្រូវដាំដើមគក្នុងមាត់ យើងធ្វើគធ្វើថ្លង់ កុំដឹងកុំឮ ឃើញអ៊ីក៏ដោយៗ បើកូនធ្វើតាមពាក្យចាស់ៗកូននិងបានសុខហើយ បើចង់ដឹងចង់ឮច្រើនពេកខ្លួនយើងក៏មិនបានសុខដែរមែនដូចគាត់ថាមែន អ្នកណាប៉ិនដឹងប៉ិនឮចេះចុះមិនសូវបានសុខទេ បន្តិចផ្លាស់ទៅនេះបន្តិចផ្លាស់ទៅនោះ ដូចមីងពីណាអីក៏អីទៅ មីងមិនដឹងឮអីទេ ។

សុវណ្ណៈ ចឹងមីងមានឃើញគេធ្វើបាបអ្នកដែលធ្វើខុស ដូចថាលួចនេះហូបលួចនោះចឹង មានទេមីង?

ភាពៈ អត់ទេ ។

សុវណ្ណៈ មានគេវាយធ្វើបាបអី?

ភាពៈ អត់ទេ ។

សុវណ្ណៈ ចឹងមីងមានដឹងថា មានឃុំខ្លួនអ្នកដែលធ្វើខុសអីអត់ ពេលហ្នឹង?

ភាពៈ អត់មានកន្លែងទេ កន្លែងគេផ្សេងដឹង បើថាកន្លែងមីងដូចមិនដែលមានឃើញទេ បើឃើញភ័យឆាប់ហើយ មិនបាននៅទេ រត់មកផ្ទះសំបែងហើយ មានអារម្មណ៍ភ័យណាស់ ។

សុវណ្ណៈ គណៈស្រុករវៀងឈ្មោះអីគេមីង?

ភាពៈ គណៈស្រុករវៀង ចៅហ្វាយស្រុកគេ ។

សុវណ្ណៈ បាទ!កាលជំនាន់បីឆ្នាំហ្នឹង?

ភាពៈ ចាស!គាត់ស្លាប់បាត់ហើយ ។

សុវណ្ណៈ តែគាត់ឈ្មោះអីគេ?

ភាពៈ គាត់ឈ្មោះ សាន ។

សុវណ្ណៈ ឈ្មោះ សាន?

ភាពៈ ចាស ។

សុវណ្ណៈ គាត់អ្នកនៅស្រុកហ្នឹងឬមួយយ៉ាងម៉េច?

ភាពៈ គាត់អ្នកនៅហ្នឹង បងថ្លៃលោកខៀវ សំផន ។

សុវណ្ណៈ អូ!ឈ្មោះ សាន ចឹងតែម្តងមីង?

ភាពៈ សាន គាត់ស្លាប់ហើយ គាត់ស្លាប់តាំងពីយូរហើយ ។

សុវណ្ណៈ ចឹងគាត់ត្រូវជាបងថ្លៃរបស់អ៊ីខៀវ សំផន?

ភាពៈ ចាស ។ **០២:៤០:៥៩**

សុវណ្ណៈ ថ្ងៃមីងថ្ងៃនេះខ្ញុំតពីម្សិលមិញ ហើយថ្ងៃនេះថ្ងៃទី១៨ ថ្ងៃពុធ ថ្ងៃនេះ ចឹងម្សិលយើងទើបចប់៧៩ទេ មិនទាន់ចប់ស្រួលបួរមែនទែនណាស់ ។

ភាពៈ ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងឆ្នាំ៧៧ មីងត្រឡប់មកនៅវៀងវិញ?

ភាពៈ ចាស ។

សុវណ្ណៈ កាលហ្នឹងចុង៧៧ឬក៏ដើមពាក់កណ្តាល៧៧?

ភាពៈ ពាក់កណ្តាលហើយ ។

សុវណ្ណៈ ចឹងពាក់កណ្តាលឆ្នាំ៧៧មីង?

ភាពៈ ចាស!ពាក់កណ្តាលឆ្នាំ៧៧ហ្នឹងមកនៅវៀងវិញ ។

សុវណ្ណៈ ចឹងមកធ្វើឆ្នបនៅវៀងវិញត្រូវទេ?

ភាពៈ ចាស ។

សុវណ្ណៈ ហើយការងារធ្វើឆ្នបនិងយ៉ាងម៉េចខ្លះទៅមីង?

ភាពៈ វាជួបការលំបាកខ្លះស្រួលខ្លះ ម្យ៉ាងយើងមិនរៀនអីចេះណាស់ណា និយាយថាក៏រិតមធ្យមអាចជួយសង្គ្រោះគ្នាបានណា ពេលស្រួលទៅយប់ឡើងយើងសម្រាកធម្មតា មានអ្នកឈឺពោះអីបញ្ជូនមកចេះទៅ ជួបកាលទៅជួយសម្រាលអីទៅបានរួចរាល់ធម្មតា តែអ្នកខ្លះជួបការលំបាក ជួបការលំបាកដូចថាវា វាមិនប្រក្រតីពេលមានទម្ងន់អី មានការធ្វេសប្រហែសធ្វើការងារធ្ងន់ឬដេកថ្ងៃច្រើន ឬដេកអង្រឹងអីជួនកាលវាដាច់អង្រឹងអីទៅណា ដល់ពេលឈឺទៅពេទ្យទៅមានការលំបាក ជួនកាលអត់មានបានសម្រាលនៅហ្នឹងទេ បញ្ជូនទៅភ្នំពេញ ខ្ញុំជួបការលំបាកពីរនាក់ ខុសប្លែកពីធម្មតា ខ្លះសម្រាលមកជើងមុនក៏មាន មានហុចដៃមុនក៏

មាន ពុចាស់ៗថា ពេលសម្រាលទៅពេលហុចស្វា គេថាហុចស្វាពិបាកណាស់ ហុចស្វាបាន ន័យថា វាចេញមកតែដៃមួយមុននិងណា វាអត់មានចេញខ្លួនចេញក្បាលអីណា ចឹងម្ដាយ ពាក់កណ្ដាលមនុស្សពាក់កណ្ដាលខ្មោចហើយ ចឹងជួបការលំបាក ហើយជួបការលំបាកមួយ ទៀត ម្នាក់នោះពោះធំ១២ខែ ហើយនារីយើងមានទម្ងន់កូនអស់ហើយត្រឹម៩ខែ១០ថ្ងៃ ធម្មតា លើសពីនោះគឺនៅមិនបានទេ មានការប្រេះស្បូននៅមិនបាន ចឹង៩ខែ១០ថ្ងៃគឺកូន គេពេញលេញតែម្ដង គឺមានគ្រប់អៈវៈជីវៈទាំងអស់គឺអត់មានខ្វះអីទេ គឺពេលតែម្ដងលើស មួយម៉ោងមួយថ្ងៃក៏អត់បានអានោះរហូតដល់១២ខែ ចឹងចេះតែឆ្ងល់ហើយពោះចេះតែធំ ទៅៗដល់មកពេទ្យ ស្ទាប់ទៅអត់មានដុំអីទេ ស្ទាបទៅជ្រាយទាំងអស់ដូចយើងស្ទាបខ្នើយ ចឹងមិនដឹងជាធ្វើយ៉ាងម៉េច តែពេលឈឺអត់មានកើតទេ ដល់ចឹងបញ្ជូនទៅភ្នំពេញ ដល់ទៅ សម្រាលមកអាកូននោះសុទ្ធតែពង ពងនោះដូចជាពងត្រីចឹង ពងប៉ុនកដៃចេះដូចពោះវៀន និយាយឡើងមួយកំភ្ទុះចេះ ប៉ុននេះវាវែងទៅចេះ ដូចពងនៅក្នុងសំបុកត្រីណា ដូចជាពង ត្រីចឹងតូចៗ អាហ្នឹងជួបការលំបាក ចឹងកូនហ្នឹងមិនមែនកើតពីម្ដាយទេ គឺវះ ចឹងខ្ញុំធ្វើឆ្មប ជួបការលំបាកពីរនាក់ លំបាកខ្លាំង មួយដូចជាពងត្រី វាមានជាតិទឹក សាច់រអិលៗតែ មួយទៀតកើតមកពងទា ហ្នឹងពងទា ហ្នឹងពងបីដែលប៉ុនកដើង ស្មាទោសប៉ុកដើងនេះហើយ ដូចជាពលទាចឹងកើតមកវាមានបី ហ្នឹងជួបការលំបាកតែពីរទេ ក្រៅពីនោះធម្មតា វាមាន បញ្ហាអីកើតឡើង វាមានឈាមច្រើនវាមានការលំបាកខ្លះកើតមកអត់មានឈាមមានអីមាន តែទឹករំអិលវាដូចរមាឌ អាខ្លះកើតមកខ្មៅដូចធ្យូងក៏មាន ហ្នឹងជួបការលំបាកចឹង តែគេកើត មកជាមនុស្សធម្មតា តែចំឡែកតែពីរមួយពងត្រី មួយពងទា ។

សុវណ្ណៈ ចឹងមីងមានលក្ខណៈកត់សម្គាល់ឃើញទេ ថាស្រីហ្នឹងគាត់មានលក្ខណៈចឹងពេលកើត សម្រាលកូនមក ដោយសារមូលហេតុអីបានធ្វើឲ្យគាត់ហ្នឹងទៅជាចឹង?

ភាពៈ មិនដឹង ពីមានមូលហេតុអី ចឹងយកទៅពេទ្យ ពេទ្យក៏ឆ្ងល់ដែរ មនុស្សវះហើយយកពងហ្នឹង ទៅដាក់កែវ គេយកកែវធំប៉ុននេះដាក់ណាស់ ដាក់ហើយសម្រាប់ឱកទ័ពគេជំនាញមកពី ក្រៅ គេសម្រាប់ឆ្នុះមើលតើវាពងនោះមានមូលហេតុមកពីអីណា ដល់ចឹងពេលគេដាក់កែវ ហើយក៏ម្ដាយវះអ៊ីរួចរាល់ធម្មតាក៏បញ្ជូនត្រឡប់មកកន្លែងខ្ញុំវិញ ដើម្បីដឹងពីលទ្ធផលគេ ពិនិត្យណា មិនជាមូលហេតុយ៉ាងម៉េច បានជាដុំឈាមទៅជាពង ទៅជាស្អីទៅអាហ្នឹងទាល់ តែបញ្ជូនទៅពេទ្យធំៗ ។

សុវណ្ណៈ ពេលហ្នឹងមានពេទ្យអ្នកជំនាញគេត្រឹមត្រូវ?

ភាពៈ មានពេទ្យជំនាញតែទៅតាមរយៈដូចពេទ្យយើងរាល់ថ្ងៃ ។

សុវណ្ណៈ យើងនិយាយជិនាន់បីឆ្នាំ?

ភាពៈ ចាស!ដូចរាល់ថ្ងៃហ្នឹង ដូចគ្នារាល់ថ្ងៃចឹង សុទ្ធតែមានពេទ្យគ្រប់កន្លែង ។

សុវណ្ណៈ ចឹងមុនគេរើសមីងចូលធ្វើឆ្មបហ្នឹង មីងមានបានរៀនពីមុនមកទេ?

ភាពៈ ខ្ញុំអត់ដែលបានរៀនទេ តែសំខាន់គេមើលគោលជំហរហ្នឹងអារម្មណ៍របស់យើងដែលគេជ្រើសរើសណាស់ គេជ្រើសរើសជំហរដាច់ខាតក្នុងការជួយសង្គ្រោះ ជំហរដាច់ខាតក្នុងការធ្វើ ជំនាន់នោះគេមិនយកសញ្ញាបត្រថ្នាក់ខ្ពស់ថ្នាក់ទាបអីទេ សំខាន់គេយកធ្វើការជាក់ស្តែង បើជាក់ស្តែងធ្វើអ៊ីមួយហ៊ានឈ្នះឈ្នលហ៊ានពុះពារធ្វើឲ្យបានចប់ចុងចប់ដើម ពីរបីដងទៅខាងលើគេទុកចិត្តហើយ ចឹងគេអត់មានយកសញ្ញាបត្រអីទេ គេយកជាក់ស្តែង ជាក់ស្តែងយើងធ្វើខ្លួនយើង យើងអត់មានថាទៅមើលគេហើយ ដើម្បីធ្វើតាមគេប្ញក៏និយាយតាមគេប្ញក៏និយាយតាមគេ គេអត់មានយកទេ អាហ្នឹងធ្វើជាក់ស្តែងក្នុងដៃយើងជំហរខ្លួនយើង យើងអត់មានខ្ពើម គេចូលចិត្តត្រង់ហ្នឹងតើ ខ្ញុំចេះដែរ តែខ្ញុំមិនជាអ្នករៀនចេះដឹងខ្ពង់ខ្ពស់ទេ គេឲ្យធ្វើអីធ្វើ ដល់យើងធ្វើទៅលទ្ធផលដែលយើងធ្វើគឺបានទៅដូចជាបំណងយើងចង់ធ្វើមែនណា ដល់ចឹងការចេះដឹងរបស់យើង មានការពិសោធន៍ ពិសោធន៍ចេះ ពីសោធន៍ចុះយើងធ្វើខ្លួនឯង អត់មានពិសោធន៍ក្នុងក្រដាសសៀវភៅវាចេះៗ ពិសេសពុតាមគេនិយាយគឺអត់ទេ ពិសោធន៍ជាក់ស្តែងតែម្តង ឈាមជ័រខ្លួនឯងវះកាត់ខ្លួនឯងដេរខ្លួនឯងគឺធ្វើខ្លួនឯងតែម្តង គឺខ្ញុំធ្វើខ្លួនឯងតែម្តង ដល់ចឹងយូរៗទៅបានឌុកទ័រគេពួកឆ្មបគេថា យី!មីហ្នឹងគ្រាន់បើវី វាអត់មានចេះបារាំងអង់គ្លេសអីទេ ប្រសិនបើយើងទៅណាមកណើអាចបណ្តោយវាបាន ដូចមីហ្នឹងវាដាច់ខាត វាធ្វើអីធ្វើហើយវាយកចិត្តទុកដាក់គឺប្រាប់យ៉ាងម៉េចធ្វើចឹង អត់មានខុសបញ្ជារបស់មេទេ ចឹងមនុស្សដែលយកចិត្តទុកដាក់ចឹង មនុស្សគេទុកចិត្តការរៀនសូត្រអីគេចេះតែជំរុញ ជំរុញឲ្យយើងរៀនចេះប៉ុននេះឲ្យចេះប៉ុណ្ណោះឲ្យយើងខស្សរាហ៍ព្យាយាមណាស់ ចឹងបំណងរបស់យើងនិងការទុក្ខរបស់អ្នកខាងលើគេមានការកក់ក្តៅ ។

សុវណ្ណៈ ចឹងចិត្តមីងពីមុនមកមានអារម្មណ៍ថា ធំឡើងចង់ធ្វើពេទ្យចង់ធ្វើអី?

ភាពៈ ខ្ញុំចង់ធ្វើឆ្មបតាំងពីតូចមក ព្រោះយាយខ្ញុំគាត់ឆ្មប យាយខ្ញុំតាំងពីខ្ញុំធំដឹងក្តីមកឃើញយាយខ្ញុំគេហៅយាយនោះឈ្មោះ យាយរ៉ាយ គឺគេហៅឆ្មបល្បួងឡាវ ។

សុវណ្ណៈ ឆ្មបបុរាណមីង?

ភាពៈ ចាស!ឆ្មមបុរាណអ្នកតូចអ្នកធំ ប្រពន្ធចៅហ្វាយស្រុក ប៉ូលីសប៉េអ៊ឹមណាក៏ដោយឲ្យតែសម្រាលមិនហួសពីផ្ទះយាយខ្ញុំទេ ឲ្យតែប្រពន្ធគ្រប់ខែយកយាយខ្ញុំទៅនៅប្រចាំ ប្រពន្ធ

លោកណាក៏ដោយ មិនថាចៅហ្វាយណាទេ គេហៅយាយរ៉ាយ ឆ្នបល្លូងឡាវ ឆ្នបល្លូងឡាវ បានន័យថា គាត់ធ្វើទៅវាមិនគ្រោះថ្នាក់ ដូចជាមានបញ្ហាអីពិបាកយ៉ាងណាអី គាត់មានប្រដាប់គាត់ទាំងអស់ មានស្រោមដៃមានអី មានតុងស្បូងមានអីទាំងអស់ ចឹងគេហៅយាយខ្ញុំថា ឆ្នបល្លូងឡាវ ខាងពេទ្យក៏ចេះខាងបុរាណក៏គាត់ចេះ ។

សុវណ្ណៈ ចឹងកាលមីងមកធ្វើពេទ្យនៅហ្នឹងវិញ មីងមានស្នើសុំគេមកទេ?

ភាពៈ អត់ទេ ។

សុវណ្ណៈ ចឹងយ៉ាងម៉េចបានជាគេផ្លាស់មីងឲ្យចូលធ្វើពេទ្យវិញ?

ភាពៈ ដល់ពេលខ្ញុំនៅជាមួយយាយខ្ញុំ ខ្ញុំចេះទៅខ្ញុំទៅនៅជាមួយបងដែលរាប់អានខ្ញុំនោះ ប្រធានពេទ្យដែលឈ្មោះ បងខុម គាត់ថាមិត្តឯងនៅជាមួយអញ មើលកូនឲ្យអញ ។

សុវណ្ណៈ ចឹងដល់ពេលយើងផ្លាស់ពីភ្នំពេញមកនេះ?

ភាពៈ ផ្លាស់ពីភ្នំពេញមកខ្ញុំមកកន្លែងសាធារណការ ចឹងខ្ញុំខ្ជិលនៅសាធារណការខ្ញុំទៅ«៣២»វិញ ទៅមកៗចឹង ទៅនៅជាមួយបងមុនដំបូងឲ្យទៅមើលកូនទេ មិត្តគ្នាខ្ញុំហ្នឹងឯងថា មីខុម អើយមីហ្នឹងវាធ្លាប់ធ្វើពេទ្យដែលតើ វារៀនចាក់ម្ជុលវិជ្ជាសាស្ត្រឡើងពីរបីបួនខែណា ចឹងកាលពីដំបូងខ្ញុំរៀនចាក់ម្ជុលវិជ្ជាសាស្ត្រ ។

សុវណ្ណៈ កាលមីងចូលដំបូង?

ភាពៈ ចាស!ចូលរៀនចាក់ម្ជុលវិជ្ជាសាស្ត្រ អាម្ជុលគេចាក់អត់មានថ្នាំណាស់ ម្ជុលគេត្បាលឈើត្រង់ណា គេចាក់ម្ជុលវិជ្ជាសាស្ត្រម្ជុលខ្ញុំប្រហែលជា៤០បំពង់ ខ្ញុំរៀនទៅគ្រូគាត់ឲ្យមក គ្រូខ្ញុំដែលរៀនចាក់ម្ជុលវិជ្ជាសាស្ត្រនោះ ឈ្មោះបងឆន ជនជាតិ ចឹងខ្ញុំទៅរៀនចាក់ម្ជុលវិជ្ជាសាស្ត្រ ខ្ញុំរៀនចាក់ដល់យូរៗទៅបានគេដឹងថា មីហ្នឹងចេះចាក់ម្ជុលវិជ្ជាសាស្ត្រតើ ឲ្យវាមករៀនពេទ្យឆ្មប គាត់សួរថា ហងអញឲ្យចូលពេទ្យឆ្មបចូលដែរ ខ្ញុំថាចូល ហងចេះចាក់ម្ជុលវិជ្ជាសាស្ត្រហើយ ហងមានរៀនពេទ្យឆ្មប ហងមិនខ្ពឹមទេ ឲ្យតែហងសិទ្ធ សិទ្ធចូល ពីណាឈឺចង្កេះអីទៅ គាត់ថាទៅតួនាទីហងហើយឈឺក្បាលអី ។

សុវណ្ណៈ ពីណាគេជាអ្នកសួរមីងកាលហ្នឹង?

ភាពៈ ប្រធានខ្ញុំ ដែលបងធម៌ខ្ញុំ បងផុស ។

សុវណ្ណៈ ចឹងមិនមែនប្រធានពេទ្យឈ្មោះ បងកេងទេ?

ភាពៈ ទេ បងកេង គាត់ជាប្រធានធំតែម្តង ។

សុវណ្ណៈ បងកេង ប្រធានធំ?

ភាពៈ ចាស!ប្រធានធំជាងគេ ។

សុវណ្ណៈ ចឹងអ្នកហៅមីងចូលធ្វើនេះ?

ភាពៈ បន្ទាប់ទៀតបងផុស ។

សុវណ្ណៈ បងផុស ស្រីប្រុសមីង?

ភាពៈ ស្រី ។

សុវណ្ណៈ ចឹងបងផុស ហ្នឹងគាត់ទទួលខុសត្រូវខាងអីគេ?

ភាពៈ បងផុស គាត់ទទួលបន្ទុក បើបងកេង គាត់ចង់ទៅភ្នំពេញក៏បាន ទៅកន្លែងណាក៏បាន គេធំបង្អស់ គេឌុកទ័រ ។

សុវណ្ណៈ ចឹងបងផុសវិញ?

ភាពៈ បងផុស គាត់ទទួលតែបរិវេន«៣២» ទេ បើបងកេង ខាង«៣២»ក៏ទទួល«ក១»ក៏គាត់ទៅឬមួយគាត់ទៅភ្នំពេញក៏គាត់ទៅ ។

សុវណ្ណៈ ចឹងបងផុសគាត់គ្រប់គ្រងយ៉ាងម៉េចខ្លះទៅមីង?

ភាពៈ បងផុស គាត់គ្រប់គ្រងម៉ាឆ្នបទាំងអស់ហ្នឹង មានបញ្ហាអីកើតឡើងនៅលើគាត់ អ្នកពោះតូចពោះធំ នៅក្រសួងណាមានផ្ទៃពោះប៉ុន្មានខែអី បញ្ជីរស្នាមនៅលើគាត់ អ្នកណាធ្វើអីតាមគាត់ ដូចមានផ្ទៃពោះអី៧ខែអីរាយការណ៍ឲ្យគាត់ទាំងអស់ កាលហ្នឹងក្រសួងទាំងអស់ ។

សុវណ្ណៈ ចឹងមានឆ្មបប៉ុន្មាននាក់មីង ពេលហ្នឹង?

ភាពៈ ពេលហ្នឹងមានឆ្មបតែ៦នាក់ទេ ។

សុវណ្ណៈ ស្រីទាំងអស់មីង?

ភាពៈ ចាស! ស្រី អត់មានយកប្រុសទេ ។

សុវណ្ណៈ ចឹងអ្នកនៅព្រះវិហារហ្នឹងឬមួយអ្នកនៅពីផ្សេង?

ភាពៈ អ្នកនៅព្រះវិហារ ។

សុវណ្ណៈ ចឹងអ្នកនៅព្រះវិហារទាំងអស់?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងអាយុស្របាគ្នា?

ភាពៈ អាយុស្របាគ្នា ក្មេងជាងគេមានតែខ្ញុំ មានវ៉ាន់ឌី ពួកមីណេង មីណេង ទៅរៀនភ្នំពេញទៅរៀនថ្នាក់ខ្ពស់ ហើយវ៉ាន់ឌី ក្រៅពីនោះចាស់ៗ ចាស់ជាងគេបងផុស ហើយគាត់មានកូនមួយ ក្រៅពីនោះនៅក្រមុំដូចគ្នា តែគេមានអាយុបង១ ។

សុវណ្ណៈ បងផុស ហ្នឹងមីងស្គាល់គាត់របៀបយ៉ាងម៉េច?

ភាពៈ ស្គាល់តាមបងប្រុសហ្នឹង ព្រោះអីប្ដីបងផុសនោះ ត្រូវជាបងជីដូនខ្ញុំ ចឹងគាត់យកបងផុស ហ្នឹងក៏គាត់នេះទៅ គាត់ត្រូវជាបងថ្លៃផងទេ ។

សុវណ្ណៈ ចឹងបងផុសហ្នឹង គាត់ជាអ្នកស្រុកនៅណា?

ភាពៈ បងផុស គាត់ជាអ្នកស្រុកខេត្តព្រះវិហារហ្នឹងឯង តែគាត់នៅខាងព្រំដែនលាវនោះ គាត់ចេះលាវឡើងរូ ។

សុវណ្ណៈ តែនៅខេត្តព្រះវិហារជាមួយគ្នាទេ?

ភាពៈ ចាស!ចិត្តបានណាស់បង បើខ្ញុំនៅជាមួយរហូតហ្នឹង ។

សុវណ្ណៈ ចឹងមីងពេលហ្នឹងនៅ ពេលនៅក្នុងសម័យហ្នឹងពេលមីងធ្វើពេទ្យហ្នឹងនៅជុំជាមួយបងប្អូនឬនៅដាច់ដោយឡែក?

ភាពៈ ទៅតែជាមួយមិត្តភក្តិហ្នឹង បងប្អូនញាតិសន្តានមិនមែនបងប្អូនគ្នាបង្កើតអី ប្អូនខ្ញុំនៅភូមិនោះ មីប្អូនស្រីនោះ ធ្វើពេទ្យឃុំ ។

សុវណ្ណៈ ចឹងមីងពេទ្យស្រុក?

ភាពៈ ចាស!នៅកន្លែងតំបន់ ។

សុវណ្ណៈ ចឹងពេទ្យតំបន់?

ភាពៈ ចាស!នៅកន្លែងតំបន់គេតែម្ដង ព្រោះពេទ្យ«៣២» ពេទ្យតំបន់ ខ្ញុំមិនដែលនៅខាងស្រុកទេ ខ្ញុំនៅខាងតំបន់ ចឹងខ្ញុំចេញពីផ្ទះទៅ ទៅនៅកន្លែងយើងសំខាន់ៗ មិនបានរឿងសុខទុក្ខកសិករហូបបាយឬហូបបបរ លើកប្រឡាយលើទំនប់ឬធ្វើអីផ្សេងៗខ្ញុំមិនសូវដឹងទេ ព្រោះខ្ញុំចេញពីផ្ទះទៅ ទៅនៅកន្លែងសំខាន់ៗ ចឹងការហូបចុក ការរស់នៅរបស់យើងធម្មតា ខ្លះគេថា លំបាក ខ្ញុំថាខ្ញុំអត់មានលំបាកទេ ខ្ញុំរស់នៅធម្មតា ព្រោះខ្ញុំដាក់ស្ដែងនិយាយខ្លួនខ្ញុំធម្មតា ខ្លះថា ធម្មតាណាទេ កាលជំនាន់នោះស៊ីបបរ តែស៊ីសម្រាប់តែគេ ខ្ញុំមិនដែលហូបបបរទេ ។

សុវណ្ណៈ ចឹងកាលហ្នឹងបងប្អូនយើងទាក់ទងគ្នារបៀបយ៉ាងម៉េចទៅ ដើម្បីសួរសុខទុក្ខគ្នា?

ភាពៈ សុខទុក្ខអីមានអ្នកភូមិអ្នកស្រុកចេញចូលទៅ ចាប់ផ្ដើមឲ្យបងប្អូនទៅលេងទៅណា កាលនោះយើងមិនមានឡានមានអីទេ សម្បូរតែរទេះគោណា នឹកក៏ជិះរទេះគេមកលេង បងប្អូនមកក៏សុំមេទៀត ខ្ញុំថាមានប្អូនខ្ញុំម្នាក់ប្រុស មកលេងប៉ុននេះថ្ងៃប៉ុណ្ណោះថ្ងៃ មេគេអនុញ្ញាតឲ្យយើងទៅទទួលប្អូនយើងមកដេក នៅហូបបាយទឹកអីរយៈមួយអាទិត្យអីឲ្យប្អូនទៅវិញ ចង់បានអីឲ្យប្អូនក៏សុំមេគេទៅ ថាប្អូនខ្ញុំទៅវិញមានស្អីសុំឲ្យប្អូនខ្លះអាណិតប្អូនមកលេងបេះបុះ គេថាមានស្អី ឥឡូវមានស្ករ សម្បូរស្ករស្រាកណាស់ ហើយមានត្រីងៀតយកមួយគីឡូពីរ

ឲ្យប្អូន ដូចថាពីរគីឡូឲ្យប្អូនឲ្យស្អុរ មើលខោអាវរួមមាននៅឃ្លាំងហ្នឹង ទៅសុំប្រធានគេបាន ពីរកំប្លេទៅឲ្យប្អូន កុំឲ្យតែយើងលួច សុំបាន ។

សុវណ្ណៈ ចឹងគេឲ្យដែរ?

ភាព៖ ឲ្យយើងប្រាប់ត្រង់ឲ្យ សួរប្អូនមើលខាងសហករណ៍មានប្រហុកអំបិលអីដែលអត់ បើអត់ មានទៅសុំខាងសេដ្ឋកិច្ចគេ ។

សុវណ្ណៈ កាលហ្នឹងស្អុរត្នោតឬមួយស្អុរអំពៅ?

ភាព៖ ស្អុរស្រោកស្អុរត្នោត ភាគច្រើននៅនេះអត់សូវមានស្អុរអំពៅទេ ព្រោះដើមត្នោតច្រើន ណាស់ គេសម្បូរតែស្អុរត្នោត ។

សុវណ្ណៈ ចឹងស្អុរត្នោតហ្នឹងគេហៅស្អុរស្រោកទៅ?

ភាព៖ ចាស! ធ្វើដែនៗដាក់ អាធំៗនោះប្រវែងហ្នឹងទៅ១០ដែនៗទៅ ។

សុវណ្ណៈ ចឹងមីងបងប្អូនមកលេងហ្នឹងទៅនាំមកលេងទេ អត់មានគេមកខ្លួនឯងទេ?

ភាព៖ ពេលប្អូននឹកចេះទៅក៏ផ្ដាំតាមគេចេះទៅ គេមកប្រាប់ទៅក៏វាទៅៗ ដល់ទៅដឹងតាមគេអ្នក ទៅប៉ុន្មានថ្ងៃប៉ុណ្ណោះថ្ងៃមកលេងហើយ ដល់ថ្ងៃដឹងហើយ ដល់បីថ្ងៃប្រាប់មេទៅ ។

សុវណ្ណៈ ចឹងមានប៉ុន្មានខែប៉ុន្មានឆ្នាំទៅបានយើងមកលេងគ្នាម្ដង?

ភាព៖ អត់មានរឿងខែទេ មានតែរឿងឆ្នាំ ដូចថាជួនកាលកន្លះឆ្នាំមកលេងម្ដងទៅ មិនមែនពីរបី ខែអីទេ ចុះយើងអាចសុំអីៗបានឲ្យក្រែងចិត្តដែរ បើយើងញឹកញយអត់មានអីឲ្យបងប្អូនទេ កាលហ្នឹង ។

សុវណ្ណៈ កាលហ្នឹងឪពុកម្ដាយមីងស្លាប់ឆ្នាំ៧៣មីងត្រូវទេ?

ភាព៖ ចាស!៧៣ ។

សុវណ្ណៈ ចឹងពេលឪពុកម្ដាយខូចទៅ មីងទៅនៅជាមួយពីណាគេពេលហ្នឹង?

ភាព៖ ខ្ញុំនៅក្រសួងបាត់ហើយ នៅកន្លែងរួមបាត់ហើយ ។

សុវណ្ណៈ ចឹងចូលបដិវត្តតាំងពី៧១?

ភាព៖ ចាស!ចូលបដិវត្តបាត់ហើយ ។

សុវណ្ណៈ ចឹងពេលដំណឹងឪពុកខូចចឹងមានមកលេងឪពុកបានទេ?

ភាព៖ អត់ទេ គាត់ឈឺឲ្យសរសេរសំបុត្រគេយកទៅឲ្យ ដល់ពេលមកខ្ញុំនៅបានមួយខែកាលហ្នឹង មើលសំបុត្រគេអនុញ្ញាតឲ្យច្បាប់យើងពីរខែ នៅផ្ទះណា គេឲ្យយកអីៗមកអស់ហើយគេឲ្យ ច្បាប់តែពីរទេ បើពីរខែមិនឃើញទៅវិញទេ គេផ្ដាច់ឈ្មោះ គេឈប់ឲ្យយើងនៅអង្គភាព នោះគេឲ្យយើងនៅអង្គភាពផ្សេងៗ អង្គភាពនោះគេមិនឲ្យនៅទេ ព្រោះអីអង្គភាពនេះ

សំខាន់ណាស់ ចឹងខ្ញុំមកបានតែ២០ថ្ងៃឪពុកខ្ញុំស្លាប់ ឪពុកខ្ញុំស្លាប់បានតែកន្លះខែម៉ែខ្ញុំស្លាប់ទៀត ដល់ចឹងគាត់ស្លាប់ទាំងពីរទៅបានពីរខែខ្ញុំត្រឡប់ទៅវិញ ។

សុវណ្ណៈ ចឹងពេលគាត់ខូចហ្នឹងយើងមានធ្វើបុណ្យបានដែលកាលហ្នឹង គាត់ខូច៧៣ហើយមឹងចូលបដិវត្តតាំងពី៧១នោះ?

ភាពៈ ចាស ។

សុវណ្ណៈ យើងមកធ្វើបុណ្យបានធម្មតា?

ភាពៈ បាន! ទៅសុំមេគេទៀត គេឲ្យអីៗមកទៀត ទៅសុំច្បាប់គេ គេឲ្យច្បាប់គេសម្ភារបន្តិចបន្តួចមកទៀតណា គេឲ្យត្រីគេឲ្យស្អីៗដែលរបស់មាននៅឃ្លាំងគេឲ្យ ។

សុវណ្ណៈ ចឹងមឹងចេះពេលយើងមកធ្វើឆ្មបអីហ្នឹង មានគ្នា៥ទៅ៦នាក់ត្រូវទេ?

ភាពៈ ចាស ។

សុវណ្ណៈ យើងមានដែលពិភាក្សារឿងផលវិបាករបស់យើង ពីរឿងការងារពីរឿងជីវភាពរស់នៅពេលសម័យហ្នឹងយើងមានដែលនិយាយគ្នាចឹងទេ មានដែលនិយាយលេងសើចជាមួយគ្នាទេ ក្រុមឆ្មបជាមួយគ្នាហ្នឹង?

ភាពៈ យប់ឡើងមានគេប្រជុំ មេគេប្រជុំ គេប្រជុំពង្រឹងស្មារតី បើថាយើងធ្វើឆ្មបបម្រើ កាលនោះគេប្រើពាក្យថា បម្រើបក្សដោយគ្មានលក្ខខណ្ឌណាស់ មិនថាយប់ក្តីថ្ងៃក្តីធ្វើទាំងអស់អាហ្នឹងយើងប្តេជ្ញាថាបម្រើបក្សអត់មានលក្ខខណ្ឌទេ ចឹងក្នុងបញ្ហាឆ្មបនៅក្នុងមន្ទីរ មិនស្រែកថា រើសអើងថា ឆ្អាបឬក៏ឆ្អែះទេ អ្នកក្រអ្នកមានឬអ្នកធំអ្នកតូចខ្មៅសល្អអាក្រក់យ៉ាងណាឲ្យតែអ្នកជំងឺចូលមកនៅហ្នឹង ត្រូវទទួលរាក់ទាក់ជាបាយជាទឹកជាខោអាវអី ជាសម្លៀកបំពាក់ កុំថាស្អុយឆ្អែះឆ្អាបអី ចេះចុះគឺអត់មានស្មាគមន៍ទាំងអស់ មិនថាប្រុសថាស្រី មិនថាប្រជាជនឬជាកងទ័ព ។

សុវណ្ណៈ ចឹងពេលមឹងធ្វើការជាឆ្មបទៅ ធ្វើការយើងជួបផលលំបាកយើងនិយាយរឿងផលលំបាកខ្លួនយើងប្រាប់អ្នកធ្វើការជាមួយគ្នា៦នាក់ហ្នឹង?

ភាពៈ ចាស ។

សុវណ្ណៈ ឬមានមិត្តភក្តិណាដែលចិត្តស្និទ្ធយើងពិភាក្សាបញ្ហារឿងប្រាប់គ្នាឯងពីរឿងនេះរឿងនោះថាឯងធ្វើឆ្មបនេះវាចេះចុះ ឯងធ្វើមិនកើតទេ ផ្លូវចង់ដកខ្លួនអីចឹង ចឹងសម័យហ្នឹងមឹងមានដែលពិភាក្សារឿងហ្នឹងប្រាប់មិត្តភក្តិ យើងគិតថាអ្នកណាជាមិត្តភក្តិពិភាក្សាជាមួយយើងឬបញ្ហាផ្ទាល់ខ្លួនការងារឬរឿងផលពិបាកអ្វីមួយថា មកដល់នេះឆ្ងាយពីបងប្អូន ពិបាកទៅ

លេងបងប្អូនពិបាកសុំគេ យើងមានដែលនិយាយរឿងរ៉ាវហ្នឹងប្រាប់គ្នាយើងដែលអត់ប្តូមាន មិត្តភក្តិណាដែលយើងត្រូវពិភាក្សាជាមួយគ្នាអត់?

ភាព: មីងនិយាយ ។

សុវណ្ណ: មីងច្រើននិយាយរឿងអីគេមីង?

ភាព: ជួនកាលជួបការលំបាកមានគ្នាឯង ចេះតែថាជួបការលំបាក មើលទៅដូចជាតស៊ូមិនបាន ខ្លាចតែយើងចេះតែតស៊ូទៅខ្លាចមានបញ្ហា មានស្លាប់អីយើងភ័យណាស់ ទី១ខ្លាចខ្មោចទី២ ភ័យ ។

សុវណ្ណ: ម៉េចក៏ភ័យមីង?

ភាព: អ្នកខ្លះភ័យ ជួយទៅជួនកាលសង្គ្រោះមិនបានទេ មានការបាត់បង់ជីវិត ធ្លាក់ឈាមច្រើន ប្តូក៏ប្រកាច់ខាំអណ្តាតខ្លួនឯង ស្រីមានកូនមានការបារម្ភណ៍ច្រើនជំពូកណាស់ ជួនកាល សម្រាលមិនកើតភ័យ ភ័យក៏ដូចជាមិនភ័យ ពីព្រោះកន្លែងនេះមិនមែនយើងធំជាងគេ យើងតូចជាងគេ មានគេធំលើយើងទៀត បើយើងធ្វើមិនបានមានអ្នកធំៗគេមានដំណោះ ស្រាយរបស់គេ បញ្ជូនទៅតាមហ្នឹងទៀត មានជួបការលំបាក មានគ្រោះថ្នាក់ស្លាប់ ខ្ញុំជួយ បងប្អូនណាមួយអត់មានគ្រោះថ្នាក់អីទេ ធ្លាប់គេខ្លះជួបឆ្មបបុរាណមែន គ្រោះថ្នាក់រុញឲ្យខ្ញុំ អានេះគេរកឆ្មបបុរាណទៅធ្វើ ដល់ចឹងនារីនោះជិតសម្រាលហើយ កូនចេញក្បាលមក ហើយ ស្រាប់តែគាត់ឡើងជាន់ពីលើបឹប ហើយប្រលុតភ្លើងទៀត នៅក្នុងភូមិដល់ចឹងយក ពួកខ្ញុំទៅទាំងយប់ ដល់នេះរលត់ភ្លើងហើយគាត់មិនដឹងធ្វើយ៉ាងម៉េច កូនចេញក្បាលហើយ គាត់ស្ទុះទៅឡើងជាន់លើពោះតែម្តង ប្តីក៏មិនហ៊ានថាយ៉ាងម៉េច ក្រែងទម្លាប់ឆ្មបថាចឹងគ្រប់ គ្នា គ្នាកូនដំបូងមានដឹងណា ពួកខ្ញុំទៅថាធ្វើចេះយ៉ាងម៉េចកើត ផាប់គ្រោះថ្នាក់គេ ទី១គេ ប្តឹង ជំនាន់នោះវាមានប្តឹង គេមិនប្តឹងទេ ប៉ុន្តែប្រពន្ធកូនប្តីសីគេ បើប្រពន្ធគេគ្រោះថ្នាក់ ដោយសារយើង យើងសង្គ្រោះគេ យើងមិនចេះយើងថាចេះ បើមីងមិនចេះកុំធ្វើចេះ អាយុជីវិតគេណាមីង មិនមែនទិញដូរតាមផ្សារបានទេ កុំប្រទ្បំ បើយើងមិនចេះមិនបាច់ធ្វើ ចេះទេ ព្រោះជីវិតគេមួយៗឃើញយើងអ្នកចេះដឹងចឹង គឺអ្នកទាំងអស់គ្នាកក់ក្តៅ អ្នកឈឺ ក៏គេកក់ក្តៅលើយើង ចុះបើយើងធ្វើចេះ ជាន់ដើមទ្រូងចឹងដាច់ខ្យល់ទៅវាយ៉ាងម៉េច គេ ហ៊ានធ្វើអីយើងដែលអត់ មួយវ៉ាវបងប្អូនគេភ័យគេហ៊ានធ្វើយើងហើយ ព្រោះស្លាប់ដោយ ស្នាដៃយើង ថ្ងៃមុខថ្ងៃក្រោយកុំធ្វើចឹង ខ្ញុំទៅជួយបានសម្រាលមកបានត្រឹមត្រូវមួយម៉ោង ចុកឡើងលើ ខ្ញុំថាម៉ែៗរកធាងចេកឲ្យខ្ញុំខ្លះ ធាងចេកចាស់ៗកាត់ប្រវែងនេះ មានអំបោះស

អំបោះខ្មៅ  ខ្ញុំឲ្យគេស្ងោហើយដាក់អំបិលបន្តិចទៅដាក់ទឹកកន្ទះឆ្អិលខ្ញុំឲ្យផឹក  ផឹកប្រហែលជាប្អូនខ្ញុំកចឹងទៅបានដាក់អំបិលទៅបានធ្លាក់រួ  ដើរឈាមធម្មតា ។

សុវណ្ណៈ  ចឹងខ្ញុំចង់និយាយថា  យើងពិភាក្សាគ្នានៅសម័យហ្នឹង  សម័យបីឆ្នាំហ្នឹងយើងច្រើននិយាយរឿងអីគេខ្លះមីងនៅពេលហ្នឹងរឿងដែលយើងចូលចិត្តនិយាយគ្នា  និយាយជាមួយអ្នកយើងស្គាល់គ្នា  យើងអាចនិយាយគ្នាបាន  ចែករំលែកផលវិបាកជាមួយគ្នា  ចែករឿងរ៉ាវគ្នាទៅវិញទៅមក  យើងនិយាយរឿងអីគេ  និយាយរឿងការងារ?

ភាពៈ  ភាគច្រើននិយាយរឿងការងារ  ជួនកាលដូចថា  អ្នកនៅជាមួយគេមិនមែនរេនត្រូវជាមួយយើងទេ  រៀនត្រូវផ្សេងគ្នាណាស់  ម្លោះហើយឧទាហរណ៍ពិសោធន៍គេធ្លាប់នៅកន្លែងគេ  ចឹងនិយាយប្រាប់គ្នាទៅវិញទៅមក  ជួនកាលគេនិយាយកាលនៅភ្នំពេញ  ធ្វើការលំបាកវេទនា លំបាកចឹងធ្វើយ៉ាងម៉េចទៅ  ដល់ចឹងគេរៀបរាប់ប្រាប់ហើយ  ប្រាប់ឯងប្រាប់អញថានៅកន្លែងផ្សេងៗគ្នាណាស់  យើងពិភាក្សារឿងការងារចឹងទេ  បើថានិយាយរឿងផ្សេងអីក្រៅពីការងារអត់អត់មានប្រាប់ទេ ។

សុវណ្ណៈ  ចឹងមីងមាននិយាយរឿងអីច្រើនជាងគេ  ជាមួយមិត្តភក្តិ?

ភាពៈ  ខ្ញុំនិយាយពីរឿងការងារឆ្លប  ការងារអ្នកជំងឺអី  អត់មាននិយាយរឿងអីក្រៅពីហ្នឹងទេ ។

សុវណ្ណៈ  ចឹងរឿងការងារដែលយើងជួបការលំបាកឬនិយាយយ៉ាងម៉េចមីង?

ភាពៈ  ការងារជួបផលលំបាក  វេទនាដូចថាមានអារម្មណ៍ភ័យ  មានអារម្មណ៍ណា  ចឹងជួបវេទនា ភ័យណាស់  អត់ដែលជួបប្រទះ  ដល់ធ្វើទៅបានដូចចិត្តអរណាស់  ជួនកាលមិត្តភក្តិខ្ញុំវាលើកឡើងវាភ័យជាងឯងទៀតនោះ  វេទនាៗទៅគេធ្វើម៉េចទៅបើសម្រាលជួបចឹង  ចឹងយើងរៀបរាប់ប្រាប់គ្នាទៅ  មានការនិយាយប្រាប់គ្នាទៅវិញទៅមកទេ ។

សុវណ្ណៈ  ចឹងមានគំនិតដំណោះស្រាយគ្នាទៅវិញទៅមកទៅ?

ភាពៈ  ឲ្យគ្នាទៅវិញទៅមក  ជួនកាលគេមានពិសោធន៍វេទនា  យើងអត់ទាន់មានប៉ះប្រទះដូចគេ  គេមានយោបល់មកគេប្រាប់យើងទៅ  យើងចងចាំទុកទៅណា ។

សុវណ្ណៈ  ចឹងមីងច្រើននិយាយនៅពេលណា?

ភាពៈ  និយាយពេលល្ងាចៗពេលហូបបាយហើយងូតទឹកហើយ  នាំគ្នាអង្គុយប្រាជ្ញលេង ។

សុវណ្ណៈ  ចូលសម្រាកចូលអីទៅមីង?

ភាពៈ  ចូលសម្រាកទៅកាន់តារាងរៀងខ្លួនទៅ  អ្នកណាយាមម៉ោងប៉ុន្មានអី  ល្ងាចឡើងកាន់តារាងរៀងខ្លួន ។

សុវណ្ណៈ  យើងមានដែលនិយាយរឿងសប្បាយជាមួយគ្នាខ្លះទេមីង?

ភាពៈ មានសប្បាយពេលជប់លៀងអី មានរាំមានអី ។

សុវណ្ណៈ តែយើងមិនសូវនិយាយច្រើនទេរឿងសប្បាយហ្នឹង?

ភាពៈ មិនសូវនិយាយច្រើនទេ ។

សុវណ្ណៈ ចឹងច្រើននិយាយរឿងការងារផលពិបាករបស់យើង?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងពេលមីងនិយាយរឿងផលពិបាកការងារប្រាប់មិត្តភក្តិទៅគេមានឲ្យយោបល់ ឲ្យជាដំណោះស្រាយមកវិញខ្លះទេ យើងយកយោបល់គេមកយើងយកទៅអនុវត្តការងារយើងមានបានទទួលផលសម្រេចអីទេ?

ភាពៈ មានបានខ្លះដែលតើ ។

សុវណ្ណៈ ចឹងឧទាហរណ៍មីងជួបផលលំបាកអីទេ ក្រោយមកយកទៅពេលធ្វើការងារទៅវាបានសម្រេចអីចឹង?

ភាពៈ ចាស!ជួបផលវិបាកទៅយើងធ្វើតាមគេទៅ ឃើញថាវាបានដែរ ជួនកាលជួបពិបាកទៅនឹកឃើញណា ធ្លាប់ឃើញមិត្តភក្តិធ្លាប់ប្រាប់ យើងជជែកគ្នាលេងទៅដើម្បីប្រាប់គ្នាទៅវិញទៅមក ធ្វើតាមគេទៅដល់ចឹងលទ្ធផលបានផលចឹងដែរ ថ្ងៃក្រោយជួបគ្នានិយាយគ្នាទៀតទៅ ។

សុវណ្ណៈ មីងអាចឲ្យឧទាហរណ៍មួយបានទេ យើងបានចំណេះពីមិត្តភក្តិទៅយើងធ្វើការងារហ្នឹងបានមីងឲ្យឧទាហរណ៍ទៅ?

ភាពៈ ចាស!ខ្ញុំជាក់ស្តែងជួបការលំបាក ពេលឈឺពោះចេះទៅ ឈឺពោះអត់ចេះស្តាប់ពេទ្យអ្នកឈឺឲ្យតែចូលទៅដល់ពេលឈឺក្រោកដើរតែម្តង ដើរអត់ចេះស្តាប់យើងទេ ដល់ចឹងនិយាយប្រាប់អ្នកឈឺមកដល់អត់មានចេះស្តាប់ទេ ដើរឲ្យគៀកប្តីហ្នឹង ដល់ចឹងពេលឈឺទៅប្រវេប្រវ៉ា វាប្រាប់ថា ថ្ងៃក្រោយចេះទៅធ្វើអារម្មណ៍អ្នកឈឺ ធ្វើយ៉ាងម៉េច ឥឡូវយើងមិនបាច់ឲ្យគាត់ដើរទេ ឲ្យគាត់អង្គុយយើងនិយាយរឿងឲ្យគាត់ស្តាប់ ហើយសួរថាចង់ហូបអីចង់ធ្វើអី ចង់ញ៉ាំបាយបបរចង់ហូបអីឆ្ងាញ់ៗអីយើងធ្វើឲ្យគាត់ហូបទៅ យើងខស្ទាប់ជួយអង្អែលពោះអង្អែលអី កុំឲ្យដើរ ហើយកុំឲ្យដេរចេះនិយាយលោមទៅ យើងស្រីគ្រប់រូបយើងកើតមកជាស្រីអ្នកណាក៏ដូចជាអ្នកណាដែរ មានការទ្រាំដូចតែគ្នា កុំឈឺហើយស្រែកកុំឈឺហើយដេរប្តី ឈឺហើយដើរអ្នកណាដូចអ្នកណាមនុស្សរាប់ពាន់នាក់ ចឹងឲ្យតែយើងស្ត្រីយើងចេះខាំមាត់សង្កត់ចិត្តទៅ ខ្ញុំអត់មានទៅណាទៅណីទេជួយ យើងធ្វើអារម្មណ៍ចឹងទៅមនុស្សមិនសូវភ័យមិនសូវគិត វាស្តាប់យើងខ្លះដែរ ដល់ចឹងខ្ញុំជួបរាប់រយនាក់ ខ្ញុំខស្ទាប់

ពន្យល់រឿងចឹងឯង ខ្លះឈឺមិនធម្មតាទេណា ឥឡូវនេះក៏ដោយ ឥឡូវនៅគេដាក់ដូចជាឆ្នប បុរាណ មួយខែទៅប្រជុំម្ដងឲ្យយល់ មួយខែទៅប្រជុំគេម្ដងដែរ ។

សុវណ្ណៈ ចឹងមីងសព្វថ្ងៃហ្នឹងធ្វើអីគេ?

ភាពៈ ឆ្នបបុរាណ ។

សុវណ្ណៈ ចឹងឆ្នបបុរាណ?

ភាពៈ ចាស ។

សុវណ្ណៈ សល់ពីមុនមក?

ភាពៈ សល់ពីមុនមកឯងចាស់ទុំហើយ ងងឹតពាក់ពើក៏ខ្ជិល គេថាឆ្នបបុរាណទៅគ្រាន់អ្នកពោះធំអី ជូនគេទៅកន្លែងមន្ទីរមណ្ឌលមន្ទីរពេទ្យនេះ ចឹងគេគ្រប់ខេត្តអីគេឈឺពោះគេមកហៅជូនគេ ទៅប៉ុណ្ណោះឯង ទៅក៏គេឲ្យថពិការដែលប្រធានមណ្ឌលគេឲ្យមួយម៉ឺន ខ្លះមិនត្រឹមជូនខ្លះជួយ គេដល់រួចបានមកវិញ ជូនមកហើយនៅទាល់តែរួចរាល់ទៅ ទៅវិញទៅធ្វើអី ចឹងចាំ សម្រាលរួចទៅវិញក៏បានដែរ ចឹងជូនបងប្អូនជិតខាងអីក៏ដោយ ។

សុវណ្ណៈ ចឹងការងារក្រៅពីធ្វើឆ្នបបុរាណបច្ចុប្បន្នមីងមានធ្វើអីទៀត ធ្វើស្រែចម្ការ?

ភាពៈ ស្រែចម្ការធម្មតា ។

សុវណ្ណៈ ចឹងក្រៅពីធ្វើឆ្នបធ្វើស្រែធម្មតា?

ភាពៈ ចាស ។

សុវណ្ណៈ ធ្វើស្រែឬធ្វើចម្ការ?

ភាពៈ ធ្វើស្រែអត់មានចម្ការទេ ក្មួយអើយកម្លាំងថយហើយ មានតែធ្វើស្រែឥឡូវស្រែហ្នឹងធ្វើ មិនបានទៀត ។

សុវណ្ណៈ មីងមានរកស៊ីអីតិចតួចខ្លះទេ?

ភាពៈ រកស៊ីបន្តិចបន្តួចពេលខែប្រាំងធ្វើនំចេកលក់ អីបន្តិចបន្តួចគ្រាន់ទិញម្ហូបហូបប្រចាំថ្ងៃណា មីងអាំងតែចេកទេ វាវិលមុខ ទិញចេកពីផ្សារមកគេដឹកមកឲ្យ៥០ទៅ៦០ស្និតទៅ ។

សុវណ្ណៈ យើងពិភាក្សាកាលហ្នឹងអារម្មណ៍យើងភ័យខ្លាចទេ ចឹងយើងនិយាយទាំងភ័យអារម្មណ៍ខ្លាច យើងធ្វើខុសចេះធ្វើខុសចុះ យើងចេះតែភ័យមានទេ ការពិភាក្សាបែបហ្នឹងឬពិភាក្សារក ដំណោះស្រាយធម្មតាទេ អារម្មណ៍យើងធម្មតាឬក៏យ៉ាងម៉េចមីង?

ភាពៈ នៅណាកាលយើងធ្វើពេទ្យ ។

សុវណ្ណៈ កាលមីងនៅធ្វើពេទ្យឆ្នប?

ភាពៈ មានអារម្មណ៍ភ័យ ។

សុវណ្ណៈ ចឹងភ័យដែលពិភាក្សាគ្នារឿងការងារ?

ភាពៈ ភ័យខ្លាច ។

សុវណ្ណៈ ពិភាក្សាគ្នារឿងការងារយើងមានដែលនិយាយទេ?

ភាពៈ មានលើកឡើងមាន កន្លែងប្រជុំ ។

សុវណ្ណៈ ចឹងភាគច្រើនយើងប្រជុំមួយអាទិត្យម្តងប៉ុន្មានម៉េច?

ភាពៈ ប្រជុំមួយអាទិត្យម្តង ឆ្នាំមួយអាទិត្យម្តង គេមិនឲ្យនៅយូរទេ ព្រោះអីអ្នកជំងឺនិងអ្នកពោះធំនិយាយមួយមាត់មកទទួលជីវិតរាប់រយនៅនោះ អត់មានប្រហែលបុគ្គលិកបានទេ ចឹងយើងខ្លាចមានបញ្ហាគ្រោះថ្នាក់ ម្យ៉ាងយើងពន្យាពេលយូរទៅ ជួនកាលបុគ្គលិកធ្វើឆ្កួតឆ្កាចវាធ្វើខុសអីទៅមេអត់ដឹង មានការប៉ះទង្គិចលើអ្នកជំងឺទៅ ប៉ះអារម្មណ៍លិចកើតទៅ វាមិនសូវល្អណា ចឹងគេឆាប់លើកឡើងប្រមូលអារម្មណ៍ ។

សុវណ្ណៈ ចឹងគេប្រជុំមួយអាទិត្យម្តងគេច្រើននិយាយរឿងអីគេ?

ភាពៈ ប្រជុំគេច្រើននិយាយពីរឿងផ្ទះ រឿងពេទ្យ រឿងធ្វើអនាម័យ ការយាមកាម ការទទួលអ្នកជំងឺ មើលអ្នកជំងឺមិនបានដិតដល់ ជួនកាលមើលទៅវាដាច់វេនយាម ជួនកាលវេនណាដាច់ ដូចថាម៉ោង១ម៉ោង២ចឹងវាងងុយដេកណាស់ ជួនកាលយាមចឹងទៅដេកអង្រឹងលក់បាត់ទៅ អ្នកជំងឺជួនកាលអស់សារ៉ូមឈាមឡើង ពាក់កណ្តាលសេរ៉ូមក៏មាន ដល់ចឹងវាមានបញ្ហាខ្វះខាត បានជាគេមិនប្រហែលរឿងប្រជុំទេ គេប្រជុំញឹកញាប់ដើម្បីតឿន ការយាមកាមរបស់បុគ្គលិក ពេទ្យមិនស្រួលទេលោក ធ្វើពេទ្យមិនស្រួលសោះ ដេកមិនបានពេញភ្នែកទេ ជួនកាលជួបប្រទះលើអ្នកស្លាប់បាត់បង់ជីវិត នៅលើបុគ្គលិកហ្នឹង ។

សុវណ្ណៈ ចឹងមានអ្នកណាលើកបញ្ហារបស់គាត់នៅក្នុងពេលប្រជុំហ្នឹងទេ?

ភាពៈ ចាស!លើកក្នុងពេលប្រជុំបើក បើកទាំងអស់និយាយមួយម៉ាត់មក បើកសិទ្ធទាំងអស់បញ្ហាធ្ងន់ក៏ដោយស្រាលក៏ដោយឲ្យលើកឡើងទាំងអស់ មិនលីបលៀមនៅក្រៅអង្គប្រជុំនិយាយអង្គប្រជុំគឺល្អ ។

សុវណ្ណៈ ចឹងគេឲ្យដំណោះស្រាយទៅវិញយ៉ាងម៉េចដែរ?

ភាពៈ ដល់និយាយមកមេគេកត់គេសរុប បញ្ហាទី១វាចេះវាចេះៗ ៗដល់ចឹងអ្នកទាំងអស់គ្នាមានយោបល់ស្រេចអស់ហើយ មេគេចាប់ផ្តើមនិយាយដោះស្រាយហើយ ។

សុវណ្ណៈ ចឹងអ្នកណាច្រើនដឹកនាំនៅពេលប្រជុំមីង?

ភាពៈ ពេលប្រជុំមានបន្ទប់គេច្រើន ជួនកាលស្រី ជួនកាលប្រុស ជួនកាលបងគេង គាត់ប្រជុំទៅជួនកាលបងគេងមិននៅបងផុសទៅ ។

សុវណ្ណៈ ចឹងប្រធានធំបងកេង ប្រធានក្រុមបងផុស?

ភាពៈ ចាស!ក្រោយមកមានសមាជិកបន្ទាប់ៗ ។

សុវណ្ណៈ ចឹងអនុប្រធានពេទ្យធំហ្នឹង?

ភាពៈ អនុប្រធានពេទ្យធំ បងផុស ប្រធានធំជាងគេបងកេង ។

សុវណ្ណៈ តែអ្នកណាជាអ្នកដឹកនាំពេលប្រជុំម្តងៗ?

ភាពៈ ប្រជុំអីៗជួនកាលប្រធានក្រុម ។

សុវណ្ណៈ ប្រធានក្រុមឈ្មោះអីគេ មីងប្រធានក្រុមគេឬមានគេលើមីង?

ភាពៈ ខ្ញុំអាយុតិចជាងគេម៉េចគេឲ្យធ្វើប្រធាន គេឲ្យធ្វើប្រធានទាល់តែអាយុ១៨ឡើង កាលនោះយើងមិនទាន់១៨ណា គេយកតែអ្នកអាយុច្រើនៗទេ ។

សុវណ្ណៈ ចឹងប្រធានក្រុមមីងពីណាគេឈ្មោះអី?

ភាពៈ ប្រធានក្រុមខ្ញុំឈ្មោះ បងស៊ុម បងស៊ុម ត្រូវជាប្អូនជីដូនមួយ ។

សុវណ្ណៈ ចឹងឈ្មោះបងស៊ុម?

ភាពៈ ចាស ។

សុវណ្ណៈ ស្រីមីង?

ភាពៈ ចាស!ឈប់ពីបងស៊ុម មកជួនកាលបងហ៊ុច ។

សុវណ្ណៈ ចឹងបន្ទាប់មកបងហ៊ុច បងហ៊ុច ហ្នឹងជំនួសបងស៊ុម?

ភាពៈ ចាស!បងស៊ុម បងហ៊ុច ។

សុវណ្ណៈ ចឹងបងស៊ុម ទៅណាបានជាបងហ៊ុច មកជំនួស?

ភាពៈ បងហ៊ុច គាត់មានប្តីមានកូន ចុះបងស៊ុម គាត់អាយុច្រើនមែន តែគាត់មិនមានកូនគាត់ដើរគាត់ដើរទៅតាមភូមិណា ជួនកាលគាត់ទៅភ្នំពេញដែរ បងហ៊ុច មិនសូវទៅគាត់នៅបងហ៊ុចគាត់មានប្តី ។

សុវណ្ណៈ ជនជាតិអីគេមីង?

ភាពៈ ជនជាតិស្ទៀង មីងមិនបានដឹង ។

សុវណ្ណៈ ជនជាតិ ឡាវ លាវ ជនជាតិចារាយ?

ភាពៈ មិនដឹងជាជនជាតិស្ទៀង ចោះត្រចៀកមួយចំហៀងតែស្អាតណាស់ គាត់ក៏ស្អាតប្តីក៏ស្អាត ។

សុវណ្ណៈ ចឹងបងផុស និងអនុប្រធានទេ បងកេងប្រធាន?

ភាពៈ ចាស ។

សុវណ្ណៈ ហើយប្រធានក្រុមនេះបងស៊ុម?

ភាពៈ ចាស!បងស៊ុម ។

សុវណ្ណៈ ចឹងចុះពីបងស៊ុម មកបងហ៊ុច?

ភាពៈ ចាស!ច្រើនណាស់ ផ្លាស់ស្លាប់អស់ហើយ ។

សុវណ្ណៈ ចឹងឥឡូវបងស៊ុម មាននៅរស់ទេ?

ភាពៈ បែកគ្នា ខ្ញុំឡើងភ្នំឡើង៣០ទៅ៤០ឆ្នាំហើយ មិនដឹងជាយ៉ាងម៉េច ។

សុវណ្ណៈ ចឹងបងហ៊ុច?

ភាពៈ មិនដឹងយ៉ាងណា បែកគ្នាតាំងពីនោះមក មិនដែលបានដឹងដំណឹងទេ ស្ងាត់សូន្យតែម្តង គេស្មានថាខ្ញុំស្លាប់ហើយ ព្រោះខ្ញុំឡើងភ្នំគេនៅស្រុកទៅ ផ្ទះសំបែងគេខ្ញុំរត់រសាត់សែងត្រែងរត់ឡើងភ្នំ គេមិននឹកស្មានថាខ្ញុំនៅរស់ទេ ព្រោះយើងចូលព្រៃបាត់មុខមាត់ចេះ ។

សុវណ្ណៈ ចឹងមីងពេទ្យ«៣២»ហ្នឹងពេទ្យព្យាបាលជំងឺទូទៅឬមួយពេទ្យឆ្មបទេ?

ភាពៈ ពេទ្យទូទៅក៏មានឆ្មបក៏មាន មួយកន្លែងនោះទាំងអស់ ទទួលទាំងអស់ ខាងឆ្មបមួយប៉ែកទៅខាងទូទៅនោះមួយប៉ែក នៅខាងរបេងនោះមួយប៉ែកចេះទៅ ។

សុវណ្ណៈ មានពេទ្យរបេងដែរ?

ភាពៈ ចាស!មាន អ្នករបេងគេដាក់ទៅខាងក្រោយចេះ តាមផ្លូវចឹងឯងតាមលេខរាងទៅចុងគេណាស់ ។

សុវណ្ណៈ ចឹងមីងមានដឹងថា ពេទ្យ«៣២»គេបែងចែកអ្នកជំងឺជាប៉ុន្មានផ្នែកខ្លះ មានឆ្មបមួយ?

ភាពៈ ចាស!មានឆ្មប មានរបេង មានជំងឺទូទៅ មានពួកខាងផលិតថ្នាំ ផលិតថ្នាំអំពូលគេដូចអាកុងហ្វូគេស្រួចហ្នឹង ផលិតអាហ្នឹងឯង គេចំហ៊ុយថ្នាំដាក់ក្នុងអំពូលចេញមក ។

សុវណ្ណៈ ពេទ្យហ្នឹងអាគារត្រឹមត្រូវទេឬជាផ្ទះទេ?

ភាពៈ មានអាគារគេត្រឹមត្រូវ អាគារថ្មរបស់គេតើ ។

សុវណ្ណៈ អាគារពេទ្យចាស់គេពីដើម?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងរបបបីឆ្នាំគ្រប់គ្រងហ្នឹងអាគារហ្នឹងធ្វើពេទ្យ របស់សម័យបីឆ្នាំទៅ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងមានអ្នកជំងឺប្រុសអីដែរ?

ភាពៈ ចាស!មានប្រុស មានស្រី ។

សុវណ្ណៈ ចឹងប្រុសមើលប្រុសទៅ?

ភាពៈ អត់ទេ ប្រុសខាងទូទៅគេតាមវេនគេ ដូនកាលវេនប្រុសក៏ប្រុស វេនស្រីក៏ស្រី ។

សុវណ្ណៈ ចឹងអ្នកជំងឺភាគច្រើនជាប្រជាជនឬកម្មាភិបាលនៅសម័យហ្នឹងឬខាងទ័ពខាងអី?

ភាពៈ សម្បូរប្រជាជនច្រើនតែប្រជាជនទេ បើទ័ពអត់មានទេ មិនសូវមានទេ ទ័ពគេកម្រយកទៅដាក់កន្លែងហ្នឹងណាស់ មានមន្ទីរយោធាគេផ្សេង កន្លែងពេទ្យយោធាគេ មានពេទ្យសម្រាប់យោធាគេ គេមិនឲ្យប្របូកប្របល់ជាមួយអ្នកជំងឺប្រជាជនទេ ។

សុវណ្ណៈ ចឹងពេទ្យមីងជាភាគច្រើនជាប្រជាជនធម្មតាទេ?

ភាពៈ ចាស!សម្បូរប្រជាជន ។

សុវណ្ណៈ ចឹងកម្មាភិបាលឈឺធ្វើយ៉ាងម៉េចទៅ?

ភាពៈ កម្មាភិបាលឈឺមានកន្លែងគេ មានកន្លែងគេផ្សេង អត់មានដាក់ប្របូកប្របល់ទូទៅជាមួយប្រជាជនទេ ។

សុវណ្ណៈ តែនៅក្នុងបរិវេនពេទ្យ“៣២”ហ្នឹងដដែលឬមួយនៅកន្លែងផ្សេងមួយទៀត?

ភាពៈ មានកន្លែងមន្ទីរគេផ្សេងនេះទៀត ។

សុវណ្ណៈ កន្លែងដែលកម្មាភិបាលព្យាបាលហ្នឹងគេអីគេមីង មន្ទីរពេទ្យស្អីគេ?

ភាពៈ មិនដឹងថា គេហៅមន្ទីរពេទ្យស្អី គេហៅតែពេទ្យយោធាហ្នឹង ។

សុវណ្ណៈ ចឹងមានន័យថា ពេទ្យ“៣២”មើលតែប្រជាជនទេ?

ភាពៈ ចាស!ទាហានក៏មានដែរ ខ្ញុំចូលនៅនោះបួនទៅប្រាំខែ មានយោធាណាទ័ពណាចូលមួយផងមានតែប្រជាជន ។

សុវណ្ណៈ ប្រជាជនភាគច្រើនឈឺអីគេ?

ភាពៈ ប្រជាជនជួនកាលរាគរុះ ជួនកាលគ្រុនចាញ់ ដូចយើងរាល់ថ្ងៃចឹង កាលពីមុនមិនសូវមានរោគលើសឈាមទេ សម្បូរតែគ្រុន ។

សុវណ្ណៈ គ្រុនអីគេគ្រុនចាញ់?

ភាពៈ គ្រុនផ្ដាសាយភាគច្រើនណាស់ ហើយចាស់ៗក៏ឈឺតាមរបៀបមនុស្សចាស់ទៅ ក្មេងជួនកាលរាគរុះជួនកាលខ្វះទាស់ខ្វះក៏ស្អីវាគ្រប់បែបគ្រប់យ៉ាង ជំងឺណាមិនដែលជួបក៏ឃើញ ។

សុវណ្ណៈ តែភាគច្រើនយើងឃើញមានជំងឺអីច្រើនជាងគេ យកមកព្យាបាលនៅពេទ្យណាស់មីង?

ភាពៈ សម្បូរតែជំងឺរាគរុះ?

សុវណ្ណៈ មូលហេតុអីបានជាប្រជាជនរាគរុះទៅពេទ្យច្រើនចឹងមីង?

ភាពៈ មិនដឹងជារបៀបយ៉ាងម៉េច ប្រជាជនមិនសូវជាអនាម័យ ហើយម្យ៉ាងកាលហូបបបរក្នុងសហគមន៍ហូបមិនគ្រប់គ្រាន់ដឹងចឹងក្មេងវាដើរទៅប៉ះផ្លែនេះផ្លែនោះហូបចេះតែស៊ីទៅណាស់ដល់ចឹងបណ្ដាលឲ្យកើតជារាគរុះ ។

សុវណ្ណៈ ចឹងក្រោយមកយើងមានប្រាប់ខាងស្រុកឲ្យគេអប់រំប្រជាជន ថាកុំឲ្យហូបនេះហូបនោះថាឲ្យរស់នៅមានអនាម័យ មានគេពន្យល់ប្រាប់ប្រជាជនតាមមូលដ្ឋាន ចឹងពេលយើងជួបបញ្ហាចឹងយើងមានទៅប្រាប់អ្នកធំទេ?

ភាពៈ ប្រាប់ដែរ ប្រាប់ខាងសង្គមកិច្ច ប្រធានភូមិមួយៗគេត្រូវទទួលបន្ទុកមាន៥យ៉ាងខាងនយោបាយយោធា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ដល់ចឹងមានអ្នកខាងនយោបាយមាន ខាងយោធាក៏គេមាន ខាងសេដ្ឋកិច្ចក៏មានសង្គមកិច្ចក៏មាន ខាងសង្គមកិច្ចគេខាងរៀបចំអនាម័យទឹកស្អាត ផ្ទះល្វែង សម្អាតខោអាវ ស្លៀកពាក់ឬមួយការហូបចុក ផ្នែកខាងសង្គមកិច្ចគេដើរពិនិត្យតាមសហគមន៍គេ ។

សុវណ្ណៈ ចឹងមឹងមានដើរពន្យល់ប្រាប់ប្រជាជនគេ?

ភាពៈ ចាស! ដើរប្រាប់ប្រជុំ ។

សុវណ្ណៈ ចឹងពេទ្យមឹងប្រាប់ទៅហើយខាងមឹងនៅឈឹងដែលឬមានចុះថយជាងមុនខ្លះអ្នកជំងឺហ្នឹង?

ភាពៈ ជួនកាលភូមិនេះរៀងថយចុះទៅ ភូមិឆ្ងាយមានទៅ យើងគ្រាន់តែប្រជុំតែគេអនុវត្តតាមដែលឬអត់ ដល់ចឹងប្រធានសង្គមកិច្ចតាមភូមិមួយៗ គេប្រជុំប្រកាសដូចគ្នាតែក្មេងធម្មតាវាដើរព្រៃផ្សេងអី បើវាទៅបាត់ៗឃ្វាលគោឃ្វាអីវាទៅស្រែទៅអី ប៉ះស្រម៉សុីស្រម៉ ប៉ះកន្ទួតសុីកន្ទួត ។

សុវណ្ណៈ ស្រម៉ស្អីគេ?

ភាពៈ ផ្លែស្រម៉យើងក្នុងព្រៃហ្នឹងណាស់ អាហ្នឹងវាពាក់រុះអីតើ ស្រម៉ ព្រីង ផ្លែឈើគ្រប់យ៉ាងជួនកាលវាសុីទៅ ជួនកាលវានាំគ្នាគាស់ដំឡូងអីវាដុតឆ្អិនមិនឆ្អិនចេះតែសុីទៅ ម្ល៉ោះហើយវាកើតចឹងឯង ចម្ការមួយៗគេដាំដំឡូង សណ្តែក ពេញៗចម្ការ ។

សុវណ្ណៈ ចឹងអ្នកជំងឺចូលមកជាក្មេងឬមួយជាមនុស្សចាស់?

ភាពៈ ស្មើគ្នា វ័យចាស់ វ័យកណ្តាលអីមិនសូវមានទេ និងសម្បូរក្មេង វ័យកណ្តាលៗអាយុ៣០ទៅ៤០អីអាយុ២០អីមិនសូវមានទេ ។

សុវណ្ណៈ ព្យាបាលជា?

ភាពៈ ជា ។

សុវណ្ណៈ ចឹងមានព្យាបាលអត់ជាមានដែលអត់មានទេមឹង?

ភាពៈ ព្យាបាលអត់ជា ច្រើនជាងគេក្មេងៗ ។

សុវណ្ណៈ ចឹងច្រើនមានស្លាប់អី?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងពេលស្លាប់ហ្នឹងគេយកទៅធ្វើយ៉ាងម៉េចមីង?

ភាពៈ បងប្អូនគេយកមកផ្ទះវិញ ។

សុវណ្ណៈ អត់មានកន្លែងណាកប់អីទេ?

ភាពៈ ចាស! កន្លែងពេទ្យគេមានតើ កន្លែងមច្ឆាគេសម្រាប់ទុកដាក់សពបូជាដែលតើ បើមានបងប្អូនគេ យកមកទៅផ្ទះទៅសំបែងគេវិញទៅ គេខ្ជិលទុកនៅក្នុងមន្ទីរពេទ្យ ដូចថានរណាអត់មានបង ប្អូនអី គ្មានសាច់ញាតិអីខាងពេទ្យគេយកទុកដាក់ឲ្យ ។

សុវណ្ណៈ ចឹងកាលមីងមានគ្រួសារហ្នឹង មីងមានគ្រួសារនៅឆ្នាំណាទៅ?

ភាពៈ ឆ្នាំ៧៨ ។

សុវណ្ណៈ កាលហ្នឹងគ្រួសារមីងធ្វើអីគេ?

ភាពៈ អត់មានធ្វើអីទេ គាត់ធ្វើជាងផ្ទះធម្មតា គេថាពួកខាងសំណង់ ។

សុវណ្ណៈ ចឹងយ៉ាងម៉េចបានស្គាល់គ្នាមីង?

ភាពៈ កាលជំនាន់ហ្នឹងមិនស្គាល់ក៏ត្រូវតែស្គាល់ ជួនកាលគេស្គាល់យើង យើងមិនស្គាល់គេរបៀប ថាអង្គការរៀប ដូចជាស្រឡាញ់នារីណាគេទៅប្រាប់មេទៅ គេសួរទៅស្រេចលើអង្គការ អង្គការរៀបចំយ៉ាងម៉េចស្រេចតែអង្គការទៅ យើងតាមអង្គការ រៀបពាក់ខោអាវខ្មៅធម្មតា មិនថាអ្នកណាទេ ។

សុវណ្ណៈ ចឹងពេលគេស្នើចឹងមីងមានប្រកែកអីទេ?

ភាពៈ វាច្រើនទាក់ពេកខ្ញុំខ្ជិល ។

សុវណ្ណៈ ចឹងមិនមែនមានតែពូទេ ដែលស្នើហ្នឹង?

ភាពៈ មានច្រើនទាក់ទៀត តាំងពីខ្ញុំចូលដំបូងមក កាលហ្នឹងមានទាហានទៀតសួរអត់យកដល់អត់ យកទៅមេទាហានខឹងដេញបាញ់ខ្ញុំរត់ ដល់ចឹងគេសួរខ្ញុំ ខ្ញុំថាមិនយកទេ ដល់គេហៅខ្ញុំថា ភាពៗ មានគេផ្ញើរមក ចឹងខ្ញុំឃើញខ្ញុំថាក្រណាត់អីល្អម្ល៉េះ ឫស្សីចាស់ហើយមានផ្កានៅ កណ្តាលរុំរូបថត រូបថតវា តែខ្លួនរូបថតនោះវាយកអាម្ពុលនោះចាក់ដៃវាអី វាសរសេរ ឈ្មោះវាហ្នឹងដាក់ក្នុងរូបថតហ្នឹងណាស់ វាសរសេរដាក់ជូនមកខ្ញុំចេះ ឲ្យខ្ញុំទទួល ព្រោះអី មួយជីវិតនេះ មានតែខ្ញុំម្នាក់ទេ សម្រាប់ខ្លួនវា ខ្ញុំមើលហើយខ្ញុំសួរពីណា ខ្ញុំមិនចង់ទេ របស់ចង្រៃកាន់នាំប្រឡាក់ដៃខ្ញុំ ខ្ញុំមិនយកទេ បើស្ម័គ្រខ្លួនឯងយកខ្លួនឯងទៅបើចេះៗកុំយក មកប្រឡាក់ដៃខ្ញុំ ខ្ញុំខំទទួល ខ្ញុំស្មានថាមិត្តយើង បើខ្ញុំដឹងថារបស់ចង្រៃចឹងខ្ញុំមិនយកទេ ខ្ញុំចេញពីផ្ទះមកខ្ញុំមិនឲ្យពីណានិយាយហែកកេរ្តិ៍អាករខ្ញុំទេ ដោយសារតែរឿងប្រុសឈ្មោល ទេ ចឹងបើឯងចង់បានរបស់ឯងយករបស់ឯងទៅ ឥឡូវទៅប្រាប់គេទៅឯងអ្នកទទួលឯងអ្នក

វ៉ៃរាប់កុំយកមកឲ្យខ្ញុំទៀត ចឹងខ្ញុំខឹងខ្ញុំយកទៅដុតចោល ដុតទាំងកន្សែងទាំងរូបថតដល់ចឹង មានអ្នកផ្សេងរត់ទៅហៅវា មានអីគេជិះសេះមកតែម្ដង គេថាមិនបានទេ អាសាវណ្ណ ណាស់ អានោះឈ្មោះ វាអាសាវណ្ណ វាកាចណាស់ អានោះដាក់ធ្មេញមាសមួយ អានោះ ថាបាញ់ៗហើយ បើវាបាញ់ៗទៅអញមានខ្លាចអី អញបាញ់ដែរ វាអាកា អញការីប៊ីន គ្រាប់មាន៣០ដែលតើ ទល់ដាក់គ្នាទៅអាណាអស់គ្រាប់មុនអានោះដួល ខ្ញុំថាអញមិនខ្លាច ។

សុវណ្ណៈ	គាត់មេទាហានមីង?

ភាពៈ	អានោះមេកងគេ មេទាហាន ។

សុវណ្ណៈ	ចឹងមេកង?

ភាពៈ	ចាស!ត្រឹមមេកង តែវាស្មៀវ មេកងវាយព្រំដែនមិនធម្មតាទេ ចុះពីព្រំដែនទៅណា វាថាទៅស្អប់គេយ៉ាងណាក៏ដោយមិនគួរយករូបថតគេមកដុតចោលទេ ខ្ញុំថារូបថតខ្ញុំយកពីផ្ទះម្ដាយខ្ញុំមានយកពីដៃឯងមកដុតណា ខ្ញុំខុសបើខ្ញុំទៅយកពីកន្លែងអ្នកឯងមកដុតបានខ្ញុំខុស ចុះឯងផ្ញើរតាមគេរូបថតមានតម្លៃដើរហុចឲ្យអ្នកផ្សេងធ្វើអី របស់ថ្លៃថ្នូរទុកថ្វាយបង្គំទៅ របស់ដល់ដៃខ្ញុំមិនមែនរបស់អ្នកឯងទេ របស់ខ្ញុំ ខ្ញុំដុតចោលក៏បានខ្ញុំបោះចោលក៏បានខ្ញុំមានដុតរបស់ឯងណា ខ្ញុំថាចឹង វាថារបស់ហ្នឹងរបស់មានគុណ របស់គេស្អីណាណី ចុះបើមានតម្លៃដាក់លើហឹងទៅថ្វាយបង្គំទៅ របស់នេះដល់ដៃខ្ញុំរបស់ចង្រៃ ពួកហ្នឹងថាមិនបាច់តវ៉ាអីច្រើនទេទៅ វាក៏ឡើងសេះទៅមន្ទីរ«១៧»វិញទៅ ។

សុវណ្ណៈ	ចឹងពេលមីងប្រកែកជាមួយគេចឹង គេមានថាយ៉ាងម៉េចខ្លះទៅមីង មានគំរាមយើងខ្លះទេ ចឹងអ្នកគ្រប់គ្រងធំគេដល់គេស្នើមកចឹងប្រាប់មីងចឹង ហើយដល់មីងប្រកែកគេគេថាម៉េចខ្លះទៅមីង?

ភាពៈ	ទេ គេថាមនុស្សប្រុសខុស នេះគេអធ្យាស្រ័យបើតាមច្បាប់គេ គេចាប់មនុស្សប្រុសនោះដាក់គុកផង គេថារំលោភសិទ្ធគេ បង្ខូចកេរ្តិ៍ឈ្មោះគេ ។

សុវណ្ណៈ	ក្រែកអង្គការអ្នករៀបចំតើ យើងអត់មានប្រកែកអីបានណា?

ភាពៈ	អង្គការរៀបចំ នោះលើកទី១លើកទី២ទៀតមេទាហានតែម្ដង មេកងពលធំតែម្ដងតែជនជាតិ ។

សុវណ្ណៈ	ជនជាតិអីគេមីង?

ភាពៈ	អត់មានឃើញធ្មេញ ធ្មេញសើចមកឃើញខ្មៅ គាត់ស្រឡាញ់ណាស់ ខ្ញុំទៅកន្លែងណាកូនទាហានគាត់ដែរ ខ្ញុំទៅណាក៏កូនទាហានគាត់ទៅតាមដែរ ហើយខ្ញុំក៏មិនដឹងដែលស្រាប់តែដល់នេះមេខ្ញុំសួរថា ភាព អើយ ភាព លើកទី២ហើយ ភាព ឯងគួរគិត លើកទី២អីបងខ្ញុំមិន

ដែលមានកំហុសអីផង ឥឡូវមេកងពលមានកូនទាហានរាប់រយ ភាព ឯងថាគោរពអង្គការ គ្មានលក្ខខ័ណ្ឌឥឡូវដល់អាយុហើយ អាយុ១៥-១៦-១៧ហើយ ភាព ឯងគួរណាស់ ប្ដេជ្ញារៀបការជាមួយគេទៅ ឲ្យខ្ញុំរៀបការជាមួយពីណាបង ថានោះបងដែលចងអង្រឹងនៅកណ្ដាលគេពាក់នាឡិការក្រហមនោះ ខ្ញុំអង្គុយមើល ខ្ញុំថាបងអើយបង ខ្ញុំសុខចិត្តអត់មួយជីវិតខ្ញុំមិនយកទេ ថាអីរូបអាក្រក់អីគេរិះមេ្ល៉ះ ថាទេឲ្យគេយកអ្នកស្អាតដូចគ្នាទៅ ខ្ញុំអាក្រក់ ខ្ញុំនៅអត់មានប្ដីមួយជីវិតអត់ស្លាប់ទេ កុំឲ្យតែអត់បាយអត់សម្លបានខ្ញុំស្លាប់ ខ្ញុំខ្ជិលយក ខ្ញុំក៏ទៅនៅកន្លែង«១២»វិញដដែលខ្ញុំមិនទទួលទេ ដល់រួចមួយវគ្គបេះទៅពីរដង ចប់បីដងគេដប់លៀងទទួលកងទ័ពពីព្រំដែនទៅពីលើភ្នំដងរែក គេឲ្យនារីអង្គុយម្ខាង ពួៗអង្គុយម្ខាង ហើយគេឲ្យឈរចាប់ដៃ ចាប់ដៃកងទ័ពគេលាមកសមរភូមិវិញ ចឹងក៏តម្រៀបជួរគ្នាចាប់ដៃ ចាប់ដៃគេប្រឹបគ្រប់គ្នា ស្រាប់តែអាម្នាក់នោះ វាមកដល់ចាប់ដៃខ្ញុំចឹងវាមិនលែង អត់លែងទេ ខ្ញុំមើលមុខខ្ញុំថា មិត្តគេទៅអស់ហើយម៉េចក៏ចាប់ដៃខ្ញុំចឹង អ្នកក្រោយបេះតែមក ហើយម៉េចបានជាមិនលែង ហើយសួរថាឈ្មោះអី ខ្ញុំថាមិនបាច់សួរឈ្មោះទេ ចាប់ដៃមួយភ្លេចជាមិត្តភាពរបស់យើង សួរឈ្មោះ ពួកហ្នឹងប្រាប់ថា ឈ្មោះ ភាព អើបើប្រាប់ឈ្មោះ ប្រលែងដៃ ទៅបានបីថ្ងៃគេសួរតាមគេមក អានោះសួរមេ«៣២» សួរមក ខ្ញុំថាដូចជាជិពប់ឈើមិនដឹងជាមុខយ៉ាងម៉េច មិនដឹងជាខ្មៅដឹងស គ្រាន់តែមើលមុខគ្នាភ្លាមឈ្មោះអីមិនដឹងនៅណា មិនជាយ៉ាងម៉េច ខ្ញុំមិនយកទេ បងគាត់ថា ផាប់ហើយទី៣ទី៤មិនយក ផាប់ហើយ មិនដឹងជាយ៉ាងម៉េច ចឹងបានជាយកគ្រួសារខ្ញុំឥឡូវត្រូវនេះ ប្ដីណាក៏ខ្ញុំមិនចង់យកដែរ ខ្ញុំខ្ជិលខ្ញុំមិនចង់បានខ្ញុំមិនស្រឡាញ់មនុស្សប្រុស ស្អាតម៉េចក៏ស្អាតទៅ ខ្ញុំមិនចូលចិត្តសោះ អ្នកណាឡូយឆាយយ៉ាងម៉េចក៏មិនចូលចិត្ត ។

សុវណ្ណៈ ចុះពូយ៉ាងម៉េចព្រមមីង?

ភាពៈ ចុះយើងវាដល់កំណត់ហើយ ព្រោះវិន័យ បើយើងមិនយកយើងតែខុសវិន័យហើយយើងមិនយកយើងមានទោស វាច្រើនជាន់ច្រើនគ្រាពេកគេពិបាកដោយសារយើងចឹង យើងមានទោសយើងមានវិបត្តិខ្លួនឯង គេអាចដកយើងទៅដាក់កន្លែងផ្សេងទៀត ចឹងខ្វះគេដោយសារកំហុសអត់ធ្ងន់ធ្ងរ គេផ្លាស់យើងឲ្យទៅណា គេឲ្យយើងធ្វើជីអាចម៍ឬគេឲ្យទៅជញ្ជូនគ្រាប់ឬគេដាក់ទៅណាណើ ដល់ចឹងខ្ជិលផ្ដាច់ចិត្តប្ដេជ្ញាយកទៅ ។

សុវណ្ណៈ កាលពូធ្វើអីគេមីង?

ភាពៈ គាត់នៅធ្វើខាងសំណង់ធម្មតា ។

សុវណ្ណៈ ម៉េចយល់ព្រមទៅអត់មានប្រកែកទេ?

ភាពៈ ចាស!វាច្រើនជាន់ពេក ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងរៀបការហ្នឹងមានប៉ុន្មានគូរកាលហ្នឹង?

ភាពៈ ខ្ញុំរៀបការតែមួយគូរទេ ។

សុវណ្ណៈ ចឹងអត់មានជួបគ្នាច្រើនទេ?

ភាពៈ ចាស!ព្រោះខ្ញុំនិយាយប្រាប់ ខ្ញុំតាម ខ្ញុំការខ្ញុំតាមបងទាំងអស់ តែឲ្យខ្ញុំការតែមួយគូរបានខ្ញុំការ រៀបចំច្រើនគូរខ្ញុំមិនយកទេ បងប្រធានគាត់ថា បើមួយគូរៗក៏មួយគូរទៅអត់ឲ្យមានអ្នកផ្សេង អត់មានឲ្យមានអ្នកផ្សេង រៀបការតែវាមួយគូរបានហើយ ហើយគេកាប់គោពីរជ្រូកមួយ គេកាប់គោពីរបីគេរៀបការពីរទៅបីគូរ ខ្ញុំគោពីរជ្រូកមួយការតែម្នាក់ខ្ញុំ បើមិនចឹងខ្ញុំអត់ការ គាត់ថាប៉ុន្មានក៏កាប់ដែរ ឲ្យតែខ្ញុំព្រមការ ។

សុវណ្ណៈ ចឹងមីងការនៅណាដែរ?

ភាពៈ ការនៅមន្ទីរ ។

សុវណ្ណៈ មន្ទីរអីគេ?

ភាពៈ មន្ទីរ«១៧» ។

សុវណ្ណៈ ចឹងក្រែកមីងនៅធ្វើនៅ«៣៧»តើ យ៉ាងម៉េចបានទៅ«១៧»វិញ?

ភាពៈ ចាស!ចុះបើគេថា មន្ទីរ«១៧» និយាយមួយម៉ាត់ទៅ«១៧»ដូចជាផ្ទះម៉ែចឹង «១៧»ជាផ្ទះស្នាក់តែម្តង យើងមករៀនមកអី ដូចយើងមករៀនចឹងណា យើងមករៀនទៅយើងចង់ទៅក៏ទៅៗយើងចង់មកក៏មកទៅ ។

សុវណ្ណៈ ចឹង«៣៧»ដូចជាកន្លែងធ្វើការទេ?

ភាពៈ ចាស!កន្លែងធ្វើការ ។

សុវណ្ណៈ ដល់ពេលយើងធ្វើការចប់យើងទៅ«១៧»វិញ?

ភាពៈ ចាស!ធ្វើការចប់ទៅ«១៧»វិញ «១៧»ដូចជាផ្ទះម៉ែផ្ទះឪយើងចេះ ។

សុវណ្ណៈ ចឹងយើងនៅជុំគ្នានោះវិញ?

ភាពៈ ចាស!យើងនៅជុំគ្នានោះ ។

សុវណ្ណៈ ត្រូវមកធ្វើការ មកនៅធ្វើការនេះមក?

ភាពៈ ចាស ។

សុវណ្ណៈ ធ្វើការហើយត្រឡប់ទៅវិញ?

ភាពៈ ចាស!កន្លះខែបួនដប់ថ្ងៃអីចឹងលទៅៗ បងអើយខ្ញុំទៅ«១៧»វិញហើយ ទៅពីរបីថ្ងៃចេះទៅបងថា យើសទៅបានយូរណា អត់ទេ បងទៅវិញស្អែកហើយ ឲ្យតែទៅនោះដួកមិនចង់

មកទេ បងសុន គាត់ថាវានៅហ្នឹងកុំឲ្យវាមកពេក ប្រយ័ត្នវារៀនមិនបានដិតដល់ប្រយ័ត្នវាមិនចេះ ចំណេះអស់នេះអញទុកវាចាស់ទៅចិញ្ចឹមជីវិតខ្លួនតើ មិនសម្រាប់អញទេ បងដេញមកវិញ ។

សុវណ្ណៈ ពីណាគេ?

ភាពៈ បងសុន គាត់ថាឲ្យរៀននេះសម្រាប់ចំណេះខ្លួនឯង ដោះស្រាយខ្លួនឯងអនាគតទៅមុខ ចំណេះយើងអត់មានពីណាដណ្ដើមបានទេ ចំណេះក្នុងខ្លួន បើសម្ភារលុយកាក់អីគេដណ្ដើមបាន ចំណេះយើងគេដណ្ដើមមិនបានទេ ចឹងយើងទៅទីណាយើងមានចំណេះយើងចិញ្ចឹមខ្លួនបានហើយ ចឹងបើមិនខំរៀនទៅរត់ទៅរត់មកយ៉ាងម៉េចបានចេះ ។

សុវណ្ណៈ ចឹងកាលហ្នឹងយើងរៀបការហើយយើងធ្វើអីវិញកាលហ្នឹង?

ភាពៈ ការហើយអត់មានធ្វើអីទេ ឈប់បណ្ដោយ ។

សុវណ្ណៈ មីងការឆ្នាំ៧៨?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងពេលរៀបការហើយគេចាត់ចែងឲ្យធ្វើយ៉ាងម៉េចទៀតមីង?

ភាពៈ ការហើយនៅធម្មតា យើងអត់មានធ្វើអីទាំងអស់ អត់មានធ្វើអីទេ ខ្ជិល នឹកឃើញចេញតស៊ូកាលពីនៅក្មេងរហូតដល់ទីចុងបំផុតបានប្ដីនៅស្រុកស្រែឯង មានបានទៅណាទៅណីទេ ខ្ញុំខ្ជិលបណ្ដោយ ខ្ញុំខ្ជិលមិនធ្វើអី ស្ទូងក៏មិនចេះមិនដឹង ស្ទូងក៏មិនធ្វើ ធ្វើតែស្រែធម្មតា អ្នកណាឲ្យទៅណាក៏មិនទៅ តូចចិត្តខ្លួនឯង ។

សុវណ្ណៈ ចឹងក្រោយមកយើងមកនៅជាមួយគ្រួសារ?

ភាពៈ ចាស!នៅជាមួយគ្រួសារ ។

សុវណ្ណៈ ចឹងយើងធ្វើស្រែធ្វើអីទៅ?

ភាពៈ ឆ្នាំ៧៨ ចាស!ឆ្នាំ៧៨-៧៩ឆ្នាំ៨០ហ្នឹង ។

សុវណ្ណៈ មីងកុំអាលខ្ញុំសុំកាត់បន្តិចមីង ឆ្នាំការ៧៨ហ្នឹង មីងការពេលណា ការដើមឬចុងមីង?

ភាពៈ ការហ្នឹងភ្លេចខែបាត់ហើយ ការខែ២ ។

សុវណ្ណៈ ដើមដែរ?

ភាពៈ ចាស ។

សុវណ្ណៈ ដើម៧៨?

ភាពៈ ចាស ។

សុវណ្ណៈ ហើយការហើយទៅធ្វើស្រែវិញទៅ?

ភាពៈ ចាស! ធ្វើស្រែធម្មតា ។

សុវណ្ណៈ ចាប់ពីការហើយយ៉ាងម៉េចទៀតសភាពការណ៍នៅពេលហ្នឹង?

ភាពៈ អត់មានអីទេ មកនៅធ្វើស្រែធម្មតាជាមួយអ្នកភូមិ ខ្ញុំខ្ជិលឈប់ទៅវិញ ទៅក្រសួងទៅអីបងគាត់ខឹង គាត់ថាឲ្យទៅនៅក្រសួងវិញ ខ្ញុំមិនទៅ ។

សុវណ្ណៈ មានមូលហេតុអីមីង?

ភាពៈ មានមូលហេតុអី ខ្ញុំមិនទៅក្រសួងវិញខ្ជិល ។

សុវណ្ណៈ មានអន់ចិត្តគេដែរ?

ភាពៈ ចាស! អន់ចិត្ត ។

សុវណ្ណៈ អន់ចិត្តយ៉ាងម៉េចមីង?

ភាពៈ អន់ចិត្តមិនគួរណាមកការជាមួយមនុស្សមិនស្រឡាញ់សោះ បេះយកមនុស្សមិនស្រឡាញ់មុនៗមិនស្រឡាញ់បេះគេចផុត ម្តងនេះមិនស្រឡាញ់គេចមិនផុត ហើយអ្នកដែលស្រឡាញ់មិនបាន មានស្រឡាញ់តែម្នាក់អត់បាន ដូចគេជាបញ្ញាជន គេធ្លាប់នៅភ្នំពេញរៀនថ្នាក់ចប់ហើយ ជំនាន់រដ្ឋប្រហារគេរៀនចប់ហើយ គេបានសញ្ញាប័ត្រចេញធ្វើគ្រូ អាហ្នឹងគេស្រឡាញ់ដែរ ឪពុកម្តាយគេស្រឡាញ់ណាស់ ប៉ុន្តែដល់សួរអង្គការគេថា យកមិនបានព្រោះគេកូនអនុជន គេកូនអ្នកមាន ផ្ទះថ្មគេរាប់ជាន់នោះ ចឹងខ្ញុំកូនកសិករថ្នាក់កណ្តាលដល់ចឹងមួយកសិករមួយអនុជនយកគ្នាមិនបានទេ មានតែមួយហ្នឹងឯងដែលមានចិត្តស្រឡាញ់ គេក៏ស្រឡាញ់យើង យើងក៏ស្រលាញ់គេ គាត់ក៏មិនបែកចែកថា អ្នកស្រែអ្នកចម្ការអ្នកខ្មៅអ្នកសអីទេ គាត់ស្រឡាញ់ៗហើយ តែអង្គការគេមិនឲ្យយក ខ្ញុំថាដល់ពេញចិត្តមិនឲ្យយក ដល់មិនពេញចិត្តបេះតែរុញ ខ្ញុំថាឲ្យ អាគេពេញចិត្តមិនឲ្យយកទេ ដល់មិនពេញចិត្តបេះតែរុញ ចុះស្រេចតែអង្គការអញដឹងអី ។

សុវណ្ណៈ ចឹងយើងអន់ចិត្តដែលមីង?

ភាពៈ អន់ចិត្ត ។

សុវណ្ណៈ ចឹងមានប្រាប់គ្រួសារយើងដែលការហើយនេះទេ?

ភាពៈ ខ្ញុំអត់មានប្រាប់ទេ ។

សុវណ្ណៈ គាត់មានថាយ៉ាងម៉េចទេ?

ភាពៈ ខ្ញុំមិនថា មិននិយាយស្តីក៏ខ្ញុំមិននិយាយ មិននិយាយទាំងអស់ វាដឹងដែលខ្ញុំរត់ទៅថៃ ថាបើអង្គការមិនឲ្យតស់យើងរត់ ខ្ញុំថាយីខ្ញុំមិនលេងចូលទេ នាំខ្ញុំរត់អី ហើយស្អាតណាស់ សព្វថ្ងៃគេនៅភ្នំពេញ គេមានកូនមានប្តីមានប្រពន្ធអស់ហើយយ៉ាង ស្អាតណាស់ ស្រឡាញ់ខ្ញុំ

នោះ ខ្ញុំក៏ស្រឡាញ់គេស្អាត ខ្ពស់ប៉ុនក្លួយឯងហ្នឹងតែមាឌធំជាងសស្កុះគេពេទ្យផង ពេទ្យមន្ទីរគេនោះ ។

សុវណ្ណៈ ចឹងក្រោយមកយើងចាប់ផ្ដើមរត់ឆ្នាំណា ខាងវៀតណាមខាងរដ្ឋាភិបាលវាយមកចឹង?

ភាពៈ ដល់ពេលចេញពីក្រសួងមកឆ្នាំ៧៨ ដូចជាពួកវៀតណាមមកថ្ងៃទី ទៅដល់តំបន់១០៣ ចេញតាមស្ទឹងត្រែងក្រចេះមក គេមកពីកើតមកតំបន់ពួកខ្ញុំខាងខេត្តព្រះវិហារហ្នឹង គេមកពីកើតវិញ ចេញពីស្ទឹងត្រែងមកពីនោះ វាយចូលតាមឆែបពីនោះ ។

សុវណ្ណៈ ចឹងគេវាយចូលព្រះវិហារគេវាយចូលតាមឆែនទេ?

ភាពៈ ចាស!ពីឆែបមក ចេញពីស្ទឹងត្រែងមក មកពីឆែប មកពីនោះមកពីកើតដល់ចឹងគ្រាន់គេមកដល់ខ្ញុំរំលាយដូចថារំសាយខ្លះ ខ្លះមានផ្ទះដេកគេទៅផ្ទះទៅ ខ្លះផ្ទះឆ្ងាយចេះតែរត់ទៅជ្រកកោនផ្ទះគេសិនទៅណាស់ បើយើងគេចផុតៗបើយើងគេចមិនផុតទេ គេមកដល់ឃើញយើងអ្នកក្រសួងអ្នកមន្ទីរអី អាហ្នឹងគេចាប់ គេចាប់ធ្វើទារុណកម្មធ្ងន់ធ្ងរ ។

សុវណ្ណៈ មីងពូសួរព្យចាប់ផ្ដើមវាយគ្នាក្នុងក្ដាំងចឹង ចាប់ពីពេលណាមកឬឆ្នាំណាមក?

ភាពៈ ដែលគេចូលមក គេមិនមានវាយទេ ចូលមកឡានបើកឈិបៗតែម្ដង ។

សុវណ្ណៈ ចឹងយ៉ាងម៉េចបានជាឡានចូលមកងាយៗម្លេះ យើងមានអ្នកការពារដែលតើ?

ភាពៈ មានអ្នកការពារបើយើងនេះនៅចុងគេ គេចូលពីភ្នំពេញពីណាពីណីមក ចូលបានឡើងយើងចុងគេហើយ យើងធ្វើអីគេចេញ ។

សុវណ្ណៈ គេព័ទ្ធក្រចេះ គេព័ទ្ធស្ទឹងត្រែង រតនគិរីជុំអស់ហើយនៅសល់តែព្រះវិហារខាងនេះ?

ភាពៈ នៅសល់តែព្រះវិហារ យើងនៅធ្វើអីគេ គេមកពីនោះបាន គេក៏មកដល់នេះបានដែរ ។

សុវណ្ណៈ ចឹងមានទ័ពគេនៅសល់ខ្លះមិនវាយជាមួយគេបាន?

ភាពៈ អត់មានហ៊ានតទេ បើគេតមានតែគ្រោះថ្នាក់ យើងទៅតនៅណា បើយើងបាក់ទ័ព ។

សុវណ្ណៈ ចឹងពេលចូលមកខែណាឆ្នាំណាមីងមានចាំទេ?

ភាពៈ ខែណាទេ ។

សុវណ្ណៈ ខ្ទង់៧/៨ហ្នឹងឬយ៉ាងម៉េច?

ភាពៈ ខ្ទង់៧/៨ហ្នឹង ក៏ខ្ទង់ខែបីមិនដឹង បើមិនខែពីរខែបី ។

សុវណ្ណៈ មីងការបានប៉ុន្មានខែ កាលហ្នឹងមីងការខែ២?

ភាពៈ ចាស!ខ្ញុំការខែ២ ខ្ញុំការជាងពីរខែហើយដឹង ។

សុវណ្ណៈ ការហើយពីរខែ?

ភាពៈ ចាស ។

សុវណ្ណៈ	អាចថាខែ៥ គេចូលមកដល់ឬយ៉ាងម៉េច?

ភាពៈ	ខ្ញុំអត់មានចំណាំខែគេចូល ខ្ញុំមិនដឹងជាខែណា ខែបីខែបួន មិនបានជាចាំខែថ្ងៃដែរ ចូលមកមាននេះទេ ព្រោះខ្ញុំរំសាយ ប្អូនមីងជិះឡានរត់ផ្លូវទៅថៃនោះ គេចាប់ចំរិតគេមានឡាន គេថាបងប្អូនណាចូលថៃទេ ឥឡូវឡើងឡានមក បើបងប្អូនណារត់ចូលថៃចេញឲ្យផុត បើថាចេញមិនផុតខ្លាចមានគ្រោះថ្នាក់ អត់មានពីណាទទួលខុសត្រូវទេ ឥឡូវដោះស្រាយរៀងខ្លួនអ្នកណារត់រួចៗអ្នកណារត់មិនរួចចប់ ខ្ញុំមានស្អី មានតែសំពត់មួយដាក់បាយមួយយកកំប៉ុងចេញមកព្រឹប មកដល់ជួបឡាន ឡានចេញពីកំពង់ធំមក គេសួរថាទៅណា ថាខ្ញុំទៅផ្ទះ ផ្ទះនៅណា គេថាពួកក្រសួងដឹង ខ្ញុំថាទេ ខ្ញុំមិនមែនអ្នកក្រសួងទេ បើពួកក្រសួងមិនឲ្យមកទេ ។

សុវណ្ណៈ	ឡានហ្នឹងឡានខាងណាមីង?

ភាពៈ	ឡានពួកខាងវៀតណាម ។

សុវណ្ណៈ	មិនមែនឡានខាងរបបបីឆ្នាំទេ?

ភាពៈ	ទេ ឡានពួកខាងវៀតណាម បើពួកក្រសួងគេចាប់ដាក់ឡានទៅអស់ បើអត់ក្រសួងគេឲ្យមកផ្ទះវិញ ថាខ្ញុំមិនមែនអ្នកក្រសួងទេ ខ្ញុំអ្នកភូមិ ខ្ញុំទៅផ្ទះ ហើយប្អូនខ្ញុំឡើងឡានទៅជាមួយខ្មែរក្រហមបាត់ទៅជំនាន់បីឆ្នាំ ឡានគេទៅមុន ប្អូនខ្ញុំទៅដល់ឡានគេកំពង់ដាក់កម្លាំងវាចុះពីលើឡានវារត់កាត់ព្រៃតែពីរនាក់ ឡានគេនៅដាក់កម្លាំងអ្នកបត់ជើងបត់ដៃដាក់តាមព្រៃចឹងទៅប្អូនខ្ញុំចុះតាមព្រៃទៅ ដល់ឡានចេញទៅ វាពួននៅតាមព្រៃ ខ្ញុំមកដល់ភូមិបីថ្ងៃបានប្អូនខ្ញុំមកតាមមកដល់កាត់ព្រៃអត់មានបាយទឹក កុំតាំងពីនោះមកមិនដឹងថាបាត់ប្អូនបាត់សែងត្រែងទៅដល់ណា រត់បែកបាក់គ្នា ខ្លះរត់រួចខ្លះរត់មិនរួច បើពួកហ្នឹងគេចាប់បានមករត់មិនរួចផ្ទះនៅកំពង់ស្រឡៅ ដឹងចឹងវារត់ទៅដឹងរត់ទៅណា បើវាមិនស្គាល់អ្នកភូមិដងវានៅតែក្នុងក្រសួង ។

សុវណ្ណៈ	ចឹងមុនវៀតណាមចូលមកយើងមានព្ទុសភាពការណ៍ថាមិនស្រួលនៅមីង?

ភាពៈ	ចាស!មានព្ទុដែរ ព្ទុតែយើងមិនដឹងថាដោះស្រាយយ៉ាងម៉េច ហើយគេលើកទាំងផែនទីមកទៀត គេយកផែនទីឲ្យមើល ផែនទីផ្ទាំងធំ ឃើញគេដាក់សញ្ញាថាវៀតណាមនៅដីខ្មែរ គេអូសមកចេះនៅសល់ប៉ុនមេដៃមើលទៅ ។

សុវណ្ណៈ	ចឹងពេលចូលមកអត់មានវាយអីទេនៅខាងហ្នឹង ពេលខាងវៀតណាមចូលមក?

ភាពៈ	អត់មានវាយទេ ព្រោះយើងមិនត បើមានតគឺវាយហើយ មានតបាញ់ហើយ ព្រោះអីបានថាមិនត ព្រោះពួកនេះដឹងថាវៀតណាមចូលគេអត់ឲ្យជួប គេចេះតែគេចណាស់ បើ

ជួបដាក់គ្នាហើយ ចឹងមិនជួបទេ ផុតៗមិនដឹងមានអីប៉ះគ្នា រត់គេចទៅសំឡូត ខ្លះទៅប៉ៃលិន ខ្លះទៅលាចទៅស្ទឹណា ខ្លះក៏ឡើងមកដែរ ដល់ចឹងចេះតែផុតទៅចូលដល់ដីថៃអី ។

សុវណ្ណៈ ចឹងមានន័យវៀតណាមចូលមកចាប់ផ្ដើមចូលបណ្ដើរហើយ?

ភាពៈ ចាស!ខ្លះរត់ផុត ខ្លះទៅនៅផ្ទះធម្មតា ខ្លះចេះតែទៅ ពួកខ្ញុំរត់មិនផុតទៅផ្ទះធម្មតា ដល់ពេលឆ្នាំ៨០ រត់មកវិញ ។

សុវណ្ណៈ ចឹងកាលហ្នឹងពេលរត់ហ្នឹង រត់ទៅណាវិញ ពេលវៀតណាមចូលមក?

ភាពៈ ខ្ញុំរត់មកផ្ទះ មកភូមិវិញ ។

សុវណ្ណៈ មកភូមិនៅស្រុកគូលេនហ្នឹង?

ភាពៈ ចាស!មកភូមិវិញ បងប្អូនខ្ញុំក៏វាមកភូមិជុំគ្នាដែរ ។

សុវណ្ណៈ មកជុំគ្នាមួយរយៈសិន?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងពេលចូលមកវៀតណាមគេថាម៉េច ពេលចូលមកដល់?

ភាពៈ ពេលចូលគេមកដល់ដែរ មកដល់ភូមិព្រឹបដែរ ដល់មកដល់គេសួរដែរ ថាពួកហ្នឹងពួកក្រសួង ឬអី ព្រោះខ្ញុំប្រើរបស់របរក្រសួង ។

សុវណ្ណៈ គេឃើញអីបានគេដឹងថា យើងប្រើរបស់ក្រសួង?

ភាពៈ ព្រោះខោអាវអ្នកភូមិនិងអ្នកភូមិខុសគ្នា ។

សុវណ្ណៈ ខុសគ្នាយ៉ាងម៉េចមីង?

ភាពៈ ខុសគ្នាថា យើងប្រើខោអាវរបបអ្នកក្រសួង អ្នកភូមិប្រើខោអាវធម្មតា បើខោអាវពួកខ្ញុំ សុទ្ធតែមានអត់មាន បើឆ្នាំ៧៧ គេមានខោអាវប្រដេះ ហើយកាត់ខោអាវធម្មតាមានជីប តែគេប្រើប៊ូស្តាប្រើខ្សែវមួយ ដាក់ប៊ូស្តាចឹង តែឆ្នាំ៧៧ បើ៧៨ គេប្រើដៃចំហមានក្រប៉ៅ មុខ អាកមូលៗអាហ្នឹងសុទ្ធតែក្រសួងហើយ គេឃើញខោអាវគេស្គាល់តែម្ដង តែគេអត់ ឲ្យប្រើខ្សែវធម្មតាចេះទេ គេឲ្យប្រើខ្សែវកិបចេះ ។

សុវណ្ណៈ ចឹងមីងស្រុករវៀងហ្នឹងកាលពីមុនជាស្រុកទីរួមខេត្តរបស់ខេត្តព្រះវិហារឬមួយយ៉ាងម៉េច?

ភាពៈ អត់ទេ ទីរួមស្រុកទេ ។

សុវណ្ណៈ ចឹងទីរួមខេត្តព្រះវិហារពីមុន?

ភាពៈ ទីរួមខេត្តព្រះវិហារនៅនេះ នៅខាងអីកំពង់ប្រណាក កំពង់ប្រណាកខេត្តថ្មី ។

សុវណ្ណៈ មិនមែននៅខាងត្បែងមានជ័យទេ?

ភាពៈ ចាស!ត្បែងមានជ័យ ស្រុកត្បែងមានជ័យតើ ។

សុវណ្ណៈ ត្បែងមានជ័យដូរក្រោយតើ ចឹងទីរួមខេត្តសព្វថ្ងៃនៅត្បែងមានជ័យ?

ភាពៈ ចឹង ។

សុវណ្ណៈ ឬនៅជាំក្សាន្ត?

ភាពៈ ទេ ជាំក្សាន្តស្រុកជាំក្សាន្ត បើរាល់ថ្ងៃមីងមិនដែលបានទៅដែរ គេផ្លាស់ផ្លូវយ៉ាងម៉េចមីងមិនបានដឹងទេ ។

សុវណ្ណៈ ខ្ញុំចង់និយាយថា ទីរួមខេត្តរបស់ខេត្តព្រះវិហារ កាលមុនវានៅម្តុំណា?

ភាពៈ វាម្តុំដូចមីងថាមិញចឹងឯង តែទីរួមខេត្តមិនថានៅក្នុងស្រុកគូលេនមិនដឹងថានៅក្នុងស្រុកត្បែងមានជ័យ ទីរួមខេត្តហ្នឹង ។

សុវណ្ណៈ ចឹងរវៀងមិនមែនទីរួមខេត្តរបស់ខេត្តព្រះវិហារទេ?

ភាពៈ អត់ទេ ខេត្តព្រះវិហារដូចគ្នា តែទីរួមស្រុក ។

សុវណ្ណៈ ដូចជាខេត្តឧត្តរមានជ័យចឹង ទីរួមខេត្តគេនៅស្រុកសំរោង?

ភាពៈ ចាស ។

សុវណ្ណៈ ហើយនៅនេះជាស្រុកត្រពាំងប្រាសាទនិងស្រុកអន្លង់វែងទេ?

ភាពៈ ចាស ។

សុវណ្ណៈ នេះជាទីរួមស្រុក?

ភាពៈ ចាស!ទីរួមស្រុក ។

សុវណ្ណៈ តែទីរួមខេត្តនៅខាងស្រុកសំរោងនោះ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងខ្ញុំចង់ដឹងថា រវៀងមិនមែនជាទីរួមខេត្តរបស់ខេត្តព្រះវិហារទ?

ភាពៈ អត់ទេ តាំងពីដើមមក ។

សុវណ្ណៈ ចឹងគ្រាន់ជាទីរួមស្រុក?

ភាពៈ គ្រាន់ជាទីរួមស្រុក ព្រោះក្នុងខេត្តព្រះវិហារនេះ ស្រុករវៀងវាមានទីប្រជុំជនធំ ធំចង់ប្រហែលខេត្តគេ ។

សុវណ្ណៈ រវៀងហ្នឹងមីង?

ភាពៈ ចាស!ព្រោះមានប្រជាជនច្រើន មានអតិជនក៏ច្រើន មានមន្រ្តីរាជការច្រើន ហើយពួកសិស្សចំណេះចេះដឹងក៏ច្រើន មិនថាស្រីប្រុសកូនអ្នកមានអ្នកក្រទេ គឺកំរិតវប្បធម៌តាំងពីដើមមក អ្នកតូចអ្នកក្របំផុតហើយ កូនរៀនបានថ្នាក់ទី៧ទៅ៨ មិនដូចពួកយើងខ្លះកូន ខ្លះមិនបានរៀនសោះទេ ណាឲ្យតែម៉ាជួរស្រុករវៀង ច្រើនណាស់ នារីបានធ្វើគ្រូ ដល់ចឹងទី

រួមស្រុករបស់គេ ចៅហ្វាយស្រុក ពីដើមចៅហ្វាយស្រុករហូតមក គាត់ធ្វើកន្លែងទីរួមស្រុកខាងនេះ ព្រហ្មមុខបួន ។

សុវណ្ណៈ ចឹងពេលមីងត្រឡប់មកផ្ទះវិញ មកនៅជុំបងប្អូនមកធ្វើស្រែវិញ?

ភាពៈ មកនាំបងប្អូនធ្វើស្រែ ។

សុវណ្ណៈ ចឹងមកនៅបានប៉ុន្មានខែប៉ុន្មានថ្ងៃបានយើងនាំគ្នារត់ឡើងភ្នំវិញ កាលហ្នឹង?

ភាពៈ យើងគិតមើលយើងមកឆ្នាំ៧៨ ។

សុវណ្ណៈ ចឹងត្រឡប់មកផ្ទះវិញឆ្នាំ៧៨?

ភាពៈ ចាស!៧៨-៧៩ឆ្នាំ៨០មកនេះវិញ ។

សុវណ្ណៈ ចឹងចង់ដឹងថា មានមូលហេតុអី បានជាយើងចេញពីផ្ទះវិញរត់មកនេះវិញ?

ភាពៈ មូលហេតុវាមានច្រើនណាស់ក្មួយ ព្រោះអីពួកខ្ញុំមកពីក្រសួងមកនៅ ដល់ពេលមកនៅចេះទៅ យើងអត់មានឪពុកម្តាយ យើងចេះទៅនៅត្រង់នេះទៅ ដល់ពេលយើងមកជុំវិញបងប្អូនចេះតែមកទៅ ចឹងមានអ្នកស្រុកភូមិខ្លះគេមាត់មិននៅស្ងៀមណាស់ មកដល់គេសួរថាភូមិនេះមានអ្នកក្រសួងអ្នកអីមកវិញនៅតាមផ្ទះដែលអត់ ដល់ចឹងមានអ្នកភូមិនោះគេប្រាប់ថាក្រុមគ្រួសារនោះសុទ្ធតែពួកក្រសួងទេ សុទ្ធពួកមកពីក្រសួង ដល់ចឹងគេហៅប្រជុំអីទៅគេហៅបងប្រុសខ្ញុំនេះ ដល់ទៅប្រជុំចេះទៅក៏គេឲ្យបងប្រុសខ្ញុំហ្នឹង គ្រាន់តែប្រជុំហើយបងប្រុសខ្ញុំ កាលជំនាន់ប៉ុល ពត នោះគាត់ធ្វើគ្រូបង្រៀនណា កាលពីសង្គមគាត់បានរៀនថ្នាក់ខ្ពស់ដែរ គាត់បង្រៀននៅខេត្តកំពង់ចាម កាលពីដើមពីសង្គមសម្តេចសីហនុ ដល់ជំនាន់ប៉ុល ពត គេឲ្យគាត់ធ្វើគ្រូ ដល់ចឹងគាត់បង្ហាត់សិស្ស បង្ហាត់យូរៗទៅដល់ពួកខ្ញុំមកពីក្រសួងវិញក៏គាត់មកជុំវិញ ក៏គាត់នៅជាគ្រូបង្រៀន ដល់ចឹងមានមេភូមិមេអី មេឃុំដែលគេវៀតណាមចាត់តាំងនេះ គេមានការប្រណែនជាមួយបងខ្ញុំនោះ ដល់ប្រណែនថា ធ្វើគ្រូហើយសិស្សស្រឡាញ់ជាងគេអីចេះទៅ ដល់ចឹងគេរាយការណ៍ប្រាប់ខាងវៀតណាមថា បងប្អូនវាសុទ្ធតែក្រសួងទេ ហើយវាធ្វើគ្រូនេះ ធ្វើគ្រូដោយពេញចិត្តជាមួយវៀតណាមស្មោះត្រង់ទេវាមានគាំទ្រ ប៉ុល ពត មកពីក្រសួងគេចុះទៅ ដល់រាយការណ៍ចឹងទៅគេចាប់បងខ្ញុំយកដាក់គុក ។

សុវណ្ណៈ ចឹងបងមីងកាលសម័យហ្នឹងធ្វើគ្រូដែរ?

ភាពៈ ចាស ។

សុវណ្ណៈ ដល់ពេលខាងវៀតណាមចូលមកធ្វើគ្រូទៀត?

ភាពៈ មានធ្វើគ្រូអីពេលវៀតណាមចូលមកចាប់គាត់តែម្តង ។

សុវណ្ណៈ ចាប់តែម្ដងទៅ?

ភាពៈ ចាស!ចាប់តែម្ដង ចាប់គាត់យកទៅដាក់គុក រំលងបានប្រហែលជាមួយឆ្នាំបានគាត់រត់រួច កុំតែគាត់រត់បែបងាប់ ។

សុវណ្ណៈ ម៉េចចឹងមីង?

ភាពៈ មិនព្រួខ្ញុំនិយាយមិញថា គេចាប់គាត់ទៅ ដល់ចាប់គាត់ទៅខ្ញុំសួរមេគេថា មានមូលហេតុអី បានជាចាប់គាត់ ខ្ញុំមិនមែនឃាត់ហាមទេ ឲ្យតែគាត់មានកំហុស គាត់មានកំហុសអីឲ្យដឹងថា គាត់ខុស ខុសអីខ្ញុំចង់ដឹង មានគេបកប្រែខ្មែរថា បើគ្មានកំហុសគេមិនចាប់ទេ មានកំហុស បានចាប់ ដឹងហើយថាខុសតែខុសរឿងអី គាត់ធ្វើអីខុស វាថាមិនបាច់សួរទេ ចាំសួរនៅ កន្លែងស្រុក ហើយចាស់ទំមកកំពង់តែបង្រៀនសិស្សហ្នឹង នៅក្នុងសាលា គេទៅហៅពីសា លាមក មកដល់ចងព្រឹបបណ្ដោយ មានទាន់បាយណា ហើយគ្នាវាបណ្ដើរទៅខ្ញុំរត់តាមវា ចង់ហើយវានាំគ្នាស៊ីបាយ វាស៊ីបាយហើយមានខ្មែរអ្នកបកប្រែ វាចងឯងហើយវាសួរឯង ថា មិញអាអ្នកជាប់ចំណងឆ្ងាយដែលអី ឆ្ងាញ់ដែលឆ្អែតដែលអាអ្នកជាប់ចំណង គេយក ទៅដល់ប្រហែលជាបីម៉ោងខ្ញុំទៅតាម ខ្ញុំទៅដល់គេថាបញ្ជូនទៅអូរស្រក្រាចនៅរវៀងអីអូរ ត្រឡូងនោះ ថាគេបញ្ជូនទៅអូរស្រក្រាចបាត់ហើយ អត់មានសិទ្ធតវ៉ាទេចប់ហើយ ដេកគិត អង្គុយគិត ដល់ចឹងពួកខ្ញុំដឹងថាគេចាប់បង អាប៉ុន្មាននោះមកទាំងកងតែម្ដង មកដល់រឹបពួកខ្ញុំ គេចង់ក្របួចទាំងពូជតែម្ដង កុំបានមីងខ្ញុំទេ គាត់ថាក្បាលពីណាខុសសក់អ្នកនោះ អត់មាន ក្បាលអ្នកនេះហើយសក់អ្នកនោះទេ ចេះតែប្រម៉ែប្រមូលយ៉ាងម៉េច មិនទាន់រកខុសត្រូវ ស្រាប់តែយកមួយទៅដាក់គុកហើយប្រមូលទាំងពូជមិនបានទេ ម្ដាយមីងខ្ញុំនៅសង្កមថ្មីដល់ ចឹងឲ្យខ្ញុំមកនៅនេះ មកនៅមួយរយៈសិន ។

សុវណ្ណៈ មកនៅសង្កមថ្មីហ្នឹង?

ភាពៈ ចាស!មកនៅសង្កមថ្មី ។

សុវណ្ណៈ មកនៅជាមួយម្ដាយមីង?

ភាពៈ ចាស ។

សុវណ្ណៈ ម្ដាយមីងខាងឪពុកខាងម្ដាយ?

ភាពៈ ខាងម្ដាយ ម្ដាយថ្លៃទេ សាច់នោះខាងពូ ចុះប្អូនម៉ែខ្ញុំតែគាត់ស្លាប់ ស្លាប់ទៅនៅមីង ។

សុវណ្ណៈ ខាងមីងថ្លៃ?

ភាពៈ ចាស!ចឹងមកនៅនេះ មកនៅមីងខ្ញុំថា អញយកមកនៅនេះ មិនទៅធម្មតា នៅនេះនៅ ស្ដាប់ចឹង អាអ្នកគេយកទៅដាក់គុកគេយកទៅដល់ណាហើយ ខ្ញុំថាខ្ញុំក៏អត់ដឹងដែលខ្ញុំថាឲ្យ

ប្អូនខ្ញុំអាប្រុសៗទៅស៊ើប ទៅសួរបងខ្ញុំទៅដល់ណាដល់ណើ ទុកក្នុងអូរស្រក្រាច មានខ្មែរដែរ គេចេញចូលទៅ គេថាឃើញនៅហ្នឹងឯង ខ្ញុំសួរថាឃើញគេវាយគេតប់ទេ ឃើញគេដាក់ខ្នោះជើងទាំងពីរ គេដាក់ខ្នោះជើងទាំងពីរ សក់ក្បាលឡើងកន្រ្ទឹង ខ្ញុំប្រាប់ប្អូនថា ទៅសួរគេមើល លោសុំគេចូលទៅ ដល់សុំគេក៏មិនបាន ចុះរបងឡើងបីជាន់ របងលួសមួយជាន់ហើយមួយជាន់ទៀត គេដាក់បីជាន់ មានតែមុខទ្វារមួយច្រក ចឹងគាត់និយាយខ្លួនគាត់ចេញមក គាត់មានវៀតណាមនោះ គាត់និយាយប្រវត្តិគាត់ គាត់ថាគាត់ថាគ្រូបង្រៀននៅស្រុកនោះ ដល់ចឹងគាត់មកធ្វើការនៅស្រុកខ្មែរនោះ គាត់ការប្រហែលជា៥ឆ្នាំហើយគាត់ចេះខ្មែរ គាត់ចេះខ្មែរអស់អត់មាននិយាយប៉ែឡាំទេ គាត់ថាគ្រូវៀតណាមមួយហ្នឹងហើយឲ្យបាយទឹកគាត់ហូប ពេលគាត់យាមចឹងទៅគាត់យកបាយមួយកញ្ចប់ដាក់តាមខោ ស្រាប់តែហុចបាយចឹងទៅបានបាយហូប ទឹកគាត់ដាក់ដបចឹងទៅ មើលនាយអាយទៅគាត់យកទឹកទៅដាក់ក្នុងអាវឲ្យបងខ្ញុំហើយ ចឹងបានវៀតណាមមួយហ្នឹងឯង ផ្តល់បាយផ្តល់ទឹកឲ្យហូបនោះហើយបានវៀតណាមមួយហ្នឹងឯងចេញឲ្យរួចនោះ គាត់គ្រូបង្រៀន មានថ្ងៃមួយថ្ងៃនោះថ្ងៃសៅ ថ្ងៃគេដើរលេង ក៏គ្រូវៀតណាមនោះគេដើរទៅ គាត់សួរថា បងថ្ងៃនេះគេដើរលេងអស់ហើយ បងឯងរត់រួចទេ បើបងរត់រួចខ្ញុំដោះបង តែបើបងរត់យ៉ាងម៉េចឲ្យរួចបងរត់មិនរួចខ្ញុំក៏ងាប់ ផ្លូវទ្វារគេចាក់សោអស់ហើយ បើបងរត់បងរត់តាមណាបាន ចឹងបងខ្ញុំថា ចឹងឲ្យតែបងប្រលែងដកខ្នោះចេញពីជើងទៅ បងសំរួលឲ្យវាស្រួលសរសៃហើយចង់បងរត់ធ្លាក់របងក៏បាន ធាក់របងក៏បាន របងបីជាន់ ចឹងបើបងរត់រួចចាំខ្ញុំដោះលែងបងចឹងវៀតណាមហ្នឹងគាត់ដោះលែង ដល់លែងទៅគាត់ជួយលាបប្រេងក្រឡាជួយរឹតសំរួលហើយបងខ្ញុំចេញមក ចម្ងាយប្រហែលជា១០០ម៉ែត្រ ពេលហ្នឹងគាត់ធាក់តែពីរពឹងរបងដួលទៅរត់ព្រួចទៅ គាត់រត់បានប្រហែលជា៥០០ម៉ែត្រ បានពួកវាដឹងថាគាត់រត់ គាត់ថារត់ដល់ត្រពាំង រត់ថាគាត់ភ័យ គេអត់មានតាមសោះនិយាយថា គាត់រត់ៗដល់ទៅបាន៥០០ម៉ែត្រស្នូរបាញ់ពីក្រោយ ដល់បាញ់រកកន្លែងចេញមិនរួចទៅដល់ត្រពាំងហើយដល់បឹងធំ ចូលទឹកបឹង បាញ់ឡើងខ្ជាតទឹក បាញ់តាមព្រៃបាញ់អស់ គាត់ថាជាប់ប្រហែលជាបីម៉ោង ស្ងាត់ប្រហែលជាម៉ោង១ម៉ោង២ ហើយម៉ោង៣ បានស្ងាត់គាត់ឆ្លងរត់ឆ្លងថ្នល់ជាតិធ្លាក់ទៅស្មោងនោះ អាស្រ័យថាយប់វាវង្វេងណាស់ ចេះតែរត់ទៅ ។

សុវណ្ណៈ មីងនៅពេលនៅជាមួយម្តាយមីងនៅសន្តមថ្មី ក្រោយមកយ៉ាងម៉េចទៀត?

ភាពៈ អត់មានអីទេ ទៅធ្វើស្រែធម្មតា ដល់ចេញពីមីងខ្ញុំឡើងភ្នំមកនេះតែម្តង ។

សុវណ្ណៈ ចឹងមានមូលហេតុអីបានជាមីងឡើងភ្នំ?

ភាពៈ បងខ្ញុំរត់ចេញពីគុកមក ដល់បងរត់ចេញពីគុកទៅ អ្នកដែលចាប់បងខ្ញុំនេះវាភ័យវាខ្លាចពួកខ្ញុំនេះមានបាយមានទឹកបណ្តោះចិញ្ចឹមបងនៅតាមព្រៃ ដល់ហើយវាប្រុសជម្លៀសពួកខ្ញុំ វាប្រុងជម្លៀសទាំងអស់ ជម្លៀសទៅដាក់កណ្តាល ដើម្បីបងខ្ញុំរួចពីគុករស់ ក្រែកលោនេះគេទៅសួរខ្ញុំថា ឃើញបងមកនេះទេ ឥឡូវបងនាងឯងរួចហើយ រត់ចេញពីគុកហើយឥឡូវមានឃើញមកនេះដែលអត់ បើសិនជាមកនេះទេ កុំលាក់បើឃើញត្រូវតែបង្ហាញ ហ៊ានតែលាក់មានទោស ដល់ចឹងខ្ញុំថាវិញ ខ្ញុំថាបងខ្ញុំអស់លោកយកទៅហើយ មិនដឹងជាបាញ់ចោលណាឬសម្លាប់ដាក់គុកឯណាទេ ហើយមករករឿងបងប្អូន យកទៅរាប់ខែហើយបាត់មនុស្សស្រាប់តែមកសួររកហើយគំរាមអ្នកផ្ទះដាក់គុកដាក់ច្រវ៉ាក់ ពួកខ្ញុំមិនដឹងទេ ឥឡូវរកខ្លួនឯងទៅឆែកតាមផ្ទះទៅបើឃើញចាប់ទៅ ខ្ញុំមានឃាត់អី បើចាប់ទៅរាប់ខែមិនដឹងជាយកទៅសម្លាប់ចោលអីណាដាក់គុកណា រួចហើយ រួចប្រហែលជាកន្លះខែមុនហើយខ្ញុំថារួចតាមចាប់ទៅ បើឃើញនៅផ្ទះចាប់នៅផ្ទះទៅ បើមិនឃើញនៅផ្ទះទេ រកចាប់ទៅខ្ញុំមិនដឹងមិនឮទេ ព្រោះអស់លោកយកទៅខ្លួនឯង គ្រាន់មនុស្សមួយបងយកបងខ្ញុំ ៥០ទៅ៦០នាក់ហេតុអីបានជាការពារមនុស្សមួយមិនបានឲ្យគាត់រត់រួចឬក៏បាញ់ចោលបំបាត់ដាននៅណាទៅ ខ្ញុំថាឲ្យចឹង យី!កុំនិយាយជ្រៅៗពេកនិយាយឲ្យល្មមបន្តិច កោតក្រែងគេខ្លះថាឲ្យខ្ញុំ ខ្ញុំថាខ្ញុំមិនបានកោតក្រែងទេ ខ្ញុំលែងខ្លាច ខ្ញុំមិនខ្លាចទេ មិនខ្លាចចំពោះអ្នកឯងទេ ម៉េចចង់ផាប់គុកខ្ញុំថាឲ្យជាប់ៗខ្លាចអីគុក គុកសម្រាប់ដាក់មនុស្សឲ្យតែខុសដាក់ទៅ ខ្ញុំនឹកឃើញថា បើវាយកដាក់គុកអាប្អូនខ្ញុំប្រុសៗពីរបីនាក់ហ្នឹង ឲ្យវាចេញមកសហការជាមួយពួកព្រៃ ពួកព្រៃវាធ្លាប់ចូលស្រែខ្ញុំដែរ ពួកហ្នឹងមានកាំភ្លើងមានអីដែរ នឹកឃើញថាបើវាខ្ញុំដាក់គុកប្អូនខ្ញុំថា ដឹងថាពាក់កណ្តាលយប់វាចេញទៅដុតផ្ទះទាំងកូនទាំងប្រពន្ធតែម្តង បើអស់បងប្រុសមួយអស់បងស្រីទៀត ម្តងនេះកំហឹងកាន់តែឈ្លូល ។

សុវណ្ណៈ ចឹងមានន័យថា មីងនៅមានបងប្អូនពីរបីនាក់ទៀតដែលនៅរស់តាមជាមួយពួកខ្មែរក្រហម?

ភាពៈ ចាស ។

សុវណ្ណៈ អត់ទាន់ពេលហ្នឹងរត់ចូលតស៊ូជាមួយខ្មែរក្រហមនៅឡើយទេ?

ភាពៈ ទេ ប្អូនខ្ញុំអត់មានចេញពីខ្ញុំទេ នៅជាមួយខ្ញុំទាំងអស់ ចេញតែបងប្រុសទេ ដល់បងប្រុសគាត់រត់ទៅគាត់ជួបជាមួយពួកខ្មែរក្រហម ។

សុវណ្ណៈ ចឹងពេលបងប្រុសមីងរត់ទៅជួបជាមួយខ្មែរក្រហម?

ភាពៈ ចាស ។

សុវណ្ណៈ ជួបតាមផ្លូវ?

ភាពៈ ចាស!ដល់ទៅចូលជាមួយគេ គេឲ្យបាយទឹកឲ្យខោអាវស្បៀកពាក់ឲ្យអង្រឹងឲ្យអីទៅក៏គាត់នៅជាមួយគេ ដល់នៅជាមួយគេ គេអុកឡុកពួកខ្ញុំពេក ថ្ងៃមួយក៏គាត់ចូលទៅផ្ទះ ខ្ញុំទៅដងទឹកឃើញគាត់ឈរនៅគល់ ខ្ញុំក្រឡេកមើលចេះដូចជាមនុស្សឈរ ដាក់ប៉េាតចុះដើរទៅគាត់បោយដៃថាមកនេះ ខ្ញុំថាឃី!បង បងរួចពីគុកមែន ខ្ញុំអរអើយអរ ដល់ចឹងពួកវែងរស់នៅសុខសប្បាយ ខ្ញុំថាគេមកគំរាមរាល់ថ្ងៃ បងឯងរួចទៅគេចោទពួកខ្ញុំថាឲ្យបាយឲ្យអង្ករណាមកគំរាមរាល់ថ្ងៃ គាត់ថាមិនបាច់នៅទេតោះ រៀបខោអាវទៅស្អែកអញមកយកហើយណាប្រាប់ទាំងអស់គ្នាចឹង ស្អែកអញនាំកម្លាំងមកយក ស្អែកថ្ងៃប្រហែលជាស្មានេះ គាត់យកកម្លាំងមក ចេញមកនេះទាំងអស់ ។

សុវណ្ណៈ ចឹងកាលហ្នឹងឆ្នាំណាមីងរត់តាមបង?

ភាពៈ ឆ្នាំ៨០ ។

សុវណ្ណៈ ចឹងឆ្នាំ៨០ ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងរត់ទាំងបងទាំងប្អូនទាំងអស់គ្នាតែម្តង?

ភាពៈ ទាំងអស់ អត់មានពីណានៅទេ ។

សុវណ្ណៈ ទាំង៥ - ៦នាក់ហ្នឹង?

ភាពៈ ចាស!មិនមែន៦នាក់អី សឹងថាមួយភូមិនោះចេញមកទាំងអស់ ពួកខ្ញុំចេញក៏ចេញមកច្រើនតែម្តង ។

សុវណ្ណៈ ចឹងមានមូលហេតុអីបានជាមួយភូមិមកតាមគ្នាចឹង?

ភាពៈ អ្នកភូមិនោះពួកខ្ញុំចេញមក ពួកខ្ញុំចេញមកគេខ្លាចពួកវាហ្នឹងទៅអុកឡុកទៀត ដល់ចឹងឃើញពួកខ្ញុំចេញគេចេញដែរ ខ្ញុំថាពួកឯងអត់មានទោសចេញមកធ្វើអី គេថាមិនមានទោសក៏តែខ្លាច រស់នៅដាច់ៗពីគេខ្វះខ្លាចគេមកធ្វើទុក្ខទៅធ្វើទោសអីទៅ ម្យ៉ាងខ្លាចបងខ្ញុំគាត់ចូលទៅរកបងប្អូនខាងប្រពន្ធគាត់ ខ្លាចលិចឮដល់គេទៅខ្លាចគេមកធ្វើទោសធ្វើអី ខ្ញុំថាមកក៏មកទៅបងខ្ញុំថា មកក៏មកទៅ ទៅលើភ្នំទាំងអស់គ្នាទៅមិនស្អីទេ ដល់មក មករហូតដល់រាល់ថ្ងៃគេអ្នកមកជាមួយពួកខ្ញុំគេទៅវិញអស់ហើយ គេវិញទៅស្រុកទៅទេសវិញអស់ហើយ នៅតែពួកខ្ញុំមិនបានទៅវិញ ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងមក មីងខ្លាចទាហានវៀតណាមធ្វើបាបធ្វើអីទេ?

ភាពៈ ចាស!មកខ្លាចគេធ្វើបាប ។

សុវណ្ណៈ ខ្លាចគេចោទថា ចូលជាមួយខ្មែរក្រហមខ្មែរអី?

ភាព: ចាស! ថាយើងនៅជាមួយប៉ុល ពត ។

សុវណ្ណ: ថាយើងគាំទ្រ?

ភាព: ចាស! ថាយើងគាំទ្រមានបាយមានអង្ករចឹញ៉ាំមគ្នាទៅវិញទៅមក ដល់ចឹងគេមិនទុកចិត្តណាស់ ដល់មិនទុកចិត្តទៅយើងក៏ខ្លាចដែរ ចឹងយើងចេញឲ្យផុតៗមក ព្រោះអីបើគេជម្លៀសបងខ្ញុំ ជម្លៀសពួកខ្ញុំទៅបងខ្ញុំនៅនេះក៏គាត់មិនបានសុខ ខ្លាចថ្ងៃណាគាត់រក ទៅស៊ើបទៅអីគេចាប់ បានទៅវាមានគ្រោះធំចេះ សុខចិត្តមកទាំងអស់គ្នា ។

សុវណ្ណ: ចឹងកាលមីងតាមបងមកហ្នឹងឆ្នាំ៨០ហ្នឹង ថ្ងៃណាខែណា មីងមានចាំទេកាលហ្នឹង?

ភាព: ខ្ញុំអាចមកខែ១១ ព្រោះអីកាលនោះខ្ញុំធ្វើស្រែ ធ្វើស្រែហើយបោកស្រូវដាក់ផ្ទះបាន១០ ទៅ២០បេ ហើយហ្នឹង ដល់ចឹងមកចោលស្រូវ ស្រូវដឹកដល់ផ្ទះខ្លះនៅស្រែខ្លះហើយគោ លែងតាមស្រែ គោខ្ញុំប្រហែលជា៣០ក្បាលគោ គោនៅស៊ីពេញស្រែ ហើយស្រូវក៏នៅ ពេញស្រែ ច្រកបេៗឡើងសក្បោះ រៀបមកនិយាយពីស្អីៗនៅពេញត្រៀមត្រាមកមាន បានស្អីទេ ។

សុវណ្ណ: ដល់ពេលរត់ទៅជាមួយបង រត់ឡើងភ្នំទៅខាងណាវិញមីង ព្រោះភ្នំយើងមានតំបន់១០ ០១មាន១០០២មាន១០០៣?

ភាព: មកចូលមក១០០៣ ។

សុវណ្ណ: ចឹងមកចូល១០០៣?

ភាព: ចាស ។

សុវណ្ណ: ហើយ១០០៣ហ្នឹងនៅម្តុំខាងណាដែលមីង?

ភាព: ១០០៣ឡើងពីខាងផ្លូវស៊ីយ៉ង់មក មកដល់ស៊ីយ៉ង់មកតាម"ប៣១" មកចូលព្រៃស្អាក យើងក៏ដើរមកខាង១០០៣នេះច្រក ច្រកព្រះប្រឡាយ ។

សុវណ្ណ: មុនដំបូងមកតាមស៊ីយ៉ង់?

ភាព: ចាស ។

សុវណ្ណ: ចឹងស៊ីយ៉ង់នៅម្តុំណា?

ភាព: ស៊ីយ៉ង់កោះកែរយើងនេះ ចេញពីស៊ីយ៉ង់មកតាម"ប៣១" ។

សុវណ្ណ: ចឹងឡើងមកតាម"ប៣១"?

ភាព: ចាស ។

សុវណ្ណ: "ប៣១"ហ្នឹងជាកន្លែងស្អីគេ?

ភាព: "ប៣១"ជាកន្លែងកងទ័ពពីមុន ចឹងគេហៅ"ប៣១" ។

សុវណ្ណៈ ខាងកងទ័ពរបស់ខ្មែរក្រហមឬកងទ័ពខាងរដ្ឋាភិបាល?

ភាពៈ ខាងកងទ័ពរបស់ខ្មែរក្រហមដែរ ។

សុវណ្ណៈ ចឹងយើងមកតាមផ្លូវ«ប៣១»ហើយមកចូលតាមព្រៃស្អាក?

ភាពៈ ចាស!ព្រៃស្អាកកាត់មកតាមដុបរុន ។

សុវណ្ណៈ ចឹងឡើងមកដល់ដុបរុនសិន?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងដុបរុនហើយ?

ភាពៈ ដុបរុនហើយឡើងមកដល់១០០៣តែម្តង ។

សុវណ្ណៈ ចឹងក្រោយមកព្រះប្រឡាយ?

ភាពៈ ព្រះប្រឡាយដុបរុនហ្នឹងហើយ ។

សុវណ្ណៈ ចឹងព្រះប្រឡាយដុបរុនជាមួយគ្នាទេ?

ភាពៈ ចាស ។

សុវណ្ណៈ គេហៅឈ្មោះពីរ ព្រះប្រឡាយដុបរុន?

ភាពៈ ដុបរុនអីលើកន្ទែងពីភ្នំមក គេថាជប់ចេញទឹកអីណា ដល់ចឹងព្រះប្រឡាយនៅក្រោមនេះដល់ ចឹងគេប្រើឈ្មោះតែព្រះប្រឡាយ ។

សុវណ្ណៈ ចឹងដុបរុនហើយព្រះប្រឡាយ?

ភាពៈ ចាស ។

សុវណ្ណៈ ហើយមក១០០៣?

ភាពៈ ចាស!១០០៣នៅលើ ១០០៣អត់មាននៅនេះទេ ១០០៣នៅលើជិតព្រំដែនថៃ ។

សុវណ្ណៈ នៅជាប់អីគេរបស់ថៃ ឬស្រុកអីគេរបស់ថៃ?

ភាពៈ ១០០៣នៅជាប់ខេត្តស៊ីសាកេត ។

សុវណ្ណៈ ខេត្តស៊ីសាកេតស្រុកអីគេ?

ភាពៈ ដឹងស្រុកអី ស្រុកសំរោងហ្នឹងយ៉ាង ។

សុវណ្ណៈ ស្រុកខាងថៃណា?

ភាពៈ ចាស!ស្រុកសំរោងឬមួយអី ទេស្រុកសំរោងហ្នឹងឯង ។

សុវណ្ណៈ ចឹងតាមផ្លូវយើងធ្វើដំណើរប៉ុន្មានថ្ងៃបានមកដល់១០០៣នេះ?

ភាពៈ ច្រើនថ្ងៃណាស់ យើងដើរគេចយើងមានដើរមកសំដៅតែម្តងណា របៀបដើរគេចបំបែងដានណា យើងដើរបង្វែងដាន ដល់ទៅចេះទៅសភាពការណ៍មិនស្រួលទេ ឥឡូវយើងគេច

បកទៅចេះ ទៅចេះសភាពការណ៍តឹងតែងណាស់មិនស្រួលទេ ខ្លាចវាប៉ះវាស្កាត់ វាស្កាត់តាមផ្លូវណាស់ ដល់ចឹងវាកុងវាកេរច្រើនណាស់ ។

សុវណ្ណៈ តែយើងអាចប៉ាន់ស្មានបានទេ ថាមានប៉ុន្មានថ្ងៃប៉ុន្មានអាទិត្យប៉ុន្មានខែដល់?

ភាពៈ ៨ទៅ៩ថ្ងៃជិត១០ថ្ងៃ ឈឺផងអីផង ដាច់ស្បៀងផងអត់មានអីទេ ស្បៀងក៏ដាច់ឈឺក៏ឈឺ ពីដើមដើរបានយូរគ្រាន់ដល់យូរៗទៅ ពរកូនផងស្ពៀយផងចឹងដើរបាន១០០ម៉ែត្រចឹងទៅអង្គុយសិនទៅ ដើរបាន១០០ម៉ែត្រចឹងទៅអង្គុយសិនទៅ ជួនកាលក្នុងមួយថ្ងៃដើរបានតែ៥០០ម៉ែត្រអីទេ ខ្លះយកកូនទៅដាក់ចេះទៅ ហក់មកស្ពៀយអង្ករវិញ បកមកក្រោយណាស់ ជញ្ជូនបន្តិចៗហើយមានអ្នកឈឺក៏សែងទៅ គ្រុនដើរមិនរួចហើយគ្នាសែងធម្មតាសែងដើរកាត់ព្រៃ គ្នាមានការលំបាកប៉ះព្រៃ ប៉ះក្រលុកប៉ះអូរ ចឹងវាមានការលំបាកច្រើនទំរាំឆ្លងកាត់ដល់លើភ្នំ១០០៣ហ្នឹង ហើយដល់ឡើងលើភ្នំទៀត ។

សុវណ្ណៈ ចឹងខ្ញុំកាត់បន្តិចខ្ញុំចង់ដឹងថា ធ្វើដំណើរតាមផ្លូវមកហ្នឹង ជួបផលពិបាកបែបណាដែរ ចឹងខ្ញុំចង់សួរថាពេលយើងដាច់ស្បៀងអីយើងធ្វើយ៉ាងម៉េចទៅតាមផ្លូវអីមីង?

ភាពៈ មួយសារដាច់ស្បៀងអត់មានអីសោះ ។

សុវណ្ណៈ ចឹងយើងហូបចុកអីយ៉ាងម៉េច?

ភាពៈ អត់មានអីទេ គេយកស្បៀងពីលើភ្នំមកមិនទាន់ ហើយធ្វើដំណើរដាច់ភាគច្រើន ដល់ចឹងកូនតូចៗវាអត់មានបាយអូហូប អត់មានបាយប្រហែលជាបីពេលដែលណា ប្រហែលជាមួយថ្ងៃជាងដែលអត់ អត់ចឹងទៅជួបទ័ព ដល់ជួបទៅគេឲ្យអង្ករក៏មិនច្រើនទេ ដូចថាមួយគ្រួសារគេឲ្យពីរកំប៉ុង ដូចថាបួននាក់ចឹងទៅគេឲ្យមួយកំប៉ុងកន្លះ យើងប្រាំនាក់ទៅដូចថាគេឲ្យពីរកំប៉ុងណាស់ យកទៅបបរ បបរឲ្យកូនហូបចឹងទៅទំរាំតែឡើងដល់លើភ្នំ អត់បាយបីពេលដែលណា ។

សុវណ្ណៈ ចឹងយើងហូបអីគេ?

ភាពៈ អត់មានអីហូបសោះ ស្អីក៏អត់មាន មានតែទឹក ។

សុវណ្ណៈ ចឹងមានដឹកមើមក្តួចហូបទេ?

ភាពៈ មានអីបើខែប្រាំង យើងមានពេលណាបើយើងដើរខ្លាចសភាពការណ៍ស្ងាត់ស្ងៀមមានដើរមាត់ឡូឡាណា មនុស្សរាប់រយតែដើរទៅស្ងាត់ឈឹង ។

សុវណ្ណៈ មានដើរជួបទាហានវៀតណាមតាមផ្លូវគេកាក់បាញ់អីខ្លះទេ?

ភាពៈ អត់មានទេ បើជួបគេបាញ់តែយើងដើរបន្ទែនដាន ដើរគេចចឹងអត់មានជួបទេ ជួបដាក់តែម្តង គ្មានមេត្តាទេ តែវាអត់មានជួប ដើរដល់ជើងភ្នំចឹងទៅ មានសាប់ជួបខ្មោចឡើង៥ទៅ៦នាក់ ។

សុវណ្ណៈ ខ្មោចខាងណាវិញ?

ភាពៈ ខ្មោចពួកខ្មែរក្រហមយើងពួកទ័ពខ្មែរយើងហ្នឹង ។

សុវណ្ណៈ ស្លាប់ដោយសារអីគេ?

ភាពៈ ពួកវៀតណាមវាបាញ់ វាចុចខ្ទម៉ី វាចុចគ្រាប់ណាស់ វាចុចទៅសាប់អស់៥ទៅ៦នាក់ឡើងប្រងាំងដូចជាមនុស្សដេកមើលទៅ ពួកខ្ញុំថាព្រលឹងនៅចុងសក់ទេ បុណ្យឲ្យតែដល់លើភ្នំ បានមកដល់ឡើងមកលើភ្នំ១០០៣ហ្នឹង ។

សុវណ្ណៈ ចឹងយើងដេកពួនយ៉ាងម៉េចដែលក្នុងព្រៃហ្នឹងមីង?

ភាពៈ អូយ!លំបាកណាស់ ។

សុវណ្ណៈ លំបាកយ៉ាងម៉េច?

ភាពៈ យើងកាច់ស្លឹកឈើដាក់កន្ទេលនាំកូនដេកទៅ គ្មានមុងគ្មានអីទេ ។

សុវណ្ណៈ ចឹងពេលភ្លៀងមកអីនោះ?

ភាពៈ ពេលភ្លៀងមានកៅស៊ូហ្នឹង បើភ្លៀងនាំគ្នាអង្គុយទៅ ។

សុវណ្ណៈ ចឹងអត់មានបន្តដំណើរទៅមុខទៀតទេ?

ភាពៈ អត់ទេ ។

សុវណ្ណៈ ចឹងពេលធ្វើដំណើរតាមផ្លូវចឹងអារម្មណ៍យើងគិតយ៉ាងម៉េចពេលហ្នឹង?

ភាពៈ វានិយាយលែងចេញតែម្តង ដល់ចឹងមិនដឹងជានិយាយថាយ៉ាងម៉េច ។

សុវណ្ណៈ ដូចថាគិតចង់បកក្រោយទៅផ្ទះវិញ?

ភាពៈ គ្មានអារម្មណ៍នឹកឃើញថាទៅមុខមិនដឹងជាសាប់ទីណាកន្លែងណា ។

សុវណ្ណៈ គិតថាខ្លួនឯងនិងរស់ដល់កន្លែងហ្នឹងដែលអត់?

ភាពៈ មិនដឹងជាយ៉ាងម៉េច ចេះតែផ្សងព្រេងគេមក ម្នាក់ៗហានិយាយមកផ្សងព្រេងមិនដឹងជាថ្ងៃនេះមិនដឹងជាស្អែកទេ និយាយតែប៉ុណ្ណឹងឯង គ្មានអីថាបានវែងទៅមុខទៀតទេ ចុះបើវាលំបាករាប់អាទិត្យទៅហើយ ទេបើគេមនុសប្រុសមិនសូវអីទេ បើឯងស្រីនេះ ហើយមានក្មេងមានអីផង ប្អូនខ្ញុំអាពៅវានៅតូចដែរ ។

សុវណ្ណៈ ចឹងទៅដល់១០០៣ហ្នឹងមានពីណាគ្រប់គ្រងនៅហ្នឹងមីង?

ភាពៈ ទៅដល់នោះកងទ័ពគេមកទទួល ។

សុវណ្ណៈ	តែអ្នកគ្រប់គ្រងនៅតំបន់ហ្នឹងគាត់ឈ្មោះអីគេ?

ភាពៈ	កាលហ្នឹងពួកបងវឿន បងវឿន គាត់កងពលចុះមកទទួល ។

សុវណ្ណៈ	ស្អីវឿន មីងឈ្មោះពេញ ។

ភាពៈ	ឈ្មោះ អីវឿន ទេបងវឿន បងវឿន គាត់គ្រប់គ្រងទាហានហ្នឹងទាំងអស់ គ្រប់គ្រងកន្លែងមន្ទីរតែមុខសញ្ញា និយាយមួយម៉ាត់មកមុខសញ្ញាគាត់ ចឹងគាត់ឲ្យកម្លាំង៥០នាក់យកអង្ករ យកត្រីខ យកកៅស៊ូ យកអង្រឹងមកដើម្បីទទួលប្រជាជនទៅពីនេះ ដល់ទៅបានគេយកមកជំនួយ យកមកបានដាំបាយដាំអី ហូបចុកថ្ងៃហ្នឹងមួយថ្ងៃពីរ ព្រឹកឡើងបានបន្តដំណើរទៅធម្មតាអត់មានអីទេ ទៅដល់លើភ្នំហើយអត់មានយួនតាមបាញ់អីទៀតទេ ។

សុវណ្ណៈ	ចឹងលើភ្នំហ្នឹងយើងឡើងទៅមានផ្លូវអីឡើងទេ?

ភាពៈ	មានផ្លូវដើងយើងប៉ុននេះយើងដើរទៅ យើងដើរតាមថ្មទៅសឹកៗបន្តិចហ្នឹងណាស់ ចេះតែដើរតាមគ្នាទៅ ។

សុវណ្ណៈ	អត់មានរបៀបផ្លូវយើងឡើងនៅជាំទេ កៅស៊ូចឹងទេ?

ភាពៈ	អត់ទេ ផ្លូវប៉ុននេះសោះផ្លូវរុកព្រៃទៅ ស្បៀយអីរាងធំបន្តិចប៉ះព្រៃ ។

សុវណ្ណៈ	ចឹងពេលឡើងដល់១០០៣ ពីណាគ្រប់គ្រងនៅតំបន់១០០៣ហ្នឹង កងពលណា?

ភាពៈ	កងពលធំរបស់គេ កន្លែងបងវឿន តែម្ដង កងពលបងវឿន ដឹងថាកងពលប៉ុន្មានទេ កាលមុនគេហៅពួកប្រាំសាប ។

សុវណ្ណៈ	ហើយពីណាគេជាអ្នកគ្រប់គ្រងធំនៅហ្នឹងមីង?

ភាពៈ	ប្រពន្ធបងវឿន ។

សុវណ្ណៈ	ខ្ញុំចឹងនិយាយទាំងអស់តែម្ដង ប្រធានកងពលធំគ្រប់គ្រងតំបន់១០០៣តែម្ដង?

ភាពៈ	មានតែតាវឿន ហ្នឹងគ្រប់គ្រងកម្លាំងទាំងមីងៗទាំងពូៗទាំងអស់ ព្រោះគាត់កងពលធំ ទាំងឃ្លាំងនិងសេដ្ឋកិច្ចអីនៅលើគាត់ទាំងអស់ ។

សុវណ្ណៈ	ចឹងមីងមានដឹងថា កងពលធំរបស់គាត់លេខប៉ុន្មានទេ?

ភាពៈ	កងពលមិនដឹងលេខទេ ។

សុវណ្ណៈ	ចឹងឈ្មោះ បងវឿន អ្នកគ្រប់គ្រងនៅហ្នឹង?

ភាពៈ	ចាស ។

សុវណ្ណៈ	មិនមែន សុន សេន អីទេ?

ភាពៈ	ទេ សុន សេន ពួកខ្ញុំមិនស្គាល់ទេ នៅ១០០៣អ្នកដែលគ្រប់គ្រងធំជាងគេប្រធានមានរដ្ឋមន្ត្រីខាងភាគតែម្ដងមានតែតាម៉ុក ទេ មានតែតាម៉ុក មួយទេ ក្រៅពីនោះសុទ្ធតែអ្នករងៗ

ទេ បើអ្នកស្មើ សុន សេន ស្មើតាខៀវ សំផន ស្មើតាប៉ុល ពត អី មានតែតាម៉ុក ទេ ដែលគាត់មានមុខមាត់ប៉ុនគ្នាណា មានតែតាម៉ុក មួយទេ បើនៅ១០០១ខ្ញុំមិនសូវស្គាល់ទេ កាលនោះគេហៅ កែ ពក កាលនោះ បើខាងនេះមានតែតាម៉ុក ទេ ។

សុវណ្ណៈ នៅ១០០៣?

ភាពៈ ១០០៣មានតែតាម៉ុក ទេ មានតែតាម៉ុក ទេគាត់ក្តាប់មួយប្រកខាងនេះ និយាយទៅ ជំនាវហ្នឹងទាំងអស់ ។

សុវណ្ណៈ ចឹងមិញខ្ញុំមិនទាន់ច្បាស់នៅ១០០៣ ខ្ញុំចង់ដឹងថា មានប៉ុន្មានកងពលនៅ១០០៣ហ្នឹងមីង ខាងទ័ពខាងអី?

ភាពៈ មីងមិនដឹងទេ គ្រាន់ឃើញច្រើនៗចេះ មិនថាប៉ុន្មានមីងមិនបានដឹងដែរ ។

សុវណ្ណៈ ប៉ុន្តែនៅគ្រប់គ្រងធំនៅ១០០៣ នៅប្រចាំតំបន់តែម្តងមានពីណា មីងស្គាល់ទេ?

ភាពៈ អ្នកគ្រប់គ្រង១០០៣ អ្នកគ្រប់គ្រង កាលមុនអ្នកគ្រប់គ្រង១០០៣ទាំងអស់មានតាមុត កូនប្រសារតាម៉ុក អាហ្នឹងគាត់គ្រប់គ្រងទាំងអស់ ឪពុកគាត់ទៅនេះទៅណោះទៅគ្រប់គ្រង ទាំងអស់ មានបងមុត គាត់ជាអ្នកគ្រប់គ្រង ។

សុវណ្ណៈ ហើយតាមុត ហ្នឹងគាត់កាន់កងពលណា?

ភាពៈ គាត់មិនដឹងជាកាន់កងពលណាទេ កន្លែងរួមទាំងអស់អ្នកទៅបើកសម្ភារ បើកគ្រាប់បើកកាំភ្លើង បើស្អីៗទាំងអស់ ឃើញតែយកពីកន្លែងគាត់ មិនដឹងជាគាត់កងពលអី ភាគច្រើនគេ ហៅកន្លែងតាមុតៗ តែមិនដឹងជាកងពលប៉ុន្មានទេ មីងមិនបានដឹងដែរ ឃើញពួកតារឿន ទៅបើកដាក់កន្លែងឃ្លាំងគាត់ក៏ទៅយកកន្លែងតាមុត ។

សុវណ្ណៈ ហើយតារឿន ហ្នឹងគាត់នៅកងពលណា?

ភាពៈ តារឿន គាត់កងពលដែលតែគាត់កាន់មួយផ្នែកៗ បើតាមមុត គាត់កាន់រួមទាំងអស់តែ ម្តង គាត់ក្តាប់ទាំងមីងៗ គាត់ក្តោបក្តាប់ទាំងកងទ័ព គាត់ក្តោបក្តាប់សេដ្ឋកិច្ចអ្វីៗទាំងអស់ លើតាមុត ណាស់ បងរឿន គាត់ក្តោបក្តាប់មីងៗតែកន្លែងគាត់ ហើយកម្លាំងគាត់មានចុះ ទៅវាយ តាមុត គាត់មិនមែនចុះវាយទេ គាត់នៅចាត់ចែងទាំងអស់ ។

សុវណ្ណៈ ចឹងមីងពេលឡើងទៅដល់គេឲ្យមីងធ្វើអីគេ?

ភាពៈ ឡើងទៅដល់ហ្នឹងធម្មតា មានតែដាំបាយដាំបន្លែ គេឲ្យកន្លែងធ្វើផ្ទះធ្វើអី កាប់ឈើធ្វើផ្ទះ បេះស្លឹកធ្វើផ្ទះអីទៅ គេចែកឆ្នាំងចែកអង្ករចែកអំបិលប្រហុកប៊ីចេងអីគេឲ្យ គេឲ្យដីធ្វើផ្ទះគេ ឲ្យអី អង្ករអីប្អូនទាំងអស់ យកពីឃ្លាំងមកនាំគ្នាទូរែកមក ។

សុវណ្ណៈ ចឹងបងប្អូនមីងនៅជុំគ្នាទាំងអស់ឬមួយបែកគ្នា?

ភាពៈ មិនទាន់បែកទេមកជុំទាំងអស់ ។

សុវណ្ណៈ ចឹងប្អូនៗហ្នឹងគេឲ្យធ្វើអីវិញ?

ភាពៈ ប្អូនពៅមួយគេឲ្យរៀន នៅអង្គភាពកុមារ បើអាមួយនោះគេមិនទាន់ឲ្យទៅណាដែលទេ គេឲ្យនៅមួយឆ្នាំដែរ ជួនកាលជួយកាប់ឫស្សីឲ្យគេបិតចំរូងណាស់ វានៅស្ទើរដែរ គេមិនទាន់ឲ្យធ្វើទាហានទេ បើអាមួយនោះជាប់ឈ្មោះធ្វើទាហាននិងគេអាបន្ទាប់ពីខ្ញុំវាធំដែលហើយ ។

សុវណ្ណៈ ចឹងចុះឈ្មោះចូលធ្វើទាហានចុះឈ្មោះជាមួយកងពលណា លេខប៉ុន្មាន?

ភាពៈ ចូលកងពីសេសគេចូលកងពិសេស កងស្មើដើងមិនដឹងជាកងពលណាទេ មេគេអ្នកគ្រប់គ្រងឈ្មោះ តានីម ឥឡូវគាត់ចូលប៉ារ៉ាអីក៏បាត់ខ្លួនទៅ ។

សុវណ្ណៈ ឈ្មោះអីគេ?

ភាពៈ ឈ្មោះ តានីម ។

សុវណ្ណៈ ចឹងតានីម ហ្នឹងអ្នកប្រមូលកម្លាំង ប្រជាជនឲ្យចូលខាងទ័ព?

ភាពៈ ចាស!ព្រោះគាត់ជាអ្នកក្តាប់កងទ័ព កងពិសេស ចង់និយាយថា កងភាវមីនកងឈានមុខនោះណា ឧទាហរណ៍ថា យួនមកទីកន្លែងនេះអី មានទ័ពខ្លះគេឲ្យមកស៊ើបអត់ហ៊ានមកទេ ខ្លាចណាស់ ដល់ខ្លាចចឹងទៅបានយួនវាឡើងដល់ឡើភ្នំវាវាយវាអី ដុតឃ្លាំងដុតអីយើង បើកងពិសេសគេអត់មានទេ បើដាក់ដឹងថាដល់តែម្តង និយាយទៅមិនសូវវាយទេ កងស៊ើបការនិយាយទៅ ពួកពីសេសគេថយចេញ ។

សុវណ្ណៈ ចឹងមីងនៅលើហ្នឹងអត់មានធ្វើអីសោះតែម្តង គេឲ្យយើងដញ្ជូនគ្រាប់អីដែរ?

ភាពៈ ចាស!ដញ្ជូនគ្រាប់ អត់ទេ ខ្ញុំកាលនោះគេអត់ឲ្យដញ្ជូនគ្រាប់ទេ ។

សុវណ្ណៈ ចឹងចូលដឹបូង?

ភាពៈ ចូលដឹបូងខ្លះដញ្ជូនគ្រាប់ អ្នកដែលអត់មានកូនឲ្យជួយដឹកដញ្ជូន អ្នកដែលមានកូនគ្រាន់តែលីឫស្សីនិងបិតចំរូង ។

សុវណ្ណៈ ចឹងមីងកាលហ្នឹងមានកូនហើយនៅ?

ភាពៈ ខ្ញុំមានហើយ ។

សុវណ្ណៈ ចឹងមីងនៅផ្ទះបិតចំរូង?

ភាពៈ ចាស!បិតចំរូង ខ្ញុំលើឫស្សីយកមកបិតចំរូង ខ្ញុំលីចំរូងនេះចុះមកក្រោម យកមកឲ្យកងទ័ពនៅនេះ ចុះតាមជណ្តើរ៥០មក ។

សុវណ្ណៈ គេមានកំណត់ឲ្យយើងថា មួយថ្ងៃយើងធ្វើបានប៉ុន្មានទេ?

ភាពៈ មួយថ្ងៃគេឲ្យធ្វើ៣០០ ។

សុវណ្ណៈ ចឹង៣០០ចំរូង?

ភាពៈ ចាស ។

សុវណ្ណៈ គេទៅកាប់ឲ្យយើង ចឹងយើងធ្វើនៅផ្ទះទៅ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងចំរូងហ្នឹងមានលាបអីពីលើចំរូងហ្នឹងទេ?

ភាពៈ អត់មានលាបទេ គ្រាន់តែបិតធម្មតាៗ បើចំរូងគេមានលាបនេះលាបនោះ ចំរូងសាងគេលាប ។

សុវណ្ណៈ គេលាបអីគេមីង?

ភាពៈ ហ្នឹងមានថ្នាំពីសរបស់គេ មានស្វមានថ្នាំមានអី គេលាបតាមចំរូងគេចឹងទៅ តែអាហ្នឹងគេធ្វើតិចទេ គេថាធ្វើចំរូងពីសអីណា អាហ្នឹងមានអ្នកជំនាញគេធ្វើ អត់មានធ្វើច្រើនទេ ធ្វើតិចទេ គេធ្វើដាក់កន្លែងណាពិសេសរបស់គេ ព្រោះអាហ្នឹងធ្វើច្រើនទៅខ្វាចគ្នាយើងអត់ប្រយ័ត្នអីទៅ បើមានមុតបន្តិចដឹងថាចប់ហើយ ។

សុវណ្ណៈ យ៉ាងម៉េចទៅមីង?

ភាពៈ មុតវាមានពីសដូចជាពស់ខាំចឹង មុតបន្តិចហើមដល់ណាដល់ណី រលួយរឡេះអស់ទៅមើលមិនជា ដល់ចឹងអាហ្នឹងគេមិនចង់ធ្វើច្រើនទេ ធ្វើច្រើនគ្រោះថ្នាក់ ។

សុវណ្ណៈ ចឹងចំរូងហ្នឹងវាមានប៉ុន្មានប្រភេទមីង តាមមីងធ្លាប់ធ្វើ?

ភាពៈ ចំរូងដែលធ្លាប់ធ្វើវាមានពីរប្រភេទ ។

សុវណ្ណៈ មានចំរូងអីខ្លះ?

ភាពៈ មួយចំរូងលៀតមួយចំរូងសាង ។

សុវណ្ណៈ ចំរូងលៀត?

ភាពៈ ចំរូងលៀត ។

សុវណ្ណៈ ចំរូងសាង?

ភាពៈ ចាស!ចំរូងសាងដាក់ដើមបុស្សីបានគេដាក់ចំរូងសាងពីរចំរូងលៀត ។

សុវណ្ណៈ ចឹងសូមម្តងទៀត ចំរូងលៀត?

ភាពៈ ចំរូងសាង ។

សុវណ្ណៈ សាង?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងចំរូងលៀតហ្នឹង ចំរូងប្រភេទយ៉ាងម៉េច?

ភាពៈ ចំរូងលៀត អាហ្នឹងមានប្រវែងនេះ ហ្នឹងគេវាស់មួយចង្អាមៗគេបិតធម្មតា គេបិតដូចយើងបិតកន្ទុយអន្ទង់ហ្នឹងណាស់ អាហ្នឹងគេអត់មានបិតនិងកាំបិត អាកាំបិតបន្ទួសយើងធម្មតាទេ អាហ្នឹងកាំបិតផ្កាកយើងអាធំ អាហ្នឹងគេបិតបាន ទៅដល់យើងគ្រាន់តែដាន់បេះហើយ គេពុតបេះទៅគេទាញផ្តាច់ៗៗបោះ អត់មានឲ្យយើងបិតបេះៗអត់ទេ បើថាយើងចង់បិតកាំបិត ដាច់ខាងនេះដាច់ខាងនោះ អត់មានឲ្យបិតច្រើនកាំបិតទេ បិតច្រើនវាអស់ជាតិផ្អែលវា គេចង់បិតយ៉ាងម៉េចឲ្យមានជាតិផ្អែលដូចជាមុខកាំបិត។

សុវណ្ណៈ ចឹងគេបិតវាតែមួយកាំបិតទេ?

ភាពៈ ចាស។

សុវណ្ណៈ ចឹងគេបិតសំរួចវា?

ភាពៈ ចាស!ចិតវាងសំប៉ែតដូចជាកន្ទុយអន្ទង់ចឹង អាហ្នឹងយកតែមួយកាំបិតទេ អាហ្នឹងចំរូងលៀត។

សុវណ្ណៈ ចឹងអ្នកដែលបិតចំរូងច្រើនតែអ្នកមានគ្រួសារ មានកូនអីនៅផ្ទះបិតទៅ?

ភាពៈ ចាស។

សុវណ្ណៈ ចឹងពេលអ្នកនៅលីវទៅជញ្ជូនគ្រាប់អីទៅ?

ភាពៈ ចាស!ទៅជញ្ជូនគ្រាប់។

សុវណ្ណៈ ចឹងមួយថ្ងៃគេកំណត់ឲ្យមីងបិតបាន៣០០?

ភាពៈ ចាស!៣០០។

សុវណ្ណៈ ចឹងយើងធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ភាពៈ មួយភ្លេច បិតក្លួយឯងមកអង្គុយនេះមីងបិតបានរាប់ពាន់ហើយ។

សុវណ្ណៈ តែគេកំណត់តែ៣០០ទេ?

ភាពៈ ចាស!៣០០ បើមួយថ្ងៃយើងបិតបាន២០០០ទៅ៣០០០ទុកទៅ អាប៉ុន្មានថ្ងៃយើងទំនេរទៅ។

សុវណ្ណៈ ចឹងពេលទំនេរយើងធ្វើអីទៀត?

ភាពៈ ទំនេរយើងដាំបន្លែដាំអីទៅ មានមាន់ទា មានគោ ណាស៊ី បើទំនេរយើងដាំបន្លែ ដាំអីដាំខ្ទឹមដាំស្ពៃ ដាំឆៃថាវអីទៅ ពូជគាត់ទិញឲ្យទាំងអស់ ពិបាកតិចតួចទេ។

សុវណ្ណៈ ចឹងចំរូងសាងគេធ្វើបែបម៉េចទៅ?

ភាពៈ ចំរូងសាងគេធ្វើវែង។

សុវណ្ណៈ ប្រវែងវាប៉ុន្មានមីង?

ភាពៈ ចំរូងសាងប្រវែងនេះ ។

សុវណ្ណៈ ត្រឹមដើមដៃ?

ភាពៈ ចាស! ចំរូងសាងចង់ប្រវែងនេះ ។

សុវណ្ណៈ ប្រវែងដៃតែម្ដង?

ភាពៈ ចាស! ប្រវែងដៃតែម្ដង អាហ្នឹងចំរូងសាង អាហ្នឹងចំរូងសាងគេយកតែគល់ឫស្សីទេ ។

សុវណ្ណៈ គេយកគល់ឫស្សី?

ភាពៈ ចាស! គេយកគល់ឫស្សី ឫស្សីណាដែលរាងល្អៗបន្ទិចអាហ្នឹងគេដាក់ឫស្សីវែងចង់ប្រហែល ចង់៥ម៉ែត្រចេះទៅ គេចោះដាក់ដូចថាឫស្សីកណ្ដាលចេះទៅ គេចោះដាក់ចេះទៅ អាខាង នេះផុះមកខាងនេះ គេចោះពាក់កណ្ដាលម្នាក់ណា ចង់ពាក្យកណ្ដាលចេះទៅ ដូចថាគេ រមៀលទៅកន្លែងណាក៏ប៉ះកន្លែងណាក៏ប៉ះ ប៉ះគ្រប់កន្លែង ក្ដួយឯងមិនដែលបានឡើងព្រះ វិហារទេ ឥឡូវវាអត់មាន កាលជំនាន់ខ្មែរក្រហមមានចំរូង ចំរូងគេដាក់បីសង្កាត់ ។

សុវណ្ណៈ ចឹងចំរូងលៀតហ្នឹងគេដាក់បង្កប់ក្នុងដី?

ភាពៈ គេដោតតាមដី ដីចឹងៗគេដោត ។

សុវណ្ណៈ យើងដីកដីទៅ គេដោតវាទៅ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងដីលើហ្នឹងយើងយ៉ាងម៉េច?

ភាពៈ ចាស! យើងដោតចឹងទៅ យើងដោតជ្រួសគ្នាចឹង ។

សុវណ្ណៈ ចឹងយើងដីកជារណ្ដៅមួយ?

ភាពៈ អត់មានដីកទេ ដើរដោតដីរាបហ្នឹងទៅ ភ្លើងឆេះមកក៏ឆេះទៅ ។

សុវណ្ណៈ ចឹងដោតលើដីចោលចឹងគេមិនឃើញទេ?

ភាពៈ ចឹងបើគេឃើញក៏ឃើញទៅ គេមិនឃើញមុតទៅ អាណាដែលវានៅជ្រៅលិចចុងវាមុតទៅ អាណាដែលគេឃើញហើយក៏ឃើញទៅ ។

សុវណ្ណៈ ចឹងគេធ្វើជាចំរូងហ្នឹង មិនមែនគេជីកជារណ្ដៅអីមួយដើម្បីគេបង្កប់ចំរូងហ្នឹងទេ?

ភាពៈ អាហ្នឹងគេមានបញ្ឆោតគេ គេឃើញមានរណ្ដៅមានមីន ។

សុវណ្ណៈ ចឹងជាទូទៅចំរូងលៀតហ្នឹងគេដោតនៅលើដីយកតែម្ដង?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងចំរូងសាង?

ភាពៈ ចំរូងសាងអាហ្នឹងគេដាក់ទៅតាមមាត់ច្រក គេដាក់តាមកន្លែងពើយៗ ដីលៀតបេះគេមិនដាក់ទេ យើងខទាហរណ៍ឲ្យឆាប់យល់ ដូចជាប្រាសាទព្រះវិហារ ថាមានបីច្រក ឥឡូវមានបីច្រកគេដាក់ចំរូងសាងចូល ព្រោះច្រកគេធ្លាប់ឡើងគេដាក់ចំរូងសាងតាមច្រក គេដាក់ចំរូងសាងឡើងយ៉ាងម៉េចរួច ឡើងមិនរួចទេ ព្រោះចំរូងសាងវាសំបើមណាស់ គេដាក់ទៅចំដីថៃ គេដាក់ទៅខាងប្រាសាទទី១ មុខនាគហ្នឹង គេដាក់ចំរូងសាងហ្នឹងបីសង្កាត់ កាលជំនាន់នៅខ្មែរក្រហម ដល់មកវាមិនមករួចពីចំរូងសាងហ្នឹងទេ ចំរូងលៀតគេដាក់សម្រាប់អ្នកស៊ើបការណ៍មកតាមព្រៃអី វាមកប៉ះទៅវាមុតទៅ វាមិនប៉ះក៏អីទៅ តែជំនាន់តាម៉ុក ប្រើចំរូងសាងដឹងថាឆេះអីហ្នឹងគេប្រើចំរូងដែកតែម្ដង ចំរូងដែកដឹកមករាប់ម៉ឺនតោនតែម្ដង បោះយកតែម្ដងបោះខាងណាក៏ជាប់បោះខាងណាក៏នៅដែរ ចុះវាឡើងបីជ្រុងហើយ យើងក្រវិតទៅបេះចេញអាជ្រុងនោះ ត្រឡប់ទៅខាងណាក៏នៅតែចេញជ្រុងដែរ ឃើញវាស្រួចហើយ វាមានឆៀងដូចជាផ្លែសន្ទូចទៀត ហ្នឹងជំនាន់តាម៉ុក ដល់ពេលបើកយុទ្ធនាការខ្ញាំងពេក គ្រួសារទ័ពវាប្រមូកប្រមូលអត់បាននៅកន្លែងសមរភូមិចិនគេយកឲ្យទ័ព យកទៅបោះប្រវែងនេះទៅផ្លូវមនុស្សនៅនេះ ទៅដល់បោះតាមព្រៃអីបេះតែបោះទៅ ទៅយកទៀតចំរូងដែក ។

សុវណ្ណៈ ចឹងពេលមីងនៅ១០០៣ហ្នឹង មីងមានផ្លាស់ទៅណាទៀតដែលអត់?

ភាពៈ អត់មានផ្លាស់ទៅណាទេ នៅចឹងផ្លាស់ទៅនោះអូរធំទៅនៅអីអូរ៨០នោះ តាមជាយដែនទៅបេះ ។

សុវណ្ណៈ ចឹងអត់មានផ្លាស់ទៅនៅ១០០១-១០០២អីទេ?

ភាពៈ អត់ទេ ១០០១គេអត់មានប្រមូកប្រមូលទេ ព្រោះអង្គភាពគេផ្សេង បើ១០០៣ថាទៅនៅកន្លែងណានៅជុំគ្នា ។

សុវណ្ណៈ ចឹង១០០៣ហ្នឹងខាងភ្នំដងរែកខាងណាវិញមីង?

ភាពៈ ភ្នំដងរែកហ្នឹង១០០៣ ។

សុវណ្ណៈ ចឹងខាងកន្ទុយនាគអីនោះ ទន្លេល្ពៅអីនោះ?

ភាពៈ ទន្លេល្ពៅនៅខាង១០០១-១០០២ ។

សុវណ្ណៈ ចឹងទន្លេល្ពៅ១០០១-១០០២ទេ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងទន្លេល្ពៅទៅខាងណាវិញ?

ភាពៈ ទន្លេល្ពៅទៅបេះ ទៅខាងពួយព្រិចអីនោះ ។

សុវណ្ណៈ	ចឹងនៅខាងជាំសាងាំនេះនៅ១០០៣?

ភាពៈ	ច្រកជាំ ជាំសាងាំ គេហៅឆសាងាំ ។

សុវណ្ណៈ	កាលពីមុនគេហៅអីគេ?

ភាពៈ	អត់ដឹង ។

សុវណ្ណៈ	៨០៨?

ភាពៈ	៨០៨ទៅខាងលិចទៀតនោះ ទៅស្រែប្រិយ៍នោះ ។

សុវណ្ណៈ	ស្រែប្រិយទេ?

ភាពៈ	ចាស!អានោះគេហៅមួយជួរក្បាលទន្លេវាងនោះ ក្បាលទន្លេវាងនៅជាំសាងាំហ្នឹង ។

សុវណ្ណៈ	ចឹង១០០៣យើងនេះ?

ភាពៈ	១០០៣នៅជុំបរុន ។

សុវណ្ណៈ	ចឹងយើងនៅលើហ្នឹងរហូតអត់មានផ្លាស់ទៅណាទេ អត់មានរត់អីទេ?

ភាពៈ	ចាស ។

សុវណ្ណៈ	ចុះពេលខាងទាហានវៀតណាមគេវាយមក យើងរត់ទៅដល់ណាទៀតពេលហ្នឹង យើងរត់ចេញពី១០០៣ទៅខាងណាទៀត?

ភាពៈ	រត់ពី១០០៣ទៅនៅអូរធំ វាមិនដឹងជាទៅខាងទៀតក្អួយអើយវាច្រើនណាស់ វាទៅតាមភ្នំទេណាស់ យើងអត់មានដីរាបទេ យើងដើរតាមភ្នំហ្នឹងតែម្តង ។

សុវណ្ណៈ	តែយើងទៅនៅម្តុំណាកាលហ្នឹង ពេលចេញពី១០០៣ ទាហានវៀតណាមគេវាយមក?

ភាពៈ	ទៅនៅកន្លែងវាលដងទង់ ហើយទៅភូមិធ្នង់ ចេញពី១០០៣ទៅកន្លែងវាលដងទង់រួចហើយបានទៅនៅជិតកន្ទ្រេងភូមិថៃ នៅប្រហែលបានមួយអាទិត្យចេះទៅបាន តាម៉ុក ប្រាប់ឲ្យថយទៅនៅតាមព្រំដែនទៅលិចចេះទៀត ។

សុវណ្ណៈ	ចឹងកាលទាហានវៀតណាមវាយឡើងមក១០០៣នៅឆ្នាំណាមីងមានដឹងទេ?

ភាពៈ	ឆ្នាំ១៩៨៣ ។

សុវណ្ណៈ	ចឹងឆ្នាំ៨៣វាយមក?

ភាពៈ	ចាស!ឆ្នាំ៨៣ខែ៣ថ្ងៃទី២០ហ្នឹងជំនាន់តាម៉ុក ដែលវាយយុទ្ធនាការបុកខ្លាំងមែនទែនឆ្នាំ៨៣ហ្នឹង ។

សុវណ្ណៈ	ចឹងពេលវាយមកយើងចូលទៅដីថៃ?

ភាពៈ	ចាស ។

សុវណ្ណៈ	ចឹងនៅតាមលើភ្នំនៅឡើយទេ?

ភាពៈ យើងនៅលើភ្នំ ។

សុវណ្ណៈ តែយើងចូលទៅនៅដីថៃហើយ? .

ភាពៈ ដីងដីថៃ ដីយើងវាមានដូចចេះណា វាចង់ស្មើខ្នងភ្នំចេះណា គ្រាន់តែដើរទៅជិវាលបន្តិចដល់ដីថៃហើយ ។

សុវណ្ណៈ ចឹងពេលគេវាយចូលមកយើងចូលទៅនៅខាងដីថៃខាងអូរធំ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងអូរធំជំរំអូរធំមីង?

ភាពៈ ជំរំតាម៉ុក ទាំងអស់កន្លែងអូរធំ គាត់ឲ្យទៅនៅហ្នឹងឲ្យវាផុតពីថៃឲ្យផុតពីទាហានយួន ទៅនៅនោះភូមិថៃដែរ នៅភូមិធ្នង់នៅជិតវត្តថៃ ។

សុវណ្ណៈ គេហៅវត្តអីគេមីង?

ភាពៈ គេហៅវត្តធ្នង់ ទៅចេះៗសុទ្ធតែភូមិថៃ ខាងរំទងខាងភ្នំដីខាងកាត្រាវខាងភូមិចងក សុទ្ធភូមិថៃ ។

សុវណ្ណៈ ចឹងពេលឆ្នាំ៨៣វៀតណាមវាយចូលហ្នឹងយើងចូលទៅនៅខាងដីថៃហើយ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងឆ្នាំណាយើងរត់មក១០០៣វិញ?

ភាពៈ អត់ទេ ពេលរត់ រត់រហូត ។

សុវណ្ណៈ ចឹងអតមានរត់ត្រឡប់មកវិញទេ?

ភាពៈ ចាស!អត់មានត្រឡប់មកទេ ។

សុវណ្ណៈ ចឹងរត់រហូតចុងក្រោយយើងរត់ទៅដល់ណា?

ភាពៈ រត់ចុងក្រោយរត់ទៅនៅជាំស្វា ។

សុវណ្ណៈ ចឹងជាំស្វាហ្នឹងខាងដីថៃ?

ភាពៈ ចាស!ជាំស្វាដីថៃ យើងនៅគៀកថៃចេះ ព្រឹកឡើងថៃវាយកឥវ៉ាន់មកលក់ឲ្យយើងរាល់ថ្ងៃហ្នឹង វាមកលេងអី កាលនៅជាំស្វា ។

សុវណ្ណៈ ជាំស្វាហ្នឹងជាភូមិជាំស្វាឬជាអីគេ?

ភាពៈ ដីថៃ តែដល់យើងទៅគ្នាច្រើនទៅបង្កើតជាភូមិខ្នងផ្ទះរាប់រយទៅណាស់ តាម៉ុក គាត់ចុះកុងត្រាជាមួយថៃរយៈប៉ុន្មានអីប៉ុន្មានឆ្នាំអីឲ្យគ្រួសារទ័ពនៅ បើផុតកិច្ចសន្យាឲ្យយើងមកវិញមកកាលហ្នឹង ។

សុវណ្ណៈ ពេលទៅហ្នឹងយើងធ្វើអីគេមីង?

ភាពៈ	អត់មានធ្វើអីទេ នៅផ្ទះធម្មតាដល់ដាច់ខែបើកអង្ករ ។

សុវណ្ណៈ	ចឹងរបបបើក?

ភាពៈ	របបបើករហូត ។

សុវណ្ណៈ	ប៉ុន្មានអាទិត្យបើកម្តងឬមួយអាទិត្យបើកម្តង?

ភាពៈ	មួយខែបើកម្តង ។

សុវណ្ណៈ	ចឹងរបបគេមានអីគេខ្វះកាលហ្នឹង?

ភាពៈ	របបជួនពេលមានជួនពេលអត់ បើគេបើកអង្ករអំបិលប្រហុក ប៊ីចេងស្ករ ខ្ទឹម ។

សុវណ្ណៈ	អត់មានខ្វះខាតអីទេ?

ភាពៈ	អត់មានខ្វះអីទេ បើតាមគ្រួសារមួយៗតែម្តង បើអង្ករមានគ្នា៦នាក់ បាន៦ប៉ោតដែរ គេអត់មានគិតក្មេងចាស់ទេ គេគិតម្នាក់មួយប៉ោតតែម្តង ។

សុវណ្ណៈ	ចឹងយើងមានរកស៊ីអីទាក់ទងជាមួយថៃអីទេ ពេលដែលនៅហ្នឹង?

ភាពៈ	គេអ្នករក រកបានដែលណា គេអ្នកធ្វើរកអីបាន ធ្វើម៉េចកុំប៉ះពាល់ ឧទាហរណ៍យើងធ្វើនំលក់ឲ្យថៃ យើងធ្វើអីធម្មតាយើងធ្វើមិនបានទេ ពីព្រោះអីយើងនៅចង្កោមរដ្ឋ រដ្ឋគេក្តោបក្តាប់តាំងពីបាយអង្ករ គេចិញ្ចឹមរាប់ឆ្នាំគ្រប់បែបគ្រប់យ៉ាង ចឹងយើងធ្វើនំលក់ចូលហៅប៉ោខ្លួនឯង គេថាយើងនៅមានកម្មសិទ្ធក្រាស់ ចង់បានលោភលន់ទៀត ចឹងវាខុស ចឹងយើងនៅម៉ារស់ បើចង់ស៊ីឈ្នួលថៃ ចឹងព្រឹកឡើងទៅស៊ីឈ្នួលថៃទៅ ជួយដកដំឡូងវាទៅក្នុងមួយថ្ងៃ២០០បាត ល្ងាចឡើងមកផ្ទះទៅ ។

សុវណ្ណៈ	ចឹងពេលហ្នឹងមានចាយលុយដែរ?

ភាពៈ	ចាយសុទ្ធតែលុយបាតខ្ញុំមិនស្គាល់លុយខ្មែរទេ ខ្ញុំទើបស្គាល់លុយខ្មែរច្បាស់នៅឆ្នាំ២០០២ទេ កាលផ្តាច់ខ្លួនដំបូងខ្ញុំមិនទាន់ស្គាល់ផង មិនដឹងជាមួយម៉ឺនខ្មែរយ៉ាងម៉េចប្រាំពាន់ខ្មែរយ៉ាងម៉េច នៅទីទើៗដល់បានពីរបីឆ្នាំបានខ្ញុំស្គាល់ច្បាស់ ។

សុវណ្ណៈ	ចឹងកាលហ្នឹងចាប់ផ្តើមចាយលុយថៃ ចាប់ពីពេលណាមក?

ភាពៈ	ចាយលុយតាំងពីយើងនៅតាមព្រំដែនថៃហ្នឹង ចាយលុយថៃរហូត ។

សុវណ្ណៈ	ចឹងយើងចាប់រត់១០០៣ចូលឆ្នាំ៨០យើងចាយភ្លាមតែម្តង?

ភាពៈ	ចាស!ចាយរហូត ។

សុវណ្ណៈ	តែមីងទៅដល់បានគេចាយឬគេចាយមុនមីងទៅដល់?

ភាពៈ	គេចាយមុនយូរហើយ យើងទៅដល់ចាយក្រោយគេ មុនដំបូងគ្រាន់លុយថៃចាយរាយៗលុយគេម៉េចទេ ពាក្យចាស់ថាលុយដូចមានព្រលឹងម៉េចទេ ។

សុវណ្ណៈ ចឹងមឹងមានចំឡែកទេ យើងនៅនេះអត់មានចាយលុយអីចឹង មឹងទៅដល់ឆ្នាំ៨០មានចាយលុយអីចឹង យើងគិតថាធ្វើយ៉ាងម៉េចបានជាបានលុយកាក់អី ពេលហ្នឹងព្រោះថាយើងនៅតាមព្រៃយើងអត់មានលុយកាក់អីទេ?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងពេលទៅដល់គេចាយលុយធ្វើម៉េចបានមានលុយចាយ?

ភាពៈ យើងទៅស៊ីឈ្នួលគេទៅណា យើងមានអីលក់ បើយើងធ្វើអីលក់វាប៉ះពាល់ យើងស៊ីអង្ករដ្ឋ រដ្ឋផ្ដាត់ផ្ដង់ទាំងអស់ ចឹងយើងធ្វើយ៉ាងម៉េច មានតែស៊ីឈ្នួលគេ ទៅដកសណ្ដែកដីទៅជួយដកឥឡឹក ជួយកាច់ពោតគេទៅឬជួយដកដំឡូងអីហ្នឹងវាបានហើយ បានលុយចាយ ។

សុវណ្ណៈ កាលហ្នឹងមឹងទៅធ្វើអីគេ កាលហ្នឹង?

ភាពៈ ខ្ញុំមានធ្វើស្អីខ្ញុំប្រូតស្បៀ បងប្រុសខ្ញុំអ្នកប្រូតខ្ញុំអ្នកក្រង ក្រងបាន១០០ទៅ៣០០ក្រដបបេះទៅឡានគេមកដល់ទិញទៅ គិតមើលមួយក្រដបវា១០បាតតើ យើង១០០ក្រដបទៅវាបាន១០០០បាត់ហើយដល់ចឹងធ្វើបាន៣០០ក្រដបបានហៅគេមក ។

សុវណ្ណៈ ចឹងមឹងប្រូតស្បៀធ្វើក្រដបលក់ទៅ?

ភាពៈ ចាស!ធ្វើស្បៀលក់ខ្ញុំបិតស្រាលក់ ។

សុវណ្ណៈ ចឹងមានបិតស្រាទៀត?

ភាពៈ ចាស!ធ្វើមេស្រាលក់ ។

សុវណ្ណៈ ចឹងមឹងមានធ្វើអីទៀត បងប្អូនផ្សេងៗ?

ភាពៈ បងប្អូនផ្សេងៗគ្មានអីទេ ខ្ញុំអ្នកឈឺពោះលិចកើត ជួយសម្រាលគេលិចកើត គេជូនទាយអាយទៅក៏វាបានមួយទប់ៗ ។

សុវណ្ណៈ ចឹងយើងធ្វើរបស់របរលក់ឲ្យខ្មែរយើងឬមួយលក់ឲ្យថៃ?

ភាពៈ ធ្វើលក់ខ្មែរគ្នាឯង បើថៃគេមកក៏គេទិញទៅ ខ្មែរនៅនោះក៏ទិញគ្នាឯងបន្តិចបន្តួច ចឹញ្ចឹមជ្រូកអីបានដែលតើ ចឹញ្ចឹមជ្រូកលក់ឲ្យថៃ ចឹញ្ចឹមជ្រូកបានអង្កររួមមែន ទៅសុំគេអាពុកៗទៅនៅបាតឃ្លាំងមួយបាវពីរបាវមកយើងបបរបាយជ្រូកទៅ យកទៅធ្វើមេស្រាទៅ មេស្រាដុំប៉ុននេះ ធ្វើម្ដងមានតែ៥០០ទៅ១០០០ដុំអី លក់ឲ្យថៃខ្លះ ខ្ញុំបិតខ្លះទៅ ។

សុវណ្ណៈ ចឹងទាហានអីរកស៊ីជាមួយថៃគេរកស៊ីអីខ្លះទៅ គេដោះដូរជាមួយថៃទៅ?

ភាពៈ អត់មានពីណាហ៊ានទេ ។

សុវណ្ណៈ គេរកស៊ីដោះដូរធំៗអីមានទេ?

ភាពៈ អត់មានទេ អត់ហ៊ានតែម្ដង ។

សុវណ្ណៈ	មានរកស៊ីដោះដូឈើឬដោះដូជាវត្ថុបុរាណអីទេ?

ភាពៈ	អត់មានទេ ។

សុវណ្ណៈ	មីងមានដឹងរឿងហ្នឹងទេ?

ភាពៈ	អត់ដឹងទេ ។

សុវណ្ណៈ	ចឹងលុយកាក់ខាងទ័ពគេបានមកពីណា?

ភាពៈ	ហ្នឹងតាម៉ុក គាត់បានពីណាមក ដឹងគាត់ទាក់ទងជាមួយថៃ ដឹងថាគាត់យកអីទៅទូទាត់ដោះដូលុយចែកមកទាំងគីប ៗ ឲ្យទ័ពនោះ ។

សុវណ្ណៈ	ចឹងមីងមានដឹងថារបស់របរទាំងអស់ហ្នឹង មានដឹងថាគាត់បានមកពីណាទេ ដើម្បីបានយកមកផ្គត់ផ្គង់ប្រជាជននៅតំបន់ហ្នឹង?

ភាពៈ	មិនដឹងជាគាត់បានពីណាមក ចេះតែឆ្ងល់ដែរ ទោះបីប្តីខ្ញុំគាត់ក្តោបក្តាប់ទ័ពយកលុយយកជំនួយពីតាម៉ុក មកឡើងទាំងគីប ៗ តែមិនដឹងជាគាត់បានពីណាមក មិនដឹងជាលុយគាត់ធ្វើអី បានជាគាត់មានលុយច្រើន តែតានោះបានតែកម្លាំងកងទ័ពទេ កូនចៅគាត់គ្មានសិទ្ធអីទៅកាន់លុយទេ កូនចៅគាត់ក្រដូចតែគេដែរ ។

សុវណ្ណៈ	ចឹងយើងចុះមកពីភ្នំអីយើងចុះមកតាំងពីឆ្នាំណាដំបូង?

ភាពៈ	ចុះមកនៅដីនេះឆ្នាំ៩៨ ។

សុវណ្ណៈ	អត់ទេខ្ញុំចង់និយាយថា ដំបូង?

ភាពៈ	ចុះពីភ្នំមកដំបូងនៅឆ្នាំ៩០ ។

សុវណ្ណៈ	ចឹងឆ្នាំ៩០ហ្នឹង យើងចុះមកពីខាងណាវិញ?

ភាពៈ	ចុះពីដាំស្វាមក ។

សុវណ្ណៈ	ដាំស្វាហ្នឹងនៅខាងណាវិញ?

ភាពៈ	ដាំស្វានៅខាងសំរោងគៀតដីថៃ ។

សុវណ្ណៈ	មីងចង្អុលមើលនៅខាងណាវិញ?

ភាពៈ	មើលម៉ាដូរនេះទៅចេះ ។

សុវណ្ណៈ	ចឹងមួយដូរខាងនេះទៅចេះវិញ?

ភាពៈ	ចាស!ផ្លូវខាងសំរោងគៀតខាងផ្លូវគីឡូលេខ៩ ដីថៃ ។

សុវណ្ណៈ	ចឹងចុះមកនៅកន្លែងណាកាលហ្នឹង?

ភាពៈ	ខ្ញុំចុះមកនៅព្រះប្រឡាយហ្នឹង ។

សុវណ្ណៈ	នៅខាងព្រះប្រឡាយខាងជើងភ្នំ?

ភាពៈ ចាស!នៅជាប់ជើងភ្នំ ដីខ្ញុំនៅត្រង់កន្លែងឡើងស្ពានខាងនេះមួយ ដីខ្ញុំប្រកកណ្តាល ឥឡូវខ្ទុរខ្ញុំឡើងប៉ុនៗនេះ ។

សុវណ្ណៈ ឥឡូវព្រះប្រឡាយហ្នឹងគេហៅភូមិអីគេ?

ភាពៈ គេហៅភូមិព្រះប្រឡាយហ្នឹង ។

សុវណ្ណៈ ចឹងភូមិរបស់កងពលមុនគេហៅភូមិកងពលអីគេ?

ភាពៈ អត់មានហៅកងពលទេ គេហៅព្រះប្រឡាយតែម្តង ។

សុវណ្ណៈ តែគេមានកងពលលេខអីគេខ្លះទេមីង ដូចជាភូមិ១០៥?

ភាពៈ អត់ទេ ។

សុវណ្ណៈ ដូចជានៅខាងផ្សារអីគេមានភូមិ១០៥?

ភាពៈ ចាស ។

សុវណ្ណៈ ចឹងខាងព្រះប្រឡាយនេះមានភូមិអី?

ភាពៈ អត់មានគេហៅតែព្រះប្រឡាយ ។

សុវណ្ណៈ ចឹងគេហៅព្រះប្រឡាយរហូតទៅ?

ភាពៈ ចាស!ភូមិព្រះប្រឡាយឃុំព្រះប្រឡាយ ។

សុវណ្ណៈ តែមានកងពលណាគេគ្រប់គ្រងទេកាលហ្នឹង?

ភាពៈ មិនដឹងជាកងពលណាទេ ក្មួយអើយ មានកងពលច្រើនមិនដឹងជាណាណី ។

សុវណ្ណៈ ចឹងពីណាគេប្រធានភូមិព្រះប្រឡាយហ្នឹងមីង?

ភាពៈ កាលមុនតាពឿន ។

សុវណ្ណៈ តាពឿន?

ភាពៈ ចាស ។

សុវណ្ណៈ តាពឿន ហ្នឹងគាត់មកពីខាងណាវិញ?

ភាពៈ តាពឿន ពួកចាស់ពីមុនមក ឥឡូវគាត់ឈប់ហើយ គាត់ធ្វើមេឃុំឥឡូវគាត់ឈប់ហើយ គាត់ផុតអាណត្តិមេឃុំ ។

សុវណ្ណៈ គាត់មេឃុំណាឥឡូវ?

ភាពៈ ឥឡូវគាត់ឈប់ធ្វើមេឃុំហើយ ។

សុវណ្ណៈ ចូលនិវត្តហើយ?

ភាពៈ ចូលនិវត្តហើយគាត់ឲ្យអ្នកផ្សេងធ្វើ ។

សុវណ្ណៈ គាត់ធ្វើមេឃុំព្រះប្រឡាយហ្នឹង?

ភាព៖ ចាស ។

សុវណ្ណ៖ ចឹងព្រះប្រឡាយហ្នឹងនៅក្នុងស្រុកត្រពាំងប្រាសាទដែលទេ?

ភាព៖ ចាស ។

សុវណ្ណ៖ យើងទៅដល់ខាងណាវិញ ព្រះប្រឡាយទៅតាមផ្លូវណាវិញ?

ភាព៖ នេះទៅផ្លូវនេះ ។

សុវណ្ណ៖ ផ្លូវនេះដដែល យើងទៅត្រង់រហូត?

ភាព៖ ចាស ។

សុវណ្ណ៖ ចឹងវានៅជើងភ្នំទេ?

ភាព៖ ចាស!នៅជើងភ្នំទឹចុះព្រះប្រឡាយទាំងអស់ ត្រពាំងបីនេះក៏ព្រះប្រឡាយដែរ តែឥឡូវគេរៀបភូមិថ្មីហើយអាចគេរៀបឃុំភូមិថ្មីអីដឹង ទេនៅទេ នៅឃុំព្រះប្រឡាយដដែល ឃើញប្រធានឃុំថ្មីគេធ្វើការនៅហ្នឹង នៅទឹកដីព្រះប្រឡាយដដែលហ្នឹងឯង ។

សុវណ្ណ៖ ចឹងមីងចុះមកនៅហ្នឹងជាប់ឆ្នាំ៩០ហ្នឹង ឬយើងមានរត់ឡើងទៅវិញម្តងទៀត?

ភាព៖ អត់ទេ ចុះមកនៅហ្នឹងរហូត ចុះមកនៅព្រះប្រឡាយនេះបានផ្លាស់ទៅនោះ ។

សុវណ្ណ៖ ចឹងពេលឆ្នាំ៩០យើងចុះមកនៅព្រះប្រឡាយហ្នឹង យើងនៅមកនៅរហូតអត់មានខាងទាហានវៀតណាមទាហានរដ្ឋាភិបាលគេវាយតបទៅវិញទេ?

ភាព៖ ចាស!មានវាយទៀតតើ ។

សុវណ្ណ៖ ចឹងយើងមានរត់ម្តងទៀតទេ?

ភាព៖ ចាស!រត់ម្តងទៀត តែមិនបានឡើងទេ រត់តាមជាយជើងភ្នំទៅចេះ ។

សុវណ្ណ៖ រត់ដល់ណាវិញកាលហ្នឹង?

ភាព៖ រត់ទៅនៅអូរជីក រត់ទៅដល់១០៥នោះ ។

សុវណ្ណ៖ ចឹងទៅដល់ផ្លូវ១០៥ហ្នឹង?

ភាព៖ ហ្នឹងហើយទៅដល់ហ្នឹងរត់ទៅបានគេទប់ស្កាត់ទៅបាននៅនោះនៅៗរហូតទាល់ដល់ឆ្នាំ៩៨ចប់បណ្តោយ ។

សុវណ្ណ៖ ចឹងមានន័យថា ឆ្នាំណាយើងរត់ម្តងទៀត?

ភាព៖ អត់មានឆ្នាំណាទេ ។

សុវណ្ណ៖ រត់ឆ្នាំ៩០ដដែល?

ភាព៖ ចាស!ដែលរត់ចេញទៅពីនេះ៩៥ ។

សុវណ្ណ៖ រត់ចេញពីព្រះប្រឡាយ?

ភាពៈ ចាស!ឆ្នាំ៩៥ ។

សុវណ្ណៈ ចឹងឆ្នាំ៩៥រត់ម្ដងទៀត?

ភាពៈ ចាស!៩៥រត់ពីនេះទៅនៅនោះ ។

សុវណ្ណៈ ទៅនៅភូមិ១០៥?

ភាពៈ ទៅនៅខាងនេះ១០៥ណា នៅមួយជួរខាងអូរជីកអី ។

សុវណ្ណៈ ចឹងយើងចេញពីព្រះប្រឡាយឆ្នាំ៩៥?

ភាពៈ ចាស ។

សុវណ្ណៈ កាលហ្នឹងមានមូលហេតុអីបានយើងចេញទៅ?

ភាពៈ ពួកយួនវាយ វាយខ្លាំងណាស់ វាយដុតជង្រុកស្រូវអស់ និយាយពីរត់ចោលស្រូវចោលផ្ទះចោលសំបែង ខ្ញុំអត់មានស្អីទេ មានអីមានតែរទេះមួយនិងក្របីមេ និយាយបរក្របីវាក្ដៅផងថាចង់ងាប់ក្របី អត់មានទឹកអីទៀតក្លួយអើយ វេទនារកនិយាយមិនចេញទេ ។

សុវណ្ណៈ កាលហ្នឹងពីណាដឹកនាំកម្លាំងរត់មីង៩៥ហ្នឹង ?

ភាពៈ តាញឿន មេភូមិហ្នឹងឯង អ្នកនាំទៅពិបាកទាំងអស់គ្នាហ្នឹងណាស់ ចេះតែរត់គេចទៅបើនៅនេះទៅខ្លាចទាហានយួន ក្រែងទាហានខ្មែរឡើងមកខ្លាចលោយើងទប់មិនឈ្នះ ចឹងយើងដកឃ្លាឲ្យឆ្ងាយទៅ ស្រណុកគេទប់បើមិនឈ្នះយ៉ាងណាក៏វាបានឆ្ងាយគ្រាន់យើងចេះតែដកឃ្លាទៅ ។

សុវណ្ណៈ ចឹងកាលហ្នឹងគេបោះឆ្នោតឆ្នាំ៩៣ មីងមានបានទៅបោះនិងគេទេ?

ភាពៈ អត់ដឹងដងក្លួយអើយ ។

សុវណ្ណៈ ចឹងមានបានដឹងថាគេបោះឆ្នោតអីទេ គេមានផ្សព្វផ្សាយប្រាប់ដែលអត់ខាងយើងនេះ?

ភាពៈ អត់មានទេ ។

សុវណ្ណៈ ចឹងពត៌មានយើងទទួលបានយ៉ាងរបៀបយ៉ាងម៉េច តាមដានពត៌មានសភាពការណ៍ ពត៌មានយើងតាមដានឬយើងមិនតាមដានទេ ឬមានគេផ្សព្វផ្សាយប្រាប់ដែលឬអត់ទេ?

ភាពៈ អត់ទេ មីងមិនដែលបានស្ដាប់អីផង បើដឹងសភាពការណ៍ត្រូវផ្លាស់ បើទៅក៏ទៅនិងគេទៅគ្មានបានដេញដោលថាពត៌មានវាចេះវាចុះអីអត់មានទេ មីងមិនសូវជាអ្នកចង់ដឹងចង់ឮអីឲ្យតែមេនាំរត់ៗមេឲ្យឈរៗឲ្យអង្គុយៗ ។

សុវណ្ណៈ ចឹងឆ្នាំ៩៥រត់ទៅនៅជិតភូមិ១០៥?

ភាពៈ ទៅនៅខាងអូរជីក ។

សុវណ្ណៈ ចឹងពេលយើងទៅនៅអូរជីកហ្នឹងទៅនៅបានប៉ុន្មានឆ្នាំមីង?

ភាពៈ ទៅប៉ុន្មានទៅបានបីឆ្នាំ ចឹងឆ្នាំ៩៨យើងរត់មកនេះវិញ យើងទៅពីនេះយើងទៅឆ្នាំ៩៥ ឆ្នាំ ៩៥-៩៦-៩៧-៩៨ក្មួយឯងគិតមើល ។

សុវណ្ណៈ ចឹងសមាហរណ៍កម្មហើយមីងមកនេះវិញ?

ភាពៈ ដល់ពេលចឹងយើងរត់មកនេះវិញ សមាហរណ៍កម្មយើងនេះ ។

សុវណ្ណៈ ចឹងមានន័យថា ពេលរត់មកនៅនេះវិញមិនទាន់មានសមាហរណ៍កម្មទេ?

ភាពៈ វានៅទេ វាមិនទាន់សមាហរណ៍កម្មទេ គេគ្រាន់តែដកដាលអី វានៅទន្ទិចគ្នា វាដំឡើង ប្រេងដាក់គ្នាថាឯងថាអញណា ។

សុវណ្ណៈ ចឹងឆ្នាំ៩៨មកខែណាកាលហ្នឹង?

ភាពៈ ទេ មកខែណាមុនចូលឆ្នាំមកខែ៣ ។

សុវណ្ណៈ ហើយមកនៅដំបូងមកនៅហ្នឹងតែម្តងមីង?

ភាពៈ ចាស! នៅដំបូងនៅហ្នឹងតែម្តង ។

សុវណ្ណៈ នៅដីនេះតែម្តង?

ភាពៈ ចាស! នៅដីនេះឯង ដីនេះម្ចាស់គេមាន ម្ចាស់គេកាលពួកខ្ញុំចុះពីភ្នំមកពួកខ្ញុំនៅព្រះប្រឡាយ គេនៅអង្គភាពនេះ គេមកនៅដីនេះ គេនៅកន្លែងនេះ កន្លែងតា០៥ កន្លែងពួកខ្ញុំ ពួកតាពឿន នៅនោះ ដល់ពេលឆ្នាំ៩៥នេះ រត់ទៅនោះទាំងអស់គ្នា ៩៨មានសមាហរណ៍កម្ម ពេលគេឲ្យចេញពីនោះមក ខ្ញុំក៏មកនេះវិញ មកស្នាក់នៅដីគេទេ ខ្ញុំអត់មានទេ ដីខ្ញុំនៅតាមជើងភ្នំនោះ ដល់ពេលនេះខ្ញុំសុំគេនៅ ខ្ញុំសុំនៅសិន ចាំខ្ញុំរកកន្លែងនៅបានខ្ញុំដកចេញពីកន្លែងនេះ ខ្ញុំមិនយកទេដីនេះ ខ្ញុំនៅមួយរយៈ ដល់ពេលខ្ញុំចេះតែនៅទៅៗ ម្ចាស់ដីគេហ្នឹងគេព្រមលក់ឲ្យខ្ញុំ គេថាភាព ឯងមានលុយចេញយកទៅ ខ្ញុំសុំតែលុយ១០០០បាតទេ ដីនេះគេយក១០០០បាត ដីវាមានព្រៃដែលកាលនោះ ។

សុវណ្ណៈ ចឹងមីងចូលមកនៅដំបូងភូមិនេះគេហៅភូមិអីគេមីង?

ភាពៈ ភូមិទំនប់ដាច់ ។

សុវណ្ណៈ ចឹងគេមិនមែនហៅភូមិតា០៥ទេ?

ភាពៈ កន្លែងមន្ទីរ០៥ តែភូមិទំនប់ដាច់ ។

សុវណ្ណៈ កន្លែងរបស់គាត់នៅណាមន្ទីរ០៥ហ្នឹង?

ភាពៈ នោះមន្ទីរ០៥នៅខាងក្រោយនោះ កន្លែងអគ្គរាល់ថ្ងៃហ្នឹង ។

សុវណ្ណៈ អគ្គអីគេ?

ភាពៈ អត្តគេសម័យសមាហរណ៍កម្មនោះ អត្តគេមកនៅគេដាក់កន្លែងអត្តគេទៅដល់ពេលនេះ គេចេញទៅផ្ទះសំបែងអី ផ្ទះគាត់នៅតើតែគេរុះរើ កូនចៅគាត់នៅនេះតើតា០៥ហ្នឹង កូនគាត់នៅនេះតើ ។

សុវណ្ណៈ កូនគាត់ឈ្មោះអីគេ?

ភាពៈ កូនគាត់អាវិន្ត អាវី ។

សុវណ្ណៈ មាស សាវី ហ្នឹងកូនប្រុសឈ្មោះ សាវីហ្នឹង?

ភាពៈ អត់ទេ កូនគាត់មានបី អាប្រុសឈ្មោះ សាវេន សាវិន្ត សាវី ។

សុវណ្ណៈ ចឹងសាវេន សាវិន្ត សាវី?

ភាពៈ ចាស!អាសាវិន្ត នោះប្រុស ។

សុវណ្ណៈ តា០៥ឈ្មោះ គាត់ហៅឈ្មោះស្អីគេ?

ភាពៈ ឈ្មោះ គាត់គេហៅ សូរ សារឿន ។

សុវណ្ណៈ ចឹងសូរ សារឿន?

ភាពៈ ចាស!តា០៥ ។

សុវណ្ណៈ មីងមានដែលឃើញគាត់ដែរ?

ភាពៈ នៅជាមួយគ្នាឡើងរហូត ។

សុវណ្ណៈ ពេលដែលចូលមកនៅគាត់ជាអ្នកគ្រប់គ្រងនៅហ្នឹងតែម្ដង?

ភាពៈ ខ្ញុំមកនៅនេះគេយកគាត់ទៅបាត់ហើយតើ តាម៉ុក ចាប់ទៅបាត់ហើយ ។

សុវណ្ណៈ គេចាប់គាត់រឿងអីគេ?

ភាពៈ រឿងផ្ទៃក្នុងគេ មីងមិនដឹងដែរ មិនដឹងថាគេចាប់រឿងអី គ្នាគាត់គេហៅឡើងឡានទៅក៏បាត់ខ្លួនរហូតមិនដឹងថា មានទោសពៃរ៍យ៉ាងណាយ៉ាងណី ផ្ទៃក្នុងមីងមិនបានដឹងដែរ ។

សុវណ្ណៈ ចឹងមីងមករស់នៅដំបូងទិដ្ឋភាពនៅនេះយ៉ាងម៉េចដែរ កន្លែងនេះជាតំបន់យ៉ាងម៉េច ជាព្រៃឬមួយស្អាតទូលាយចឹង?

ភាពៈ កាលហ្នឹងនៅព្រៃ នៅព្រៃខ្លះ គេនៅមុនដែលតែមិនមានវាលដូចជារាល់ថ្ងៃទេ មានព្រៃស្តុកចឹងណា ដល់ពេលយើងនៅចេះតែត្រួសត្រាយទៅ ដល់ចេះតែធ្វើស្រែលិចកើតទៅបានវាលទៅ កាលមុនព្រៃ តែវាមិនមានព្រៃណាស់ណាទេ គេនៅខ្លះៗដែរ ។

សុវណ្ណៈ ចឹងមានផ្លូវថ្នល់កៅស៊ូស្អាតចឹងទេមីង?

ភាពៈ ផ្លូវកៅស៊ូគ្មានទេ បើផ្លូវនេះមាន ផ្លូវក្រហមមាន ផ្លូវដំបូងថៃចុះមកធ្វើ ។

សុវណ្ណៈ ផ្លូវនេះ?

ភាពៈ ចាស ។

សុវណ្ណៈ គេធ្វើឲ្យ?

ភាពៈ ចាស! ថៃវាចុះមកធ្វើទៅ វាឈូសឲ្យដល់ពេលយើងសមាហរណ៍កម្មទៅក៏រដ្ឋាភិបាល ភូមិឃុំយើងរៀបរាយទៅ យើងចាក់ដីបន្ថែមពីលើស្នាមចាស់ពីមុនណាស់ តែបើផ្លូវកៅស៊ូនោះគេធ្វើថ្មីទេ ផ្លូវទៅស្រែអែមអីហ្នឹងធ្វើថ្មី ។

សុវណ្ណៈ ចឹងប្រជាជនចុះមកដំបូងគេរកស៊ីអីគេ មីងពេលហ្នឹង?

ភាពៈ ធ្វើស្រែចម្ការ ។

សុវណ្ណៈ ចឹងក្មេងៗមានបានរៀនសូត្រអីទេ មានសាលាមានអីទេ?

ភាពៈ កាលចូលមុនដំបូងពេលសមាហរណ៍កម្មបានរៀនតើ ធ្វើកូនសាលាតូចៗ គេឲ្យរៀនបណ្ដោះអាសន្នណាស់ កូនខ្ញុំមី បង កាលវានៅតូចបានរៀន ឥឡូវវាទៅថៃហើយ កូនខ្ញុំកាលសមារណ៍កម្មវាអាយុ៨ឆ្នាំហើយ បានរៀនហ្នឹងគេ ។

សុវណ្ណៈ សាលានៅណាកាលហ្នឹង?

ភាពៈ នោះសាលាខាងនោះវត្ត ចឹងចេះតែរៀនៗទៅបានប៉ុន្មានឆ្នាំមានគំរោងទៅបានធ្វើសាលារាល់ថ្ងៃបានធំដុំទៅ ។

សុវណ្ណៈ ចឹងកាលហ្នឹងឈឺស្កាត់អីយ៉ាងម៉េចដែរ មានពេទ្យមានអីទេ?

ភាពៈ ឈឺស្កាត់អីមានពេទ្យតើ តែឥឡូវភាគច្រើនចូលតែពេទ្យឈ្នួលហ្នឹង ។

សុវណ្ណៈ ចឹងខ្ញុំចង់និយាយពីមុនមកដំបូងៗអី ឈឺស្កាត់អីយ៉ាងម៉េចដែរ?

ភាពៈ ឈឺស្កាត់អីពឹងគ្នាឯង ដែលគេមិនទាន់រៀបរយគ្នាឯងធ្លាប់ពឹងពីមុនមកធ្វើពេទ្យពេលយើងឈឺស្កាត់រត់រកអ្នកហ្នឹងហើយ ទៅមានថ្នាំគេលក់ឲ្យខ្លះ គេឲ្យខ្លះទៅណាស់ ។

សុវណ្ណៈ ថ្នាំគេបានមកពីណាដែរ?

ភាពៈ ថ្នាំគេទិញទៅតាមរយៈហ្នឹង ពេលមានពេទ្យគេធំៗ គេចេះជំនាញៗ សុទ្ធតែពេទ្យកាត់ជើងសុទ្ធពេទ្យស្អីៗ ។

សុវណ្ណៈ ហើយចាប់ផ្ដើមមានគោរពសាសនាអីទេ ទៅវត្តអីមីងចាប់ផ្ដើមពេលណាដែរ?

ភាពៈ ពេលមានបុណ្យទាន ។

សុវណ្ណៈ ខ្ញុំចង់និយាយពីមុនមក យើងទើបសមាហរណ៍កម្មហើយយើងចូលវត្តឬនៅលើភ្នំយើងចូលវត្តតាំងពីនៅលើភ្នំ?

ភាពៈ នៅលើភ្នំនោះ យើងចង់ទៅវត្តទៅខាងដីថៃ ទៅវត្តថៃ ថៃមានបុណ្យទានយើងចង់ទៅវត្តទៅ មានយាយជីលោកសង្ឃថៃអី មកវែអន្ដាសដាក់បាតក៏ដាក់ទៅ ។

សុវណ្ណៈ ចឹងពេលចូលឆ្នាំអីយើងធ្វើយ៉ាងម៉េចទៅ?

ភាពៈ ចូលឆ្នាំ យើងលេងរបៀបប្រពៃណីគេ ។

សុវណ្ណៈ គេអត់មានហាមឃាត់យើងទេ?

ភាពៈ ទេ គេក៏លេងរបៀបប្រពៃណីដូចយើងដែលហ្នឹង ថៃគេមានប្រពៃណីដូចយើង ប្រពៃណីជាងយើងទៀតក្ដួយ ។

សុវណ្ណៈ ចឹងខ្ញុំចង់និយាយថា ក្នុងរបបបីឆ្នាំយើងអត់មានសាសនា យើងអត់មានវត្តអារាមត្រូវគោរពប្រត្តិបត្តិអីទេ ចង់ទៅវត្តអីបាន យើងចង់អុចធូបទានគោរពសាសនាក៏អត់បានដែរ ហើយខ្ញុំចង់សួរថា ចឹងយើងខានគោរពសាសនាហ្នឹងយូរមកហើយ ចឹងក្រោយមកយើងចឹងយើងឥឡូវគួរតែគោរពមិនគួរគោរពអីចឹង តើមីងយល់ឃើញយ៉ាងម៉េចដែរ ព្រោះយើងខានគោរពសាសនា៣ទៅ៤ឆ្នាំចឹង ក្នុងរបបបីឆ្នាំយើងអត់មានបានធ្វើអីទាំងអស់ចឹងដល់ពេលយើងរត់ឡើងលើភ្នំយើង គិតថាគោរពក៏បានមិនគោរពក៏បានអី មានគិតចឹងទេមីង?

ភាពៈ អត់ទេ ខ្ញុំនិយាយពីគេអ្នកផ្សេងអត់ដឹងដែរ បើនិយាយពីខ្ញុំ ទោះបីអត់មានវត្តអត់មានអីក៏ដោយឆ្ងាយវត្តឬនៅរោងក្នុងព្រៃមានប្រក់តែកៅស៊ូក៏ដោយ គឺពេលបុណ្យខ្ញុំអត់មានចោលទេ នៅតែដុតធូបនៅតែគោរព នៅតែរំលឹកនិយាយមួយម៉ាត់នៅតែរំលឹក ទោះបីខ្ញុំមិនបានទៅវត្តក៏មានបាយមានសម្ល ដូចថាយើងអត់មានផ្ទះយើងប្រក់តង់ក្រាលកន្ទេលនៅដីក៏ខ្ញុំនៅតែដុតធូបខ្ញុំនៅរំលឹក ធូបខ្ញុំអត់ចោលទេ ខ្ញុំទៅថៃអីឲ្យថៃទិញមកដាក់ក្នុងសាក់កាដូខ្ញុំទុកស្រេច ពេលថ្ងៃសិលឬមានបុណ្យអីខ្ញុំដុតរំលឹកដាក់ដោតទៅដីទៅ អត់មានដែលចោលទម្លាប់ទេ ។

សុវណ្ណៈ ចឹងមីងមានសល់របស់ចាស់ៗអីពីមុនមានដូចជារូបថត ដូចជាសាក់កាដូអីឬមានរបស់របរមីងធ្លាប់ធ្វើពេទ្យពីមុនមកមីងមានសល់ខ្លះទេ?

ភាពៈ អត់មានទេ ក្ដួយរូបថតអី អស់រលីង រូបថតជិនាន់តាម៉ុក ថតទៅក៏ជាប់តាមមិត្តភក្តិពួកថៃវាសុំយកទៅ ។

សុវណ្ណៈ ចឹងមីងថាមានលុយសន្លឹកសល់ពីសង្គមមកអី?

ភាពៈ សល់ពីសង្គមមិនដឹងជានៅណាណី ។

សុវណ្ណៈ របស់របរដូចជាកាដុងទឹកអី សម័យទាហានអី?

ភាពៈ កាដុងទឹកសម័យទាហាននៅកាដុងមួយមិនដឹងជានៅណាទេ ។

សុវណ្ណៈ មានសាក់កាដូទេ?

ភាពៈ សាក់កាដូពួកហ្នឹងយកទៅព្រៃ កូនវាយកទៅឡើងក្រញ៉ូងអីវាយកទៅបោះចោលបាត់ទៅ សាក់កាដូចិនអាពណ៌ខៀវ មានតែអាហ្នឹងដៃវាស្តាយស្រួល ។

សុវណ្ណៈ ចឹងមីងមានរបស់អីសល់ចាស់ៗពីមុនមកទេ ជំនាន់តស៊ូអី?

ភាពៈ អត់មានទេ នៅសល់តែកាដុងមួយនេះឯង កាដុងកញ្ចាស់មួយ ក្រៅពីនោះអស់រលីងកូនប្រសារខ្ញុំវាឃើញប្លែកៗចេះតែប្រើ ខ្ញុំទុកអង្រឹងអ៊ុយអែសមួយ តាំងពី៨៥ម៉ែថ្មមទុកមិនហ៊ានប្រើទេទុកៗគ្រាន់មើលទៅ ទុកឲ្យពួកឯងសារក្រោយម៉ែបង្ហាញឲ្យមើល វាយកទៅភ្នំ អង្រឹងនេះស្អាត យកទៅមានអីពួកថៃវាបាញ់ព្រឹង វាចោលបាត់រត់បានតែខ្លួនអង្រឹងទុកចោលអត់អាអង្រឹងអ៊ុយអែសមួយស្តាយដែរ ។

សុវណ្ណៈ ចឹងមីងយល់ឃើញយ៉ាងម៉េចដែលជីវិតរស់នៅពេលបច្ចុប្បន្ននេះ ពីមុនវាខុសគ្នាយ៉ាងម៉េចដែរ ពេលនៅជំនាន់បីឆ្នាំ ពេលជំនាន់យើងរត់តស៊ូ ហើយនិងពេលបច្ចុប្បន្ននេះ មីងចូលចិត្តជីវិតរស់នៅមួយណាជាងគេ ហើយមីងគិតថាជីវិតរស់នៅមួយណាមានភាពល្អប្រសើជាងគេ ដែលមីងចូលចិត្ត?

ភាពៈ យើងឆ្លងកាត់ពីរជំនាន់ហើយណា ជំនាន់ប៉ុល ពត ។

សុវណ្ណៈ ជំនាន់ លន់ នល់?

ភាពៈ ជំនាន់ លន់ នល់ ជំនាន់ខ្មែរក្រហមនេះ ជំនាន់រត់តស៊ូវាមានពីរជំនាន់ហើយ ឡើងបីជំនាន់ហើយ ។

សុវណ្ណៈ ចឹងបើគិតជំនាន់តស៊ូបីបាត់ហើយ?

ភាពៈ បីហើយ ។

សុវណ្ណៈ ហើយចូលជំនាន់នេះទៀតឡើងបួនហើយ ហើយមីងយល់ឃើញជំនាន់មួយណា ថាមីងរស់នៅសប្បាយចិត្តជាងគេ?

ភាពៈ មីងតាំងពីធំដឹងក្តីមក មីងមិនដែលថា នៅសុខនៅស្រួលដូចថារកស៊ីអីបញ្ចេញគំនិតខ្លួនឯងឲ្យវាអស់ពីចិត្ត ទោះបីមានក្រយ៉ាងណាអីវាអត់ដឹង ដល់ពេលដឹងខ្លួនឡើងវាចាស់ហួសពេលបាត់ ដល់យើងដឹងក្តីយើងចេះរកអី សង្គមវាក្រឡាប់ចាក់វាម្តងចេះវាម្តងចុះប្រទេសជាតិយើងវាមានឯករាជ្យណា ក្មួយឃើញស្រាប់ហើយ ម្តងជំនាន់នេះម្តងជំនាន់នោះ អាយុយើងចេះតែជ្រុលទៅមុខ ជំនាន់នេះយើងឆ្លងកាត់មួយកាត់ទៅជំនាន់នោះយើងឆ្លងកាត់មួយកាត់ទៅ ជំនាន់នោះទៀត ទំរាំឆ្លងកាត់ចុះទៅៗ កាលស្រណុកកាលស្រួល ការមានការកើតអត់ដឹងទេ ដល់ពេលមកដឹងវាហួសពេលបាត់និងមានកើតយ៉ាងម៉េច វាមានកើតអីទេវាហួសពេលហួសវេលា តែការរស់នៅអី រាល់ថ្ងៃរស់នៅស្រួលជាងជំនាន់មុនៗ យើង

មានសិទ្ធធ្វើការងារ មានសិទ្ធដើរហើរឲ្យតែយើងមានលុយមានកាក់ ហើយយើងរកស៊ីចង់ធ្វើនំចំណីអី យើងទូលក់ដូរអី យើងធ្វើអីអត់មានពីណាហាមឃាត់ដែរ ចឹងដូចថាឥឡូវនេះវាស្រួល វារស់នៅស្រួល គេអ្នកផ្សេងមិនដឹងសម្រាប់មីងរស់នៅស្រួល មិនពិបាកអីទេ គ្មានពីណាមកគៀបសង្កត់អីយើងទេ ឲ្យតែយើងធ្វើត្រូវ កុំឲ្យតែយើងដើរដេរគេ ដើរដឹកស៊ីលក់ថ្នាំញៀនថ្នាំអីអាហ្នឹងយើងមានទោស យើងនៅធម្មតាទោះបីអ្នកធំ ថ្នាក់ប៉ុន្មានក៏គេមិនអាចមកមើលងាយយើងដែរ យើងនៅជាប្រជាជនធម្មតា គ្មានពីណាចេះមើលងាយមើលថោកយើងទេ ។

សុវណ្ណៈ ចឹងមីងមានមូលហេតុអីបានជាមីងចូលចិត្តរបបបច្ចុប្បន្ននេះ មានមូលហេតុអី?

ភាពៈ ព្រោះរស់នៅស្រួល ។

សុវណ្ណៈ ស្រួលយ៉ាងម៉េចមីង?

ភាពៈ ស្រួលអត់មានពីណាមកគំរាមកំហែងអី មានពីណាមកធ្វើអីយើង យើងធ្វើអីបានយើងទទួលផលទៅ យើងធ្វើស្រែបានយើងលក់ស្រូវយើងបានលុយដាក់ហោប៉ៅយើង ។

សុវណ្ណៈ ចឹងជំនាន់បីឆ្នាំ?

ភាពៈ ជំនាន់បីឆ្នាំយើងមានពេលណាទៅធ្វើ ធ្វើលួចលាក់គេថាយើងនេះកម្មសិទ្ធ គេថាយើងនេះមិនស្មោះត្រង់ របស់ពេញស្រឡាញ់ហើយគេត្រូវយកហើយៗ ។

សុវណ្ណៈ ចឹងជំនាន់យើងតស៊ូនោះ?

ភាពៈ ជំនាន់តស៊ូធ្វើអីក៏មិនស្រួលដែរ អត់ស្រួលទេ ។

សុវណ្ណៈ អត់ស្រួលយ៉ាងម៉េចមីង?

ភាពៈ អត់ស្រួលមានការលំបាក ឧទាហរណ៍យើងមានផ្ទះមានសំបែងចឹង តែយើងមិនបានឋិតថេរថាជាផ្ទះរបស់យើងទេ មិនដឹងជាថ្ងៃណាយើងរត់ចោលទៅ មិនដឹងថ្ងៃណាយើងព្រាត់ទៅទៀត ចឹងកាលកណត់របស់យើងមិនបានម៉្ងត់ចត់ទេ ។

សុវណ្ណៈ ចឹងជីវិតជំនាន់ លន់ នល់ ជីវិតរស់នៅយ៉ាងម៉េច?

ភាពៈ ជំនាន់ លន់ នល់ ខ្ញុំនៅតូចដែរ ខ្ញុំមិនដឹង បើគេនាំនៅនោះចេះតែទៅនាំច្រៀងក៏ច្រៀងជំនាន់ លន់ នល់ មីងអាយុ១៣-១៤ឆ្នាំហ្នឹង ចុះជំនាន់ឆ្នាំ៧០អាយុ១២ហើយ ។

សុវណ្ណៈ ចឹងមីងនៅសព្វថ្ងៃហ្នឹង មានគេដាក់បង្ហាញបង្រៀនរឿងប្រវត្តិសាស្រ្តខ្មែរក្រហមទេ មីងដូចជាសៀវភៅខ្ញុំជូនមីងម្សិញមិញចឹង គេឲ្យក្មេងៗរៀនថ្នាក់ទី៩ថ្នាក់ទី១០ថ្នាក់១២អីមីងយល់ឃើញថា ការបង្រៀនរឿងរ៉ាវប្រវត្តិសាស្រ្តមុនៗប្រាប់ដល់ក្មេងៗហ្នឹងពីឆ្នាំ៧៥

ដល់៧៩ហ្នឹង មីងយល់ថាល្អឬមួយមិនល្អទេមីង ការដាក់បង្រៀនបែបហ្នឹង នៅតាមសាលារៀន?

ភាពៈ វាមិនជាស្អីទេ ព្រោះអីឲ្យក្មេងវាបានដឹងខ្លះៗ កុំឲ្យងងឹតថា ពុកតែនិយាយតគ្នាដល់ចឹងឲ្យបានដឹងនៅក្នុងសៀវភៅដែលគេចងក្រងទៅឲ្យបានដឹងខ្លះ ទោះបីជាច្បាស់មិនច្បាស់ក៏គេអាចសួរសាកដេញដោលអីបាន វាមិនជាទាស់ខុសអីទេ ។

សុវណ្ណៈ ចឹងមីងមានដែលនិយាយរឿងប្រាប់កូនចៅអីទេ ក្មេងៗអី?

ភាពៈ មាននិយាយខ្លះដែរ ជួនកាលក្មេងសាក្រោយនេះវាច្រើនស្រួល វាកើតមកវាទៅរៀនមានលុយដាក់ហោប៉ៅហើយម្យ៉ាងការងារអី ក្មេងរាល់ថ្ងៃវាតាមគ្នា ការងារអីវាមិនសូវជួយអីចេះតែលើកឡើងទៅ អញពីមុនមានការលំបាក មានការអីណា បើស្រួលដូចចេះបានរៀនទាល់តែចេះដឹងណាណី តែពិបាកសព្វគ្រប់ ។

សុវណ្ណៈ ច្រើននិយាយនៅពេលណាប្រាប់កូនចៅ?

ភាពៈ និយាយពេលវាហូបបាយអីចេះ ចេះតែណែនាំវាទៅ ចៅខ្ញុំនិយាយប្អូនដប់ម៉ាត់វាដើរទៅណាបាត់ទៅ ។

សុវណ្ណៈ ចឹងចៅអត់ស្តាប់ហ្នឹង មីងគិតថាយ៉ាងម៉េចដែរ?

ភាពៈ យូរៗទៅក៏ខ្ជិលនិយាយ អានោះវាធំៗបើមីតូចៗនោះវាមិនដឹងម៉េងអីទេ ។

សុវណ្ណៈ ចឹងមីងសព្វថ្ងៃនេះមានដែលនិយាយគ្នាជាមួយអ្នកជិតខាង ពីនេះពីនោះអីខ្លះទេមីង?

ភាពៈ ដើរព្រោកប្រាជ្ញ មាននិយាយអីទេ មានតែនិយាយថា រកអីបានចាយ អត់មានមុខរបរអីធ្វើម៉េច អត់មានលុយកាក់ចាយហ្នឹង ។

សុវណ្ណៈ យើងអត់មានពិភាក្សាគ្នារឿងទម្លាក់គ្រាប់អី ផ្លោងចុះឡើងភ័យខ្លាចអីទេ?

ភាពៈ អត់ទេ ។

សុវណ្ណៈ ចឹងច្រើននិយាយគ្នារឿងរកស៊ី ថាធ្វើយ៉ាងម៉េចបាន?

ភាពៈ ចាស!និយាយរឿងរកស៊ីធ្វើយ៉ាងណា យើងរកអីលក់អី ។

សុវណ្ណៈ ពេលយើងនិយាយចឹងទៅ យើងមានអារម្មណ៍សប្បាយចិត្តទេ?

ភាពៈ ចាស ។

សុវណ្ណៈ ព្រោះការពិភាក្សាយើងវាខុសពីការពិភាក្សាកាលជំនាន់បីឆ្នាំ?

ភាពៈ ចាស ។

សុវណ្ណៈ យើងពិភាក្សាគ្នារឿងចែករំលែកការផលលំបាកឲ្យគ្នាសោះ?

ភាពៈ ចាស!និយាយហើយក៏ដាក់រឿងមើលទៅ មានអារម្មណ៍សើចក្រេវៗទៅមានទៅពិបាកអី ។

សុវណ្ណៈ	ចឹងមីងមានអីចង់សួរខ្ញុំខ្លះទេមីង ខ្ញុំសួរមីងច្រើនហើយ ថ្ងៃនេះទៀតចង់ពីថ្ងៃហើយ តាំងពីម្សិញមិញពេលថ្ងៃដង មីងមានចង់សួរអីខ្ញុំខ្លះទេមីង ឬមានអីចង់បន្ថែមទេ?

ភាពៈ	មានចង់សួរអី និយាយមួយម៉ាត់មករកសំនួរអីវាអត់ឃើញ ដឹងថាចង់សួរអី ។

សុវណ្ណៈ	ចឹងមីងប្រវត្តិភូមិនេះយ៉ាងម៉េចដែលកាលពីមុន?

ភាពៈ	ប្រវត្តិភូមិនេះ មានសុទ្ធតែព្រៃហិតព្រៃហោង មានភូមិអី ។

សុវណ្ណៈ	ចឹងតា០៥គាត់មកគ្រប់គ្រង កាលហ្នឹងយ៉ាងម៉េចដែរ ការរស់នៅ?

ភាពៈ	កាលហ្នឹងមានព្រៃ កាលហ្នឹងគាត់គ្រប់គ្រង គាត់ត្រួសគាត់ស្ការទៅ ចែកដីចែកធ្លីទៅតាមអគ្គភាព គាត់ក៏រៀបចំជាដីឡូ អគ្គភាពគាត់នៅហ្នឹង ។

សុវណ្ណៈ	ចឹងកាលហ្នឹងកងពលណាគេគ្រប់គ្រងរបស់តា០៥ហ្នឹង?

ភាពៈ	ចាស!របស់តា០៥តែម្តង ។

សុវណ្ណៈ	របស់កងពល?

ភាពៈ	ខ្ញុំមិនដឹងជាកងពលណាមិនដឹងលេខកងពលណា ។

សុវណ្ណៈ	ចឹងអឹមានដឹងទេ កងពលណាគ្រប់គ្រងនៅភូមិនេះ?

ភាពៈ	"ជិតខាងនិយាយថា របស់តាម៉ុក" ។

សុវណ្ណៈ	ដឹងថារបស់តាម៉ុក តែគេមានកងពល លេខកងពលគេមួយៗ ។

ភាពៈ	មានពីណាមានតែ សួរ សារឿន ហ្នឹងហើយ ។

សុវណ្ណៈ	តែលេខប៉ុន្មានកងពលហ្នឹង?

ភាពៈ	មិនដឹងជាលេខប៉ុន្មានដឹងថា តា០៥ៗ ។

សុវណ្ណៈ	ចឹងតា០៥គាត់គ្រប់គ្រងនៅភូមិហ្នឹង?

ភាពៈ	ចាស ។

សុវណ្ណៈ	ចឹងតា០៦គាត់គ្រប់គ្រងនៅភូមិណាវិញ?

ភាពៈ	ខាងនោះ ។

សុវណ្ណៈ	ខាងនោះខាងណាវិញ?

ភាពៈ	ខាងអន្លង់វែងហ្នឹង ខាងពួក៩២០នៅខាងកើតស្រះឈូក កន្លែងតា០៦ ខ្ញុំធ្លាប់ទៅពីរបីដងដែរ ។

សុវណ្ណៈ	ចឹងខ្ញុំដូចជា បើមីងអត់មានអីបន្ថែមខ្លះទេមីង?

ភាពៈ	ខ្ញុំរកគិតសំនួរអត់ឃើញ ។

សុវណ្ណៈ	លោខ្ញុំសួរមីងទៅ មីងគិតថាមានអីចង់បន្ថែមលើហ្នឹងទៀត មីងមានអីចង់សួរខ្លះទេ?

ភាព៖ ខ្ញុំមិនដឹងជាសួរអី មានឆ្ងល់អី វាឆ្ងល់ដែលតែរកគិតវាមិនឃើញ មិនដឹងជាសួរអី ។

សុវណ្ណៈ ចឹងខ្ញុំដូចជាមានប៉ុណ្ណឹង ខ្ញុំអត់មានអីច្រើន ។

ភាព៖ ចាស ។

សុវណ្ណៈ គិតថា សួរច្រើនហើយ ចឹងបើសិនជាមីងមិនមានទេ ខ្ញុំសូមអរគុណច្រើន ។

ភាព៖ ចាស ។

សុវណ្ណៈ ចឹងខ្ញុំសូមអរគុណដែលបានផ្តល់បទសម្ភាសឲ្យខាងខ្ញុំ ។

ភាព៖ ចាស!ខ្ញុំក៏អរគុណដែរ ខ្ញុំនិយាយតិចភ្លេចច្រើនចេះ ចេះតែនិយាយទៅអាណាដែលចាំ ។

សុវណ្ណៈ មិនអីទេមីង ។

ភាព៖ ចាស ។

**ចប់**